ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



## មជ្ឈមណ្ឌលឯកសារខេត្តតាកែវ

- « អ្វីទៅជាការពិត? »
- ប្រជាជន មន្ត្រីមូលដ្ឋានឃុំ និងសិស្សានុសិស្សមកទស្សនាពិព័រណ៍រូបថត

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខពិសេស ឆ្នាំ២០២៣

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារខេត្តតាកែវ

លេខពិសេស ឆ្នាំ២០២៣

# មាតិកា


**ផ្នែកសំបុត្រ**

◆ « អ្វីទៅជាការពិត? » ........................... ១

**ផ្នែកឯកសារ**

◆ ដូ ដុនហ៊ិន ប្រជាជនថ្មី ........................... ៩

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»............ ១៣

◆ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យធ្វើប្រធានក្រុម..... ១៧

◆ ង៉ែត មោង្ស ៖ អតីតទាហានកន្សែងស..... ១៩

◆ ម៉ម វ៉ាន់ស៊ុ ៖ នារីពេទ្យខ្មែរក្រហម .......... ២១

◆ ចាប គីមណា ៖ កងនារីក្នុងរបបខ្មែរក្រហម .. ២៣

◆ ញឹម សំកើ ៖ គ្រួសារខ្ញុំត្រូវជម្លៀសទៅកាន់ ស្រុក១០៩ ដោយសារកំហឹងរបស់......... ២៤

◆ គី ហៀង ៖ ខ្ញុំចូលធ្វើទ័ពខ្មែរក្រហម ......... ២៦

◆ ធឹក ង៉ែត ៖ កងនារីស្រែអំបិល ............. ២៩

◆ មួយទសវត្សរ៍ធ្វើទាហានបីរបប ............ ៣១

◆ ខ្ញុំរស់នៅរងទុក្ខលំបាក ស្ទើរតែទ្រាំពុំបាន.... ៣៣

◆ មាស ផាត ៖ កម្មករស្រែអំបិលកែប........ ៣៤

**ផ្នែកវេទិកាពិភាក្សាសាធារណៈ**

◆ ប្រជាជន មន្ត្រីមូលដ្ឋានឃុំ និងសិស្សានុសិស្ស មកទស្សនាពិព័រណ៍រូបថតអចិន្ត្រៃយ៍ ....... ៣៦

◆ យុវជនស្រុកបាទី ខេត្តតាកែវ ផ្តល់ក្តីគោរពដ៏ជ្រាលជ្រៅ ដល់អ្នកស្លាប់ពីរបបខ្មែរក្រហម.. ៣៨

◆ សិស្សានុសិស្សមកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ ........... ៤១

◆ សិស្សានុសិស្សមកពីវិទ្យាល័យ ជា ស៊ីម តាកែវ សិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជា............... ៤៥

◆ វេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «មូលហេតុនៃការកកើតខ្មែរក្រហម» នៅមជ្ឈមណ្ឌល ឯកសារ ខេត្តតាកែវ ........................... ៥០

◆ វេទិកាអប់រំសហគមន៍ ស្តីពីការសន្ទនាអន្តរជំនាន់ អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) នៅវត្តត្រើយឃ្លោក ....... ៥៤

**ផ្នែកស្រាវជ្រាវរកក្រួសារ**

◆ ឈន ឧិន្នែត ៖ ខ្មែរក្រហមយកឪពុកខ្ញុំទៅសម្លាប់ ដោយសារតែបណ្តោយឲ្យគោ ស៊ីកណ្តាប់.... ៥៩

◆ ប៊ុន វ៉ាត ៖ ឪពុកម្តាយខ្ញុំស្លាប់ដោយសារជំងឺ និងអត់អាហារ ............................... ៦០




រូបពីឆ្វេងទៅស្តាំ៖ អុល, អ៊ីម, ផេង, អោ, ញ៉េប (សុខ), សាន្ត សុខ និងផ្សេងៗ សាន្ត សុខ រួមចលនាតស៊ូបដិវត្តន៍ ថតរួមជាមួយប្អូនៗ បុគ្គលិកអង្គភាព គណៈកម្មាធិការទទួលប្រជាជនជម្លៀស ស្រុកព្រៃកប្បាស (ហៅស្រុក៥៥) ឆ្នាំ១៩៧២។ (សាន្ត សុខ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** គ្រេក អ៊ិចជេសាន់, សុង ថាណៃ, ផេង ពង្សរ៉ាស៊ី, សៀង កញ្ញា, រឹម ស្រីស្រស់, ង៉ាន់ វីន, ហៀក ស្រីពេជ្រ, ភា រស្មី និង ជីម សុខគា,

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ផាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដា៉វរដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង


Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# « អ្វីទៅជាការពិត? »

មជ្ឈមណ្ឌលឯកសារកម្ពុជា



*ព្រះពុទ្ធត្រាស់ដឹងនៅក្រោមម្លប់ពោធិ៍ព្រឹក្ស។*
*(កែវ ធាស្រ៊ុន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

«**អ្វីទៅជាការពិត?**» ហាក់បីដូចជាសំណួរមួយដ៏គួរឲ្យអស់សំណើចៗ ចំពោះមនុស្សភាគច្រើនអ្វីទៅជាការពិត? ជាធម្មតា ហាក់បីដូចជាច្បាស់ក្រឡែត ដូចជាគ្មានអ្វីគួរឲ្យលំបាកយល់ទាល់តែសោះ ប្រសិនបើនរណាម្នាក់យកសត្វឆ្មាពណ៌ខ្មៅមួយក្បាលបង្ហាញយើងហើយប្រាប់ថា «ជាឆ្មាពណ៌ស» នៅពេលនោះយើងអាចដឹងភ្លាមថា នោះមិនមែនជាការពិតទេ។ ផ្ទុយមកវិញ ប្រសិនបើគេយកសត្វឆ្មាខ្មៅមួយ ហើយប្រាប់យើងថាជាឆ្មាខ្មៅនោះ យើងអាចមានអារម្មណ៍ដឹងច្បាស់ថា នេះជាការពិត។ ដូច្នេះ «ការពិត» ហាក់បីដូចជា សាមញ្ញមួយក៏ប៉ុន្តែក្នុងភាពជាក់ស្តែងក្នុងសង្គមមនុស្ស «ការពិត» ពុំមែនជារឿងសាមញ្ញមួយនោះទេ។ បញ្ហាមួយក្នុងវង្វង់ចំណោមបញ្ហាទស្សនវិជ្ជាដ៏ធំធេងបំផុតសម្រាប់មនុស្សគ្រប់ជំនាន់នោះគឺធ្វើយ៉ាងដូចម្តេចទើបដឹងថា អ្វីជាការពិតនេះឯង។

ព្រះពុទ្ធជាម្ចាស់ ទ្រង់ក៏បានទទួលស្គាល់យ៉ាងច្បាស់នូវបញ្ហានេះ។ ព្រះពុទ្ធមានពុទ្ធដីកាប្រៀនប្រដៅថា អ្វីៗដែលមើលនឹងភ្នែកឃើញច្បាស់ក្រឡែតបំផុតក្នុងលោកជាច្រើនដែលមនុស្សលោកបានជួបប្រទះក្នុងជីវិត ហើយតាមធម្មតាយើងមានអារម្មណ៍

ថា «មែនទែន» ឬ «ពិត» នោះគឺសុទ្ធសឹងតែជាការស្រមើស្រមៃទាំងអស់ ដែលនាំឲ្យយើងទាំងអស់គ្នាភ័ន្តច្រឡំអំពី «ការពិត» ។

ប្រសិនបើលោកអ្នកឃ្លានអាហារ ឬក៏ប្រសិនបើលោកអ្នកស្រឡាញ់នរណាម្នាក់ ឬ ប្រសិនបើលោកអ្នកបានជួបប្រទះការខឹងក្រេវក្រោធ ឬការស្អប់ខ្ពើមចំពោះ «សត្រូវ» ណាមួយនោះ ជារឿយៗលោកអ្នកយល់ឃើញថាអារម្មណ៍ទាំងអស់នេះគឺ «ពិត» ព្រោះថាអារម្មណ៍ទាំងនេះ ឆ្លុះបញ្ចាំងអ្វីមួយដែលពិតហើយមានការពិតក្នុងលោក ពីព្រោះមនុស្សគ្រប់រូបសុទ្ធតែមានអារម្មណ៍បែបនេះ។ ក៏ប៉ុន្តែនេះពុំមែនអ្វីដែលព្រះពុទ្ធជាម្ចាស់ប្រៀនប្រដៅនោះទេ។ ព្រះពុទ្ធបានបង្រៀនថាអារម្មណ៍បែបនេះបានត្រឹមតែនាំមុខឲ្យមនុស្សឃ្លាតឆ្ងាយពីការយល់ដឹងពិតតែប៉ុណ្ណោះ។ យោងទៅតាមព្រះពុទ្ធជាម្ចាស់ ផ្លូវអារម្មណ៍និងការស្រេចឃ្លានរបស់មនុស្សលោក គឺពុំមែនជាផ្លូវនាំរកការពិតឡើយ។ នេះបង្ហាញថា ព្រះពុទ្ធជាម្ចាស់បានយល់ច្បាស់អំពីខ្លឹមសារនៃបញ្ហាថា «អ្វីជាការពិត?» នេះ។

ទស្សនវិទូក្នុងលោក បានស៊ិតស៊ាញស្វែងរកចម្លើយទៅនឹងបញ្ហានេះ តាមរយៈការស្រាវជ្រាវពីប្រវត្តិសាស្ត្រពិភពលោកទាំងមូលដែលបានកត់ត្រាទុក ហើយគួរឲ្យភ្ញាក់ផ្អើលណាស់អស់រយៈពេលរាប់ពាន់ឆ្នាំ នៃការពិតពិចារណាយ៉ាងហ្មត់ចត់ដោយអ្នកប្រាជ្ញដ៏ឈ្លាសវៃបំផុតក្នុងលោក មកទល់នឹងពេលនេះនៅតែពុំមានការឯកភាពគ្នា ដែលមានមូលដ្ឋានរឹងមាំ និងអាចទទួលបានជាសកលថា តើអ្វីប្រាកដដែលជាសារជាតិនៃការពិតនៅឡើយ។ មានមែកធាងប្រវត្តិវិទ្យាមួយហៅថា «ទ្រឹស្តីនៃចំណេះដឹង» ដែលផ្តោតទៅលើការជជែកវែកញែកពីអ្វីដែលជាការពិត ហើយថាតើធ្វើដូចម្តេចទើបយើងអាចដឹងថា អ្វីមួយជាការពិតនៅពេលដែលយើងឃើញឬជួបប្រទះ។ មានផ្នែកស៊ើបអង្កេតវិទ្យាសាស្ត្រមួយទៀតហៅថា ទស្សនវិជ្ជានៃវិទ្យាសាស្ត្រ ពីព្រោះអ្នកវិទ្យាសាស្ត្រជាច្រើនជឿថា គោលបំណងនៃវិស័យវិទ្យាសាស្ត្រទាំងមូលគឺពិតជាគ្មានអ្វីក្រៅពីស្វែងរកការពិតនោះទេ។ ទោះជាយ៉ាងនេះក្តី ក៏នៅតែមានការវិភាគវែកញែកដ៏ក្តៅគគុកមួយអំពីការពិតនៅឡើយ ក្នុងចំណោមអ្នកទស្សនវិទូផ្នែកវិទ្យាសាស្ត្រទាំងនោះ ហើយបញ្ហានេះ នៅតែជាការពិភាក្សាដ៏ស្មុគស្មាញមួយ។

ជនជាតិក្រិចកាលពីសម័យបុរាណ បានប្តេជ្ញាយកចិត្តទុកដាក់ដ៏ច្រើនសន្ធឹកសន្ធាប់ទៅលើចំណោទបញ្ហាថាអ្វីទៅជាការពិត? ហើយអរិយធម៌របស់ជនជាតិក្រិច គឺជាអរិយធម៌ដំបូងគេបង្អស់ក្នុងលោកនេះដែលបានកត់ត្រាយ៉ាងប្រុងប្រយ័ត្ននិងល្អិតល្អន់នូវរាល់គំនិត និងការពិភាក្សារបស់ខ្លួនអំពីបញ្ហានៃការពិតនេះ។ អ្នកទស្សនវិទូជនជាតិក្រិចដ៏ល្បីល្បាញបំផុតគឺលោកអារីស្តូត ដែលបានប៉ុនប៉ងចាប់យកផ្នែកមួយនៃចំណោមបញ្ហានៃការពិតមកដោះស្រាយបង្ហាញ។

លោក អារីស្តូត បានរិះរកឃើញប្រព័ន្ធ «តក្កវិជ្ជា» មួយ។ គាត់បានចាប់ផ្តើមដោយសំណើដែលបង្ហាញភស្តុតាងច្បាស់បំផុតដោយខ្លួនឯងគឺ «វត្ថុមួយមានតម្លៃស្មើនឹងខ្លួនឯង»។ ទំនាក់ទំនងនេះត្រូវបានហៅថា «អត្តសញ្ញាណ» ហើយអាចត្រូវបានឆ្លុះបញ្ចាំងក្នុងទម្រង់ជានិមិត្តសញ្ញា «ក ស្មើនឹង ក»។ ចេញពីការអង្កេតក៏ងាយស្រួលបំផុតនេះ អារីស្តូតបានបន្តរិះរកបង្កើតប្រព័ន្ធតក្កវិជ្ជានេះ ជាឧទាហរណ៍ យើងអាចបង្កើតសមភាព «តក្កភាព» ឬ «ទំនាក់ទំនងតក្ក»។

ឧទាហរណ៍នៃតក្កភាពដែលមានជាយូរលង់ណាស់មកហើយនោះគឺ «មនុស្សទាំងអស់ស្លាប់។ សូក្រាតគឺជាមនុស្ស។ នាំឲ្យសូក្រាតត្រូវតែស្លាប់»។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើយើងផ្លាស់ប្តូរសមភាពនេះតែបន្តិច ហើយជំនួសវិញដោយ «សំណើថាមនុស្សទាំងអស់ស្លាប់ សូក្រាតគឺជាមនុស្ស ដូច្នេះសូក្រាតត្រូវតែស្លាប់ជាការពិត» នៅពេលនោះ យើងនឹងឃើញមានបញ្ហា។ សំណើទី២នេះ បើនិយាយឲ្យលម្អិតទៅលើន័យគឺការដាក់ឈ្មោះឲ្យខុស ដែលជាមូលហេតុនាំឲ្យមានការភ័ន្តច្រឡំ។ បើនិយាយឲ្យត្រឹមត្រូវប្រាកដតក្កភាពអំពីការស្លាប់របស់សូក្រាតគឺមិនមែនមានឈ្មោះថាជា «ការពិត Truth» ទេ ប៉ុន្តែមានឈ្មោះថា «មានន័យ Valid»។ សំណើដែលមានន័យគឺជាសំណើដែលក្នុងនោះពុំមានភាពមិនត្រឹមត្រូវគ្នាលើតក្កភាព ឬភាពផ្ទុយគ្នាខាងក្នុងសំណើនោះ។

ភាពខុសប្លែកគ្នារវាង «ការពិត» និង «មានន័យ» បានបង្កើតឲ្យមានបញ្ហាជាច្រើន ក្នុងចំណោមប្រភេទមនុស្សដ៏ឆ្លាតវៀងវៃជាច្រើន អស់រយៈពេលដ៏យូរលង់ណាស់មកហើយ។ ភាពខុសប្លែកគ្នានេះ អាចត្រូវបានប្រទះឃើញនៅក្នុងប្រវត្តិនៃមែកធាងគណិតវិទ្យា ហៅថាធរណីមាត្រ។ ទស្សនវិទូជនជាតិក្រិចនាសម័យបុរាណម្នាក់ទៀត ឈ្មោះ អ៊ុគ្លីត បានបង្កើតប្រព័ន្ធគណិតវិទ្យាមួយពាក់ព័ន្ធទៅនឹង បន្ទាត់ មុំគម្លាត ចន្លោះបន្ទាត់ពីលក្ខណៈពិសេស និង រាងដែលកើតចេញពីការផ្គុំបន្ទាត់។ ប្រព័ន្ធធរណីមាត្រនេះ ត្រូវបានដាក់ឈ្មោះថា «ធរណីមាត្រអ៊ុគ្លីត» ហើយសព្វថ្ងៃនេះប្រព័ន្ធធរណីមាត្រនៅតែជាផ្នែកដ៏សំខាន់មួយសម្រាប់ការបង្រៀននៅតាមសាលាគ្រប់ទីកន្លែង ទូទាំងពិភពលោក អស់រយៈពេល ២៣០០ឆ្នាំ បន្ទាប់ពីគាត់បានច្នៃប្រឌិតប្រព័ន្ធនេះ។ អ៊ុគ្លីត គឺជាអ្នកប្រាជ្ញដើរតាមគន្លងរបស់អារីស្តូត ហេតុដូច្នេះហើយ គោលការណ៍ធរណីមាត្ររបស់អ៊ុគ្លីត ត្រូវបានបង្កើត ហើយអនុវត្តទៅតាមក្បួនច្បាប់នៃតក្កភាពរបស់អារីស្តូត។ ជាឧទាហរណ៍សំណើថា «នៅក្នុងត្រីកោណប្រភេទណាក៏ដោយ មុំពីរបូកបូលគ្នាត្រូវតែតិចជាងមុំកែងពីរ» ពីព្រោះថាសំណើនេះ ដែលជាការពិតតាមតក្កវិជ្ជាឥតខ្ចោះបានដើរតាមក្បួនច្បាប់នៃតក្កភាពរបស់អារីស្តូត។ អ៊ុគ្លីតជឿថា ប្រព័ន្ធនេះបានពិពណ៌នាអំពីការពិតរបស់ធម្មជាតិដែលគ្មាននរណាអាចផ្លាស់ប្តូរបាន។ ក៏ប៉ុន្តែជំនឿរបស់អ៊ុគ្លីតប្រែជាពុំសូវត្រឹមត្រូវឡើយ។

ជាច្រើនសតវត្សរ៍ក្រោយមកអ្នកប្រាជ្ញគណិតវិទ្យាមួយក្រុមរួមបញ្ចូលទាំង ឡាបាឆេវស្គី Labachevsky បូលីយ៉ា Bolyai ហ្គោស Gauss និង រៀម៉ាន់ Riemann បានបង្កើតផ្នែកមួយនៃគណិតវិទ្យា ដែលឥឡូវនេះហៅថា ធរណីមាត្រមិនអ៊ុគ្លីត។ នៅក្នុងប្រព័ន្ធធរណីមាត្រទាំងនេះ សំណើរបស់អ៊ុគ្លីតមួយចំនួនពុំពិតទាំងអស់ទេ! បើធ្វើការប្រៀបធៀបទៅនឹងទ្រឹស្តីអារីស្តូត នៅក្នុងធរណីមាត្រមិនអ៊ុគ្លីតអាចទាញថា «ក មិនស្មើនឹង ក» ទេក្នុងករណីមួយចំនួន។ ការអះអាងបែបនេះ នាំឲ្យមានការពិភាក្សាដែលពិបាកនឹងរកដំណោះស្រាយថា តើធរណីមាត្រមួយណា «ពិត» ធរណីមាត្រអ៊ុគ្លីតឬធរណីមាត្រមិនអ៊ុគ្លីត? ដោយហេតុថា បញ្ហាបែបនេះលេចឡើងជាញឹកញាប់ទើលំបាកនេះ បណ្តាលឲ្យមានការភ័ន្តច្រឡំណាស់ ពីព្រោះថាសំណួរខាងលើនេះជាសំណួរដែលត្រឹមត្រូវ។ ចម្លើយគឺថាពុំមានធរណីមាត្រណា «ពិត» នោះទេ។ ប៉ុន្តែចំពោះប្រព័ន្ធតក្កនិងប្រព័ន្ធធរណីមាត្រត្រូវបានហៅថា «មានន័យ» ពីព្រោះថាក្បួនច្បាប់របស់ប្រព័ន្ធធរណីមាត្រនេះ គឺមានភាពសមភាពត្រូវគ្នាទាំងអស់។ «មានន័យ» គឺសំដៅតែទៅលើភាពត្រូវគ្នាខាងក្នុងទំនាក់ទំនងតក្ក ក្នុងចំណោម ឬរវាងសំណើទាំងឡាយ។ ផ្ទុយទៅវិញ «ការពិត» សំដៅទៅលើទំនាក់ទំនងមួយរវាងអំណះអំណាងជាភាសាមួយទៅនឹងភាពជាក់ស្តែងតាមការអង្កេត និងការពិសោធន៍ជាសត្យានុម័ត។

ទោះបីជាយ៉ាងដូច្នោះក៏ដោយ ជនជាតិក្រិចនាសម័យបុរាណប្រើពាក្យ២ខុសពីគ្នា។ ពាក្យទាំង២នោះ បកប្រែទៅជាភាសាអង់គ្លេសថា «Truth» ហើយជាភាសាខ្មែរថា «ការពិត»។ ពាក្យទី១ជាភាសាក្រិចដែលមានន័យថា«ការពិត» គឺ «Episteme»។ ការពិតនេះឈរលើគោលការណ៍នៃចំណេះដឹងពិតដែលមានតែព្រះ «អាចថាព្រះមួយ ឬច្រើនអាស្រ័យទៅលើជំនឿសាសនារបស់មនុស្ស» ជាអ្នកបង្កើតចក្រវាឡ។ ពាក្យក្រិច Episteme មានន័យថា ការដឹងពិតទាំងស្រុងអំពីចក្រវាឡដែលមនុស្សគ្មានជីវិតអមតៈ ដូចជារូបយើងទាំងអស់គ្នាមិនអាចយល់បាន។ នេះមានន័យថា មានតែព្រះទ្រង់ត្រាស់ដឹងអ្វីៗទាំងអស់ក្នុងចក្រវាឡ។ ពាក្យទី២ ដែលជនជាតិក្រិចនាសម័យបុរាណ ប្រើសម្រាប់ពាក្យថា «ការពិត» នោះគឺ Noesis។ ក្នុងន័យនៃពាក្យនេះ ការពិតឆ្លុះបញ្ចាំងតាមពិភពនៃបទពិសោធន៍និងការយល់ឃើញតាមបញ្ញាធម្មតារបស់មនុស្សទូទៅ។ និយាយម្យ៉ាងទៀតពាក្យថា Noesis គឺស្ថិតនៅក្នុងកម្រិតនៃសមត្ថភាពការយល់ដឹងរបស់មនុស្សទូទៅ ការពិតប្រភេទនេះ គឺជាការពិតដែលអ្នកវិទ្យាសាស្ត្របានស្វែងរក។ តាមពិតអត្ថន័យនៃការពិតនេះ គឺជាការពិតដែលត្រូវបានគ្រប់គ្រងមួយកម្រិតដោយមនុស្សលោកដែលបានស្រាវជ្រាវរកបានដោគជ័យ។

អ្នកប្រាជ្ញទស្សនវិជ្ជាដ៏ល្បីល្បាញជាងគេបំផុត ឈ្មោះ អាល់បឺត អេនស្តែន Albert Einstein នៅពេលដែលគាត់បានធ្វើសេចក្តីអធិប្បាយមួយអំពីទ្រឹស្តីការពិត Noesis ថា «អ្វីដែលពិបាកយល់បំផុតអំពីចក្រវាឡគឺថា ចក្រវាឡអាចយល់បាន»។

នៅក្នុងសេចក្តីអត្ថាធិប្បាយនោះលោក អេនស្តែន បានវេចខ្ចប់អាថ៌កំបាំងមួយ ក្នុងចំណោមអាថ៌កំបាំងដែលស្ថិតក្នុងភាពងងឹតជាយូរយារណាស់មកហើយ នៅក្នុងទស្សនវិជ្ជាវិទ្យាសាស្ត្រ។ ហេតុអ្វីបានជាគណិតវិទ្យា «ផ្តល់ផលប្រយោជន៍?» ហេតុអ្វីបានជាទ្រឹស្តីវិទ្យាសាស្ត្រជាច្រើន អនុញ្ញាតឲ្យយើងអាចទស្សន៍ទាយបានយ៉ាងត្រឹមត្រូវខ្លាំងម្ល៉េះ អំពីអ្វីៗជាច្រើននៅពិភពខាងក្រៅ? អ្វីទៅជាទំនាក់ទំនងរវាងទ្រឹស្តីវិទ្យាសាស្ត្រទាំងនោះទៅនឹងពិភពលោកដែលអនុញ្ញាតឲ្យយើងបានយល់អំពីអ្វីដែលកំពុងប្រព្រឹត្តនៅជុំវិញខ្លួនយើង? និយាយម្យ៉ាងទៀត អ្វីគឺជាលក្ខណៈនៃ «ការពិត»? បញ្ហានេះចាប់ផ្តើមចូលទៅក្នុងបញ្ហាទស្សនវិជ្ជាដែលសិក្សាអំពីសារជាតិនៃការពិត និងអត្ថិភាពនៃការពិតហើយ ត្រង់ហ្នឹងហើយដែលបញ្ហានៃការពិតចាប់ផ្តើមកាន់តែស្មុគស្មាញ។

ទស្សនវិទូផ្នែកវិទ្យាសាស្ត្រ ឈ្មោះ កាល ប៉ុបព័រ Karl Popper ព្យាយាមទំលុះអាថ៌កំបាំងទាំងនេះ គឺមូលហេតុអ្វីបានជាទ្រឹស្តីវិទ្យាសាស្ត្រ ហាក់បីដូចជា «ត្រឹមត្រូវ» យ៉ាងខ្លាំងទៅនឹងពិភពលោក។ ប៉ុបព័របានសន្និដ្ឋានការពិតថា មានពិភពផ្សេងៗជាច្រើន។ ពិភពមួយគឺពិភពខាងក្រៅ «សត្យានុម័ត» គឺពិភពខាងក្រៅខ្លួនយើង ដែលពាសពេញទៅដោយពិភពផ្កាយ រុក្ខជាតិ និងសត្វនានា និងអ្វីៗផ្សេងទៀតផងទាំងពួង។ ពិភពមួយទៀតគឺពិភព«អត្តនោម័ត» នោះមានន័យថា ពិភពដែលមាននៅក្នុងចិត្តរបស់យើងគ្រប់ៗគ្នា។ ប៉ុបព័របានប៉ុនប៉ងពិពណ៌នាប្រព័ន្ធមួយ ដើម្បីឲ្យយើងជាមនុស្សលោក ដែលងប់ងុលនឹងពិភពអត្តនោម័តទាំងនោះ អាចយល់ដឹងពីវត្ថុផ្សេងៗក្នុងពិភពសត្យានុម័តខាងក្រៅ។ គាត់បានហៅប្រព័ន្ធនេះថា «តក្កភាពនៃរបកគំហើញវិទ្យាសាស្ត្រ»។ យោងទៅតាម ប៉ុបព័រ របៀបដែលតក្កភាពនៃរបបគំហើញវិទ្យាសាស្ត្រដំណើរការគឺពិតជាសាមញ្ញល្មមអាចយល់បាន។

លោក ប៉ុបព័រ បានពិពណ៌នាវិទ្យាសាស្ត្រថាជាដំណើរការនៃការបង្កើតអំណះអំណាង ដែលអាចយកមកសាកល្បងបញ្ជាក់ភាពពិតត្រឹមត្រូវ។

អ្នកវិទ្យាសាស្ត្រទាំងឡាយបានប៉ុនប៉ងបង្ហាញភស្តុតាងថាអំណះអំណាង ឬសមតិកម្មមួយចំនួនពុំមានការពិតឡើយ។ ប្រសិនបើអ្នកវិទ្យាសាស្ត្រទាំងនោះពុំអាចបង្ហាញឲ្យឃើញថា អំណះអំណាងណាមួយខុស អំណះអំណាងនោះរមែងជាការ «ត្រឹមត្រូវ»។ មធ្យោបាយនេះត្រូវបានហៅថា «ធ្វើកោសល្យ-វិច័យលើកំហុស» ពីព្រោះថាគោលដៅចម្បង គឺបង្ហាញភស្តុតាងថាអ្វីមួយខុស ហើយទទួលយកអ្វីដែលពុំអាចបង្ហាញខុសជាការ «ត្រឹមត្រូវ» តាមលក្ខណៈវិទ្យាសាស្ត្រ។ យ៉ាងហោចណាស់បង្ហាញភស្តុតាងថាអំណះអំណាងមួយ «ត្រឹមត្រូវ» សមហេតុផលបំផុតល្មមនឹងអាចទទួលយកបាន ប្រសិនបើយើងពុំទាន់បានជួបប្រទះការពន្យល់មួយថ្មីប្រសើរជាង ដែលពិពណ៌នាពីបាតុភូតនេះឲ្យបានពេញលេញនិងថែមទាំងពុំអាចបង្ហាញថា ខុសសូម្បីតែបន្តិច។ ប៉ុបព័រ បានទាញហេតុផលថា ឆ្លងកាត់មករាប់សិបសតវត្សន៍នៃការជឿទុកចិត្តលើការសាកល្បងអំណះអំណាងនានាតាមរបៀបនេះ ទ្រឹស្តីវិទ្យាសាស្ត្របែបទំនើបត្រូវបានច្នៃកែតម្រូវដែលជួយឲ្យយើងយល់បានយ៉ាងច្បាស់ អំពីរបៀបដែលពិភពលោកយើងនេះប្រព្រឹត្តទៅ ឧទាហរណ៍ ទ្រឹស្តីមេរោគនៃជំងឺឬតារាងធាតុបន្សំនៃគីមី។ នេះជារបៀបដែលវិទ្យាសាស្ត្រស្វែងរកប្រភេទនៃ «ការពិត»មួយ។

ក៏ប៉ុន្តែប្រភេទនៃការពិត ដែលរកឃើញនៅក្នុងវិទ្យាសាស្ត្រ គឺគ្រាន់តែជាប្រភេទមួយ ក្នុងចំណោមប្រភពនៃការពិតទាំងអស់ ដែលមនុស្សជាតិទាំងមូលបានដឹង។ មិនតែប៉ុណ្ណោះនៅមានការពិតផ្នែកសាសនា ការពិតផ្នែកអក្សរសាស្ត្រ និងអ្វីដែលយើងហៅថាការពិត «ផ្នែកនយោបាយ»។ អ្នកគោរពសាសនាធំដែលជឿថា មានព្រះតែមួយ ដូចជាសាសនាជ្វីហ្វ សាសនាគ្រីស្ត សាសនាអ៊ីស្លាម ជាដើម។ល។ ជឿថាការពិតគឺ ព្រះជាអ្នកមើលឃើញ និងប្រទានឲ្យ ដែលជំនឿបែបនេះត្រូវបានបកស្រាយបង្ហាញនៅក្នុងអក្សរចារឹក ឬ ក្នុងគម្ពីរ



*សត្វហើរនៅលើអាកាស នៅភ្នំគិរីរម្យ។*
*(ឆាំង យុ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

សាសនានានា។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺថា សាសនាទាំង៣នេះសុទ្ធតែបាន «ឆ្លុះបញ្ចាំង» ដូចគ្នាច្រើនជាទីបំផុត «ការពិតឬភាសាបាលីហៅថាសច្ចភាព» ដូចជា «យើងមិនត្រូវសម្លាប់អ្នកដទៃ» «យើងមិនត្រូវផិតក្បត់ជាដើម។ល។ ទាំងនេះគឺជាគោលការណ៍សីលធម៌ និងចរិយាធម៌ ឬក្បួនច្បាប់ដែលតាមរបៀបនេះមនុស្សទាំងឡាយត្រូវបានរំពឹងទុកថា នឹងយកមកអនុវត្តក្នុងការរស់នៅក្នុងសង្គម ហើយបើមនុស្សគ្រប់រូបប្រតិបត្តិតាមការពិតទាំងនេះ នោះពិភពលោកគឺប្រហែលជាកន្លែងមួយដ៏ប្រសើរ។ យ៉ាងហោចណាស់ពិភពលោកពិតជាមានសន្តិភាព នៅពេលដែលមនុស្សទាំងឡាយគោរពតាមក្បួនច្បាប់ទាំងនោះជាជាងការកាប់សម្លាប់គ្នានៅក្នុងការប្រកែកអំពីបញ្ហាថាតើក្បួនច្បាប់របស់អ្នកណាមួយដែលពិត! ស្រដៀងគ្នានេះដែរ «សាសនា» ដែលពុំជឿថាមានព្រះជាអ្នកបង្កើតលោកដូចជាសាសនាព្រះពុទ្ធ និង សាសនាដែលជឿថាមានព្រះច្រើនដូចជា សាសនាហិណ្ឌូ ក៏បានផ្តល់នូវក្បួនច្បាប់ឬ «សច្ចភាព» ដែលមនុស្សលោកអាចបញ្ឈដំណើរជីវិតរបស់ខ្លួនតាមគន្លងនោះ ហើយអាចយល់ពីទំនាក់ទំនងរបស់ខ្លួនទៅនឹងចក្រវាឡ។

រឿងនិទានមួយចំនួនដែលយើងអាចប្រទះឃើញនៅក្នុងអក្សរសាស្ត្រ ក៏មានប្រភេទនៃការពិតមួយផ្សេងទៅទៀត។ រឿងនិទានទាំងនោះត្រូវបាននិយាយតៗគ្នាពីមាត់មួយទៅមាត់មួយ ពីជំនាន់មួយទៅជំនាន់មួយ តាមទំនៀមទម្លាប់នៅក្នុងសង្គមមួយចំនួនដូចជារឿងព្រេងដែលបានកត់ត្រាទុកជាឯកសារ ដែលអាចរក្សាបានគង់វង្សមកទល់សព្វថ្ងៃនេះ និងរឿងប្រឌិតដ៏ល្បីល្បាញផ្សេងទៀត។ តាមរយៈរឿងទាំងនោះ អ្នកនិពន្ធជារឿយៗបានឆ្លុះបញ្ចាំងពីភាពឆ្លាតវៀងវៃក្នុងផ្នត់គំនិតមនុស្ស នាយុគសម័យនោះគឺភាពឆ្លាតវៀងវៃដែលរៀបរាប់ថា ជាប្រភេទមួយទៀតនៃការពិត។ ជាឧទាហរណ៍រឿងស្តេចអូឌីប៉ុស (Oedipus the king) ដែលសរសេរដោយអ្នកនិពន្ធកំណាព្យ ជនជាតិក្រិច សូផូកូល Sophoscoles កាលពីជាង ២៤០០ ឆ្នាំមុន គឺពុំមែនជាការពិតឡើយនៅក្នុងន័យអក្សរសាស្ត្រ។ ទោះបីជាយ៉ាងណាក៏ដោយរឿងនេះមានបង្កប់នូវអត្ថន័យស៊ីជម្រៅ

លើ «ការពិតជាច្រើន» អំពីសារជាតិនៃទំនាក់ទំនងរបស់មនុស្សនៃមោទនភាព ភាពលោភលន់ និងសោកនាដកម្ម។ ការយល់ឃើញទាំងនេះ គឺជាហេតុផលមួយក្នុងហេតុផលទាំងឡាយ ដែលធ្វើឲ្យរឿងនេះរស់រានមានជីវិតបន្តមកទល់សព្វថ្ងៃនេះ ហើយរឿងនេះនៅតែយកមកសម្តែងលើឆាក និងបញ្ចាំងតាមកញ្ចក់ទូរទស្សន៍ជានិច្ចកាល។ យើងអាចរៀនអំពីការពិតសំខាន់ៗ ដោយសិក្សាអំពីការពិតនោះ ទោះបីជាវាផ្អែកទៅលើព្រឹត្តិការណ៍ដែលប្រឌិតឡើងទាំងស្រុងក៏ដោយ។

«ការពិត» ផ្នែកនយោបាយ ក៏ជាបញ្ហាមួយទៀតដែរ។ ឧទាហរណ៍ នៅសហរដ្ឋអាមេរិក ឯកសារមួយក្នុងចំណោមឯកសារសំខាន់បំផុតនៃលទ្ធិប្រជាធិប-តេយ្យ អាមេរិកចាប់ផ្តើមដោយប្រើឃ្លាថា «យើងទុកឲ្យការពិតទាំងនេះបង្ហាញភស្តុតាងដោយខ្លួនឯងផ្ទាល់ថា មនុស្សទាំងអស់កើតមកស្មើៗគ្នា...» «ការពិតផ្នែកនយោបាយ» នេះគឺជាគោលការណ៍គ្រឹះនៃការរៀបចំមួយក្នុងចំណោមគោលការណ៍ដទៃទៀត សម្រាប់រៀបចំរដ្ឋាភិបាល និងនយោបាយនៅក្នុងសហរដ្ឋអាមេរិក។ ចំណែកឯនៅក្នុងប្រទេសកម្ពុជាវិញ មតិជាច្រើនចាត់ទុកគោលការណ៍ «ព្រះមហាក្សត្រ គឺជាព្រះបិតាជាតិ ហើយជាព្រះបិតាការពារសាសនា» ថាជា «ការពិត»។ ការពិតនេះត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងបាវចនាជាតិក្នុងមាត្រា៤នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា «ជាតិ សាសនា ព្រះមហាក្សត្រ» ហេតុដូច្នេះនេះគឺជាគោលការណ៍គ្រឹះនៃការរៀបចំរដ្ឋាភិបាល និង នយោបាយនៅក្នុងប្រទេសកម្ពុជា ទោះបើជាញឹកញាប់លក្ខណៈជាក់លាក់នៃការប្រព្រឹត្តទៅនៃគោលការណ៍នេះ អាចមានការលំបាកនឹងយល់បានក៏ដោយ ហើយជួនកាលក៏មានការលំបាកប្រហាក់ប្រហែលគ្នានេះដែរ ក្នុងការមើលឲ្យឃើញថាតើគោលការណ៍ «មនុស្សទាំងអស់កើតមកស្មើៗគ្នាជាមនុស្ស» តែងតែយកមកអនុវត្តតាមរបៀបណានៅក្នុងសហរដ្ឋអាមេរិក»។ លោក ហិនរី អាដាម Henry Adam ដែលជាអ្នកនិពន្ធសញ្ជាតិអាមេរិកដ៏ឆ្នើមម្នាក់ត្រូវបានមនុស្សជាច្រើនលើកយកមកនិយាយយ៉ាងល្បីខ្ទរខ្ទារថា មានពេលមួយនោះគាត់បានសរសេរថា «គាត់ពុំខ្វល់ថាតើការពិត ឬមិនពិតនោះទេ»។ សម្តីរបស់គាត់ប្រហែលជាជួយឲ្យយើងអាចបែកឲ្យបានដាច់រវាងការពិតផ្នែកនយោបាយ និងប្រភេទនៃការពិតផ្សេងទៀត។

មិត្តភក្តិរបស់ខ្ញុំម្នាក់ បានប្រាប់ខ្ញុំកាលពីពេលថ្មីៗនេះនូវរឿងកំប្លែងមួយ។ រឿងកំប្លែងនោះ មានដូចតទៅនេះ៖ ពាណិជ្ជករម្នាក់កំពុងស្វែងរកជួលគណនេយ្យករម្នាក់ឲ្យមកធ្វើការនៅក្រុមហ៊ុនរបស់គាត់។ បេក្ខជនបីនាក់បង្ហាញខ្លួនដើម្បីចូលសម្ភាសន៍។ ពាណិជ្ជករនោះហៅបេក្ខជនទី១ ឲ្យចូលមកក្នុងការិយាល័យរបស់គាត់ហើយគាត់សួរបេក្ខជនទី១ថា «២បូកនឹង២ស្មើប៉ុន្មាន?» បេក្ខជននោះឆ្លើយថាស្មើនឹង៤។ ពាណិជ្ជករនោះថ្លែងអំណរគុណដល់បេក្ខជនទី១ ហើយចង្អុលបង្ហាញទ្វារចេញ។ នៅពេលដែលបេក្ខជនទី២ ចូលមកសម្ភាសន៍ពាណិជ្ជករបានសួរម្តងទៀតថា «តើ២បូកនឹង២ស្មើប៉ុន្មាន?» បេក្ខជនទី២ ក៏បានឆ្លើយដែរថាស្មើនឹង៤។ បេក្ខជននេះក៏ត្រូវបានសុំឲ្យចេញទៅក្រៅបន្ទប់ដូចបេក្ខជនទី១ដែរ។ បន្ទាប់មកទៀត បេក្ខជនទី៣ក៏ចូលមកក្នុងបន្ទប់ការិយាល័យរបស់ពាណិជ្ជករ ហើយគាត់ត្រូវបានសួរសំណួរដដែលថាតើ «២បូកនឹង២ ស្មើប៉ុន្មាន?» បេក្ខជនទី៣បានងើបពីកៅអី ហើយក្រោកឈរឡើងចាក់សោរទ្វារបន្ទប់ការិយាល័យ បិទវាំងននរួចហើយខ្សឹប ដាក់ត្រចៀកពាណិជ្ជករនោះថា «តើលោកឯងចង់ឲ្យ២បូកនឹង២ស្មើប៉ុន្មាន?» នៅពេលនោះស្រាប់តែបេក្ខជនទី៣ ត្រូវបានជ្រើសរើសឲ្យធ្វើការភ្លាមៗ។ រឿងបែបនេះទោះបីជារឿងកំប្លែង ប៉ុន្តែធ្លាប់កើតឡើងពិតចំពោះមនុស្សមួយចំនួននៅក្នុងប្រទេសជាច្រើន។ បន្ទាប់មកសួរថាតើធ្វើយ៉ាងដូចម្តេចទើបយើងអាចរកឃើញការពិតអំពីនយោបាយ? នៅពេលដែលមានកំហឹងនឹងអ្នកនយោបាយ ឬ មិនជឿថាអ្វីដែលអ្នកនយោបាយនិយាយថាជាការពិតនោះមានមតិមហាជនកម្ពុជាខ្លះយល់ច្រឡំថា «នយោបាយ» គឺ «នយោបោក» ឬ «ការបោកប្រាស់»។ មតិនេះបានក្លាយទៅជាវប្បធម៌មួយដែលចាត់ទុកនយោបាយជាពាក្យផ្ទុយទៅនឹង

អ្វីដែលពិតតាមការបកស្រាយផ្សេងៗ។ ក៏ប៉ុន្តែធាតុពិតនៃពាក្យ «នយោបាយ» ពុំដូច្នោះទេ យើងអាចរកឃើញការពិតអំពីនយោបាយបានដោយអនុវត្តមធ្យោបាយ វិទ្យាសាស្ត្រជាច្រើនៗ នេះគឺជាមុខវិជ្ជាសិក្សាមួយ ដែលនៅក្នុងបណ្តាបស្ចិមប្រទេស ហៅថា «វិទ្យាសាស្ត្រនយោបាយ Politicial Science» ដែលជាមុខវិជ្ជាមួយដែលគួរឲ្យចង់ដឹងហើយដែលពុំត្រូវបានបង្រៀននៅតាមសាលា នៅប្រទេសកម្ពុជានៅឡើយ។ ប៉ុន្តែមុខវិជ្ជានេះគួរតែយកមកបង្រៀនពីព្រោះតាមមធ្យោបាយនេះ យើងអាចយល់បានកាន់តែប្រសើរនូវការពិតនានា ដែលបង្កប់ពីក្រោយពាក្យ «នយោបាយ» និងគោលដៅរបស់អ្នកនយោបាយនានា។ ជាឧទាហរណ៍មួយដែលអាចយកមកពិចារណាតាមវិទ្យាសាស្ត្រនយោបាយគឺថា ពាណិជ្ជករម្នាក់ត្រូវបានរដ្ឋាភិបាលប្រគល់កិច្ចសន្យាដ៏ធំមួយឲ្យប្រតិបត្តិការងារសាធារណៈ ដូចជាសាងសង់ផ្លូវថ្មីមួយ។ យើងអាចសួរសំណួរថាតើកិច្ចសន្យានោះត្រូវបានផ្តល់ឲ្យទៅពាណិជ្ជករនោះតាមរបៀបណា? តើពាណិជ្ជករនោះសូកសំណូកឬ «ប្រាក់វត់ការ» ឬដែលហៅថា «ទឹកតែ» ទៅឲ្យឥស្សរជននយោបាយដែលចំណារផ្តល់កិច្ចសន្យានោះដែរឬទេ? ថាតើអ្នកតាក់តែងច្បាប់ដែលបានបោះឆ្នោតគាំទ្រការប្រគល់កិច្ចសន្យានោះទទួលគុណបំណាច់អ្វីខ្លះពីពាណិជ្ជករដែរឬទេ? ថាតើអ្នកនយោបាយសម្រេចដូច្នេះ ដោយសារខ្លួនមានដីចម្ការដែលនៅតាមដងផ្លូវថ្មីនេះដែរឬទេ? តើមានភស្តុតាងអ្វីខ្លះដើម្បីបង្ហាញថាផ្លូវថ្មីនេះពិតជាផ្តល់ផលប្រយោជន៍ដល់តំបន់ទាំងនោះ ដែលអ្នកនយោបាយបានលើកឡើងក្នុងការទាញហេតុផលដើម្បីគាំទ្រការផ្តល់កិច្ចសន្យានោះ? តើអ្នកទទួលផលប្រយោជន៍ដ៏ធំពីកិច្ចសន្យានេះតាមពិតគឺជានរណា? តើអាចមានក្រុមហ៊ុនដទៃទៀតដែលអាចសង់ផ្លូវមានគុណភាពល្អជាង ហើយចំណាយតិចជាងដែរឬទេ? តើការសម្រេចចិត្តនោះធ្វើឡើងដើម្បីផលប្រយោជន៍សាធារណៈ សុទ្ធសាធ ឬក៏ដើម្បីផលប្រយោជន៍ឯកជនដែរឬយ៉ាងណា? តើមានឯកសារឬកំណត់ហេតុនៃការចរចាគ្នាដែលអាចជួយជាពន្លឺមកលើសំណួរណាមួយ ក្នុងចំណោមសំណួរទាំងនេះដែរឬទេ? តាមរបៀបនេះ យើងអាចចាប់ផ្តើមស្រាយសំបុកផលប្រយោជន៍ដែលជំពាក់ជំពិននៅពីក្រោយការសម្រេចចិត្តបែបនេះ ហើយចាប់ផ្តើមយល់ពី «ការពិត» នៃនយោបាយ។

ជាគោលដៅសំខាន់បំផុត ការពិតប្រភេទនេះហើយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាព្យាយាមរកឲ្យបាន។ បាវចនារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺ «ស្វែងរកការពិត»។ ប្រភេទនៃការពិតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកការពិតគឺជាអ្វីដែលជនជាតិក្រិចនាសម័យបុរាណ ហៅថា «Noesis» ដែលជាប្រភេទនៃការពិត ដែលអ្នកវិទ្យា-សាស្ត្រស្វែងរកដោយប្រើប្រាស់តក្កភាពនៃការរុករកតាមបែបវិទ្យាសាស្ត្រដែលពិពណ៌នាដោយទស្សនវិទូ កាល ប៉ុបព័រ។ មជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកការពិតអំពីនយោបាយនៃរបបខ្មែរក្រហម ឬច្បាស់ជាងនេះអំពីការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យ តើប្រជាជនកម្ពុជាជាច្រើនស្លាប់យ៉ាងដូចម្តេច? តើប្រជាជនទាំងនោះស្លាប់ដោយសារអ្វី? តើប៉ុន្មាននាក់ស្លាប់ដោយអត់អាហារ? តើប៉ុន្មាននាក់ស្លាប់ដោយសារជំងឺ? ប៉ុន្មាននាក់ត្រូវស្លាប់ដោយសារការប្រហារជីវិត? តើការប្រហារជីវិតទាំងនោះត្រូវបានរៀបចំ និងអនុវត្តឡើងយ៉ាងដូចម្តេច? តើនរណាជាអ្នកបញ្ជា? នៅពេលណា? នៅទីកន្លែងណា? ហើយថាតើបទបញ្ជាទាំងនោះបញ្ជូនពីថ្នាក់លើមកកម្មាភិបាលថ្នាក់ក្រោមដែលជាអ្នកអនុវត្តបទបញ្ជាយ៉ាងដូចម្តេច? តើអ្វីជាអង្គការ? នរណាជាអ្នកបញ្ជាកងកម្លាំងសន្តិសុខនៃរបបខ្មែរក្រហម? តើការសម្លាប់រង្គាលត្រូវអនុវត្តនៅទីណាខ្លះក្នុងប្រទេសកម្ពុជា? នរណាជាជនរងគ្រោះ ហើយនរណាជាឃាតករ? ទាំងនេះគឺជាចង្កោមសំណួរដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងស្វែងរកចម្លើយ។

មជ្ឈមណ្ឌលឯកសារកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើមធ្យោបាយវិទ្យាសាស្ត្រ។ អ្នកវិទ្យាសាស្ត្រនយោបាយ និងអ្នកប្រាជ្ញវិទ្យាសាស្ត្រសង្គមជាច្រើនមកពីទ្វីបអឺរ៉ុប អូស្ត្រាលី និងសហរដ្ឋអាមេរិក

ដែលបានផ្ដល់ដំបូន្មានជាប្រចាំដល់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពីរបៀបរៀបចំការស្វែងរកការពិត នៅក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់បច្ចេកទេសវិទ្យាសាស្ត្រទំនើប និងមានលក្ខណៈស្មុគស្មាញបែបនេះ។ មធ្យោបាយទាំងនេះរួមមានឧបករណ៍ដូចជាប្រើប្រាស់ប្រព័ន្ធផ្កាយរណបនៅក្នុងលំហអាកាសដើម្បីជួយបង្កើតទិន្នន័យដែនទីរណ្ដៅសាកសព ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដទៃទៀតដើម្បីថែរក្សា តម្កល់ទុក និងផលិតឡើងវិញនូវទិន្នន័យដើមជាច្រើនសណ្ឋាន តាមរយៈទិន្នន័យឯកសារខ្មែរក្រហមដែលប្រមូលបាននៅក្នុងដំណើរការស្រាវជ្រាវនេះ។ សំខាន់បំផុតនោះគឺការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាពឹងផ្អែកទៅលើការរកឃើញឯកសារការិយាធិបតេយ្យ ដែលចងក្រងដោយយន្តការសម្លាប់របស់ខ្មែរក្រហម។ ឯកសារទាំងនោះរួមមានដូចជា អនុសារណៈ កំណត់ហេតុ បទបញ្ជា បញ្ជីសម្លាប់ កំណត់ហេតុអង្គប្រជុំ ជាដើម។ល។

ឯកសារទាំងនេះពិពណ៌នាអំពីរបៀបដែលការប្រល័យពូជសាសន៍នៅកម្ពុជា ត្រូវបានរៀបចំឡើង ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា បានរកឃើញឯកសាររាប់រយពាន់សន្លឹក ដែលជាឯកសារបែបនេះ។ ការបើកទូលាយ និងការវិភាគព័ត៌មាននៅក្នុងឯកសារទាំងនេះ នឹងប្រាប់រឿងរ៉ាវនៃការប្រល័យពូជសាសន៍នៅកម្ពុជាបានយ៉ាងទូលំទូលាយ ជាពិសេសរឿងរ៉ាវពីជនរងគ្រោះ និងជនដៃដល់នៃអំពើប្រល័យពូជសាសន៍។ ទាំងនេះគឺជាសាច់រឿងប្រវត្តិសាស្ត្រ ដែលប្រជាជនកម្ពុជានាពេលបច្ចុប្បន្ន និងពេលអនាគតមានសិទ្ធិត្រូវដឹង។

ការស្វែងរកការពិតអំពីសំណួរទាំងនេះ គឺជាបេសកកម្មដ៏សំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដូចដែលខ្ញុំបានបញ្ជាក់ខាងលើរួចមកហើយថា ការរកឃើញការពិត និងបានដឹងការពិតពុំមែនជាភារកិច្ចដ៏សាមញ្ញមួយនោះទេ។ ប៉ុន្តែពុំទាន់ហួសពេលនៅឡើយទេសម្រាប់ប្រទេសកម្ពុជា លទ្ធភាពរកការពិតចំពោះបញ្ហានេះនៅតែមាន ហើយសម្រាប់ប្រទេសកម្ពុជាការពិតនេះគឺមានសារសំខាន់មិនអាចវាស់ស្មានបានឡើយ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបន្តបូជាកិច្ចខិតខំប្រឹងប្រែងចំពោះភារកិច្ចស្វែងរកការពិតអំពីអ្វីដែលបានកើតឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយមានការប្ដេជ្ញាចិត្តធ្វើឲ្យបានជោគជ័យនូវភារកិច្ចនេះ។



អដ្ឋិធាតុរបស់ជនរងគ្រោះពីរបបខ្មែរក្រហម នៅខាងក្រោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (Raffy Lerma/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជូ ជុនហ៊ាន ប្រជាជនថ្មី

*សុខ ចាន់ណា*



ការដ្ឋានលើកទំនប់ដីកប្រឡាយក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជូ ជុនហ៊ាន អាយុ៣៣ឆ្នាំ (នៅឆ្នាំ១៩៧៧) ភេទប្រុស មានស្រុកកំណើតនៅភូមិចំណោម ឃុំកំពែង ស្រុកព្រែកប្បាស តំបន់៣៣ (ភូមិភាគនិរតី)។ ខ្ញុំគឺជាអតីតគ្រូបង្រៀននៅសាលាបឋមសិក្សាចំណោម។

នៅឆ្នាំ១៩៦០ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាចំណោម បន្ទាប់មករៀននៅសាលាអនុវិទ្យាល័យព្រៃល្វា។ នៅឆ្នាំ១៩៦៦ ខ្ញុំរៀនដល់ថ្នាក់ទី២ នៅវិទ្យាល័យតាកែវ។

នៅឆ្នាំ១៩៦៧ ខ្ញុំប្រឡងជាប់ធ្វើជាគ្រូបង្រៀន និងរៀនច្បាប់គ្រូនៅមហាវិទ្យាល័យកំពង់កន្ទួត។ រយៈពេលនោះខ្ញុំបានស្នាក់នៅ និងជិតស្និទ្ធជាមួយឈ្មោះ អ៊ូ សន ដែលជាគ្រូបង្រៀនទីនោះដែរ។ នៅឆ្នាំ១៩៦៨ ខ្ញុំបានទទួលការអប់រំពីឈ្មោះ សន អំពីរបបលោកសេរី គឺប្រជាជនរស់នៅសប្បាយដូចប្រទេសអាមេរិក រីឯរបបកុម្មុយនីសជារបបរឹតត្បិតលើសេរីភាពប្រជាជន ដែលលំបាកដូចប្រទេសចិន។ ក្រោយពីទទួលការអប់រំហើយ ខ្ញុំបានចូលជា សេ.អ៊ី.អា

ដោយមានអ្នកខ្ទេសនាមបញ្ចូលឈ្មោះ ញាន ធូរ៉ាន និងទទួលស្គាល់ដោយឈ្មោះ វង់ សារ៉េត។ ទាំងពីរនាក់នេះគឺជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យកំពង់កន្ទួត។ សន ក៏ណែនាំឲ្យខ្ញុំទាក់ទងជាមួយឈ្មោះ ចិល ខេង (អតីតគ្រូបង្រៀន), ស សឿង (អតីតគ្រូបង្រៀន), សុក ហន (អតីតគ្រូបង្រៀន) ដើម្បីរួមធ្វើសកម្មភាពតាមដានចលនាខ្មែរក្រហម នៅសាលាផ្សេងៗទៀត និងកសាងកម្លាំង សេ.អុី.អា។

នៅឆ្នាំ១៩៦៩ ពេលខ្ញុំរៀនច្បាប់គ្រូចប់ហើយ ក៏មកបង្រៀននៅសាលាបឋមសិក្សាចំណោម។ ពេលនោះ សនបានឲ្យខ្ញុំធ្វើការទាក់ទងធ្វើសកម្មភាពតាមដានខ្មែរក្រហមជាមួយឈ្មោះ មិញ ឈីវ (អតីតគ្រូបង្រៀន), សួងស្រេង (ប្រជាជនថ្មីនៅសហករណ៍ដកពោ), យិន លាងឆាយ (អតីតគ្រូបង្រៀន)។ ក្រោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំ, សួង ស្រេង, យិន លាងឆាយ និង ឈីវ បានរត់មកនៅភ្នំពេញ។ ខ្ញុំបានភ្ជាប់ខ្សែ សេ.អុី.អា ចាស់ជាមួយ អ៊ូ សនជាមេរបស់ខ្ញុំដដែល។ សននិងមិញ ឈីវបាននាំខ្ញុំទៅ ទាក់ទងខ្សែ សេ.អុី.អា ដែលរត់ពីជនបទមកនៅភ្នំពេញដែរ ដែលអ្នកទាំងនោះមានឈ្មោះ អឹម សាយ, កែវ សេថា, ហង់ អឿង ដើម្បីរួមធ្វើសកម្មភាពតាមដានខ្មែរក្រហម នៅក្នុងចំណោមសិស្សនៅសាលាបឋមសិក្សាទួលស្វាយព្រៃ។ ជាមួយគ្នានេះ ខ្ញុំបានធ្វើសកម្មភាពចាប់ខ្មែរក្រហមបានម្នាក់ឈ្មោះ ជា។ នៅក្នុងឆ្នាំ១៩៧០ ដដែល អ៊ូ សន និង មិញ ឈីវ នាំខ្ញុំទៅ ទាក់ទងខ្សែ សេ.អុី.អា ម្នាក់ឈ្មោះ ប៉ែន សូត្រ អតីត (ទាហានចាស់) ពាក់ស័ក្តិ២ ដើម្បីឲ្យស្គាល់ ទាក់ទងភ្ជាប់ខ្សែ សេ.អុី.អា ក្នុងក្រុងភ្នំពេញ។ បន្ទាប់មក សាវិនបាននាំខ្ញុំឲ្យស្គាល់ ឌុច សំ (អតីតគ្រូបង្រៀន) និងធីវ៉ិត (អតីតគ្រូបង្រៀន) ដែលជាខ្សែ សេ.អុ.អា ដែរ។ ក្រោយពីទាក់ទងហើយ ខ្ញុំបានចូលរួមធ្វើសកម្មភាពជាមួយ សំ និង វ៉ិត ឃោសនាប្រជាជនឲ្យស្អប់ខ្មែរក្រហម និងចាប់ខ្មែរក្រហម។

នៅឆ្នាំ១៩៧២ ខ្ញុំបានទទួលការចាត់តាំងពី ប៉ែន សូត្រឲ្យទាក់ទងខ្សែ សេ.អុី.អា នៅសាលាបឋមសិក្សាបឹងត្របែកឈ្មោះ ឡាច សារុន។ បន្ទាប់មក ខ្ញុំបានទៅ ទាក់ទងជាមួយ ឡាច សាវិន ធ្វើសកម្មភាពចាប់ខ្មែរក្រហមបានម្នាក់ឈ្មោះ គឹម នៅបឹងត្របែក។ ឆ្នាំ១៩៧៣ ប៉ែន សូត្រ បានចាត់តាំងខ្សែ សេ.អុី.អា ទាំងអស់ឲ្យធ្វើជាមេ ១០ខ្នងទៅ៥០ខ្នង នៅក្នុងសង្កាត់លេខ១១ ដើម្បីឲ្យខ្សែ សេ.អុី.អា ទាំងអស់ស្រួលធ្វើសកម្មភាពតាមដានខ្មែរក្រហម។ ក្រោយទទួលការចាត់តាំង និងទទួលផែនការហើយ ខ្ញុំបានមកធ្វើមេ១០ខ្នងនៅសង្កាត់លេខ១១ ក្រុងភ្នំពេញ។ ខ្ញុំបានឃោសនាឲ្យប្រជាជនស្អប់ខ្មែរក្រហម និងចាប់ខ្មែរក្រហមបានពីរនាក់ឈ្មោះតូច និង ជុន ផាន នៅក្នុងសង្កាត់លេខ១១ ហើយកសាងកម្លាំង សេ.អុី.អា បាន៤នាក់មានឈ្មោះ ព្រំឆែម (អតីតពេទ្យទាហាន), សួស ឈន (ប្រជាជនថ្មីនៅសហករណ៍ប៉ោយព្រីង), វ៉ិត ទឹម (ប្រជាជនថ្មីសហករណ៍ដកពោ), ទី សាគុណ (ប្រជាជនថ្មីសហករណ៍គីរីវ៉ន)។ ពេលកសាងកម្លាំងទាំងនេះបានហើយ ប៉ែន សូត្រ បានណែនាំខ្ញុំឲ្យស្គាល់ និងទាក់ទងជាមួយខ្សែ សេ.អុី.អា ម្នាក់ទៀតមានឈ្មោះជិនកៃ (អតីតអធិការបឋមសិក្សាក្រុងតាកែវ)។

នៅខែមេសា ឆ្នាំ១៩៧៥ ក្រោយពីដឹងសភាពការណ៍កងទ័ពខ្មែរក្រហមវាយរំដោះជុំវិញភ្នំពេញហើយ ក្នុងអំឡុងពេលនោះខ្ញុំទទួលផែនការពី ប៉ែន សូត្រ ឲ្យខិតខំកសាងកម្លាំង សេ.អុី.អា បន្ថែម និងចាត់តាំងកម្លាំង សេ.អុី.អាឲ្យទៅលាក់ខ្លួនតាមផ្ទាំងថ្មចាំបាញ់ឃោធាខ្មែរក្រហមពេលចូលមកក្រុងភ្នំពេញ និងឲ្យលាក់អាវុធខ្លី គ្រាប់បែកទុកសម្រាប់ខ្មែរក្រហម។ មុនជម្លៀសមួយថ្ងៃ ខ្ញុំបានទទួលផែនការពី ប៉ែន សូត្រ ឲ្យកសាងកម្លាំង សេ.អុី.អា ក្នុងចំណោមប្រជាជនថ្មី និងបន្តធ្វើការទាក់ទងខ្សែ សេ.អុី.អា ឲ្យជាប់។ ថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ អង្គការបានជម្លៀសខ្ញុំចេញពីភ្នំពេញ ហើយក្នុងអំឡុងពេលនោះ ខ្ញុំក៏បានទៅភ្ជាប់ខ្សែ សេ.អុី.អា ចាស់ដែលមកជាមួយមានឈ្មោះ ស៊ួស ឈន និង ទី គុណ។ ខ្ញុំបានទៅនៅភូមិចំណោម ឃុំកំពែង ជាស្រុកកំណើតរបស់ខ្ញុំ។ ខ្ញុំក៏បានទៅភ្ជាប់ខ្សែ សេ.អុី.អា ចាស់ផ្សេង

ទៀតមានឈ្មោះ ស្នួង ស្រេង, ហង់ អឿង និង កែវ សេថា ក្រៅពីឈ្មោះទាំងបីនាក់ខាងលើនេះ ខ្ញុំដាច់ការទាក់ទងទាំងអស់។ ក្នុងពេលភ្ជាប់ទំនាក់ទំនងឡើងវិញនេះ អឿង គឺជាអ្នកដឹកនាំកម្លាំង សេ.អ៊ី.អា ហើយខ្ញុំគឺជាអ្នកទទួលផែនការពី អឿង ឲ្យកសាងកម្លាំង សេ.អ៊ី.អា ក្នុងចំណោមប្រជាជនថ្មី ឲ្យបំភ្លៃមាគ៌ាបង្កបង្កើនផលរបស់អង្គការ ឃោសនាឲ្យប្រជាជនថ្មីស្អប់អង្គការ និងស្រាវជ្រាវរកខ្សែ សេ.អ៊ី.អា។ នៅខែឧសភា ឆ្នាំ១៩៧៥ ខ្ញុំនិង ហង់ អឿង បានធ្វើសកម្មភាពកសាងកម្លាំង សេ.អ៊ី.អា ក្នុងចំណោមប្រជាជនចាស់បានពីរនាក់គឺឈ្មោះ ហេង និង តាំង ឆេង។ ពេលកសាងបានហើយ អង្គការបានចាត់តាំងខ្ញុំ និង ហង់ អឿងឲ្យទៅលើកទំនប់ទឹកនៅកំពង់ចក ក្នុងឃុំព្រៃល្វា ស្រុក៤៥ ។ អំឡុងពេលនោះខ្ញុំ និង ហង់ អឿង បានស្រាវជ្រាវរកឃើញខ្សែ សេ.អ៊ី.អា ចាស់ម្នាក់គឺ មិញ ឈីវ។ ខ្ញុំ និង អឿង បានទទួលផែនការពី ឈីវ ឲ្យកសាងកម្លាំង សេ.អ៊ី.អា បំផុសឲ្យប្រជាជនថ្មីស្អប់អង្គការ និងធ្វើឲ្យមានការច្របូកច្របល់។

នៅខែកក្កដា និងខែសីហា ឆ្នាំ១៩៧៥ ខ្ញុំនិង អឿង រួមជាមួយ តាំ អៃ និង ស៊ូ ក្រវ៉ាន់ បានបំផុសប្រជាជនថ្មីឲ្យមានការច្របូកច្របល់ក្នុងភូមិចំណោម ដោយបានបំផុសថាអង្គការនៅក្នុងភូមិនេះតឹងរ៉ឹងណាស់ ហើយបង្ខំឲ្យធ្វើការច្រើន, ស៊ីមិនដែលឆ្អែតទេ ប៉ុន្តែបើភូមិដទៃក្រៅពីភូមិចំណោមនេះធ្វើការងារតិច ហើយស៊ីបានឆ្អែតទៀតផង។ ក្នុងពេលនោះដែរ ខ្ញុំបានទទួលផែនការពី អឿង ធ្វើឲ្យរាំងស្ទះក្នុងការកសាងប្រទេសរបស់អង្គការ ដោយពេលស្ទូងបានបំផ្លាញសំណាប និងកសាងកម្លាំង សេ.អ៊ី.អា។ ក្រោយពេលទទួលផែនការហើយ ខ្ញុំ និង ហេងបានបំផ្លាញសំណាបអស់៦០កណ្តាប់ និងនង្គ័លអស់៥។ នៅខែកញ្ញា និងខែតុលា ឆ្នាំ១៩៧៥ ខ្ញុំរួមធ្វើសកម្មភាពជាមួយ ហេង និង ហង់ អឿង កសាងកម្លាំង សេ.អ៊ី.អា បានពីរនាក់ គឺ មុំ ស៊ិន និង ទូច មុិល។ ពេលកសាងកម្លាំងបានហើយ អង្គការក៏បានចាត់តាំងខ្ញុំ និង មុំ ស៊ិន ព្រមទាំង ហេង ឲ្យទៅដាំដំឡូង។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ អង្គការជម្លៀសខ្ញុំពីភូមិចំណោមឲ្យទៅនៅខេត្តបាត់ដំបងវិញ។ នៅពេលនោះខ្សែ សេ.អ៊ី.អា របស់ខ្ញុំ ក៏ត្រូវបានអង្គការជម្លៀសមកខេត្តបាត់ដំបងដែរ ដូច្នេះហើយខ្ញុំនៅជាប់ខ្សែដដែល។ ខ្ញុំបានទៅនៅក្នុងសហករណ៍គោកលុន ឃុំទានកាំ ស្រុកព្រះនេត្រព្រះ តំបន់៥។ ខ្ញុំបានជាប់ខ្សែ សេ.អ៊ី.អា ចាស់ឈ្មោះ ជិន កៃ ហើយ កៃ បាននាំខ្ញុំឲ្យស្គាល់ និងធ្វើសកម្មភាពជាមួយឈ្មោះ សុក សាមិត, នូ យុន។ ជាមួយគ្នានេះដែរ ខ្ញុំបានទទួលផែនការពី ជិន កៃ ឲ្យស៊ើបរកខ្សែ សេ.អ៊ី.អា ចាស់ ដើម្បីទាក់ទងធ្វើសកម្មភាពបំផ្លាញក្នុងសហករណ៍ តាមរយៈភារកិច្ចអង្គការឲ្យធ្វើដោយបំផុសប្រជាជនថ្មីឲ្យប្រឆាំងរបបសមូហភាពរបស់អង្គការ និងកសាងកម្លាំង សេ.អ៊ី.អា។

នៅខែមករា ឆ្នាំ១៩៧៦ ពេលទទួលផែនការហើយ ជិន កៃ បានចាត់តាំងខ្ញុំ ឲ្យធ្វើសកម្មភាពជាមួយខ្សែ សេ.អ៊ី.អា ចាស់មានឈ្មោះ សាមិត និង នូ យុន។ យើងកសាងកម្លាំង សេ.អ៊ី.អា បានបីនាក់ គឺ សុទ្ធ, ណៃក, គីឈៀង លី ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ប្រធានសហករណ៍គោកលុនបានចាត់តាំងខ្ញុំឲ្យទៅលើកទំនប់ទឹកនៅវាលដំបូកបី ក្នុងឃុំទានកាំ។ អំឡុងពេលនោះ ខ្ញុំបានទាក់ទងជាប់ជាមួយ ហង់ អឿង ដែលមកលើកទំនប់ដែរ។ នៅខែមិថុនា ឆ្នាំ១៩៧៦ ខ្ញុំបានមកនៅក្នុងសហករណ៍គោកលុនវិញ ហើយបានទទួលផែនការពី ឡេង និង ជិន កៃ ម្តងទៀតឲ្យលួចស្រូវក្នុងសហករណ៍លាក់ទុកត្រៀមសម្រាប់បម្រើផែនការរដ្ឋប្រហារវាយយកខេត្តបាត់ដំបង ឲ្យពង្រីងការទាក់ទងខ្សែ សេ.អ៊ី.អា នៅខាងមូលដ្ឋានចាស់ បំផុសប្រជាជនថ្មីឲ្យរត់ចូលសៀម និងបំផុសឲ្យមានការច្របូកច្របល់ក្នុងសហករណ៍។ ក្រោយពេលទទួលផែនការហើយ ឡេង បាននាំខ្ញុំទៅជួប ឆោម អនុប្រធានសហករណ៍គោកលុន ដើម្បីទាក់ទងធ្វើសកម្មភាព ហើយជាមួយគ្នានេះ ខ្ញុំ និង ឆោម ក៏បានបំផុសប្រជាជនថ្មីឲ្យរត់ទៅសៀមបានពីរនាក់។ នៅខែកក្កដា និង ខែសីហា ឆ្នាំ១៩៧៦ ឆោម បាននាំខ្ញុំឲ្យ

ស្គាល់ និង ទាក់ទងឈ្មោះ ស ប្រធានឃុំទានកាំ ។ បន្ទាប់មក ខ្ញុំបានទាក់ទងឈ្មោះ ស៊ុំ និង ធី ទៀត។ នៅពេលទាក់ទងហើយ ខ្ញុំបានធ្វើសកម្មភាពរួមជាមួយអ្នកទាំងពីរដោយបំផុសប្រជាជនថ្មីឲ្យរត់ចូលសៀមអស់៧គ្រួសារ ដោយបំផុសថានៅក្នុងសហករណ៍នេះលែងចាយលុយ បើលក់ដូរអ្វីក៏មិនបានមិនដូចទៅប្រទេសសៀមទេ ប្រជាជនអាចរកស៊ីលក់ដូរអ្វីបានតាមចិត្ត។ ក្រៅពីនេះ ខ្ញុំបានទាក់ទងជាមួយ វ៉ាន និង អឿង ធ្វើសកម្មភាពបង្ហូរទឹកឲ្យលិចសន្ទូងទើបនឹងស្ទូងអស់ចំនួនពីរហិកតា។

នៅខែមករា និងខែមីនា ឆ្នាំ១៩៧៧ ខ្ញុំបានទទួលផែនការពី ឡេង ម្តងទៀតឲ្យកសាងកម្លាំង សេ.អ៊ី.អា បន្ថែមដើម្បីទុកបម្រើផែនការ និងឲ្យលួចស្រូវអង្គការក្នុងសហករណ៍ដើម្បីត្រៀមទុក។ ពេលទទួលផែនការហើយខ្ញុំកសាងកម្លាំង សេ.អ៊ី.អា បានពីរនាក់ទៀតគឺចក់ និង ញឹម មុន។ ក្រៅពីនេះ ឆោម ឲ្យខ្ញុំទៅ ទាក់ទងជាមួយ វ៉ាន, ញយ និង អឿង ដើម្បីរៀបចំកម្លាំង។ មកដល់ខែកក្កដា ឆ្នាំ១៩៧៧ អង្គការចាប់ខ្សែរបស់ខ្ញុំមានឈ្មោះ ម៉ោង, សំអាត, ស, ឡេង ដូច្នេះខ្ញុំក៏បានទាក់ទងទៅឈ្មោះ ម៉ា និង ខុ ដើម្បីរៀបចំរកផ្លូវរត់ទៅសៀម។ ខ្ញុំក៏បានដើរទាក់ទងបបួលខ្សែក្បត់នៅតាមសហករណ៍គោកលុន សហករណ៍គិរីវិន ដែលមានឈ្មោះ ឈៀង លី, អ៊ូ ផល, ហង់ អឿង និង ទី សាគុណ បម្រុងរត់ចូលសៀម។ ខ្ញុំនៅក្នុងសហករណ៍គោកលុនរហូតដល់ខែសីហា ឆ្នាំ១៩៧៧ ទើបអង្គការចាប់ខ្លួនខ្ញុំ។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ០០៦៩៨។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ជូ ជុនហ៊ាន ពិតឬយ៉ាងណានោះទេ?**



កម្មាភិបាលខ្មែរក្រហមនៅវាលស្រែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណាត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម សុរិនាថ សីហនុ

## ព្រះវររាជមាតាជាតិខ្មែរ ជំរុញ និងលើកកម្ពស់ការចងចាំ ការផ្សះផ្សាសង្គម ការកសាងសន្តិភាព និងការអភិវឌ្ឍន៍ប្រទេស

*ផេង ពង្សរ៉ាស៊ី*




ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនដល់មន្ត្រីមូលដ្ឋាននៅតាមឃុំសង្កាត់ក្នុងខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អំឡុងពេល៥ថ្ងៃ គឺចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១៩៥ក្បាល ដល់គ្រប់អាជ្ញាធរឃុំសង្កាត់ទាំង៣៣ ក្នុងស្រុកបូរីជលសារ ស្រុកត្រាំកក់ និងស្រុកព្រៃកប្បាស នៃខេត្តតាកែវ។ នេះគឺជាការចែកផ្សាយលើកទីពីរ បន្ទាប់ពីការចែកផ្សាយទស្សនាវដ្ដី «ស្វែងរកការពិត» របស់មជ្ឈ-មណ្ឌលឯកសារកម្ពុជាកាលពីដើមទសវត្សរ៍ឆ្នាំ២០០០កន្លងទៅ នៅតាមបណ្ដាឃុំ សង្កាត់ ស្រុក ខណ្ឌ និងខេត្តនានាទូទាំងប្រទេសកម្ពុជា។ តាមរយៈការចែកផ្សាយនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា

នៅតែត្រូវបានស្គាល់ថា ជាស្ថាប័នមួយដែលមានការទទួលស្គាល់ និងជឿទុកចិត្តពីគ្រប់អាជ្ញាធរមូលដ្ឋាន លើកិច្ចការប្រមែប្រមូល ចងក្រង និងអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ទាំង៣៣ បានសាទរចំពោះការចែកផ្សាយសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» និងបានផ្តល់ការសហការខ្ពស់ក្នុងការកសាងឯកសារប្រវត្តិសាស្ត្រ ដើម្បីការចងចាំជារួមរបស់ប្រជាពលរដ្ឋកម្ពុជា ទាំងចាស់ និងក្មេងព្រមទាំងបានសម្តែងអារម្មណ៍រំភើបរីករាយចំពោះការគិតគូរដល់កូនចៅទាំងអស់គ្នាពីហ្លួងម៉ែ ដែលព្រះអង្គតែងតែយកព្រះទ័យទុកដាក់ចំពោះប្រវត្តិ-សាស្ត្រជាតិ។

ក្នុងជំនួបជាមួយអាជ្ញាធរឃុំទាំងអស់ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ នឹងពង្រឹងទំនាក់ទំនងឲ្យកាន់តែប្រសើរឡើង ក្នុងការសហការការងារជាមួយគ្នាក្នុងកម្រិតមូលដ្ឋាន ដើម្បីបន្តផ្តល់ការអប់រំដល់ក្មេងៗជំនាន់ក្រោយពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីការចងចាំ និងផ្តល់ដល់ប្រជាពលរដ្ឋដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមពីវិធីសាស្ត្រក្នុងការព្យាបាលរបួសផ្លូវចិត្ត និងការអប់រំពីសុខភាពសាធារណៈ ដើម្បីប៉ះប៉ូវនូវភាពអយុត្តិធម៌ដែលពួកគាត់បានបាត់បង់កាលពីក្នុងរបបខ្មែរក្រហម និងផ្តល់ដល់ពួកគាត់នូវការអប់រំថែរក្សាសុខភាពឲ្យល្អប្រសើរឡើងដែលអាចបន្តអាយុជីវិតរស់នៅបានយូរតទៅទៀត។

សៀវភៅ«សាក្សីប្រវត្តិសាស្ត្រ»មានសារសំខាន់ណាស់សម្រាប់អ្នកដែលបានទទួល និងអ្នកអានព្រោះសៀវភៅនេះពិតជាបានធ្វើឲ្យអ្នកទាំងនោះជាពិសេសអ្នកដែលធ្លាប់ឆ្លងកាត់សម័យកាលជូរចត់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០មក រំឭកឡើងវិញពីអតីតកាលរបស់ខ្លួនដែលធ្លាប់ចូលព្រៃម៉ាគីដើម្បីបុព្វហេតុរំដោះជាតិចេញពីការគ្រួតត្រារបស់របបសាធារណរដ្ឋខ្មែរ ដឹកនាំដោយ លន់ នល់ និងដើម្បីនាំយកមេដឹកនាំប្រទេសមួយដែលខ្លួនពេញចិត្ត គឺសម្តេចព្រះ នរោត្តម សីហនុ ត្រឡប់មកប្រទេសវិញ។ សៀវភៅនេះ មិនត្រឹមតែជាឯកសារដ៏មានសារសំខាន់ក្នុងការលើកកម្ពស់ដល់ការចងចាំប្រវត្តិសាស្ត្រជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរួមចំណែកដ៏មានប្រសិទ្ធភាពក្នុងការកសាងសន្តិភាព ការផ្សះផ្សា ការអភិវឌ្ឍន៍ និងការរារាំងការកកើតឡើងវិញនូវរបបប្រល័យពូជសាសន៍។ ប្រធានក្រុមប្រឹក្សាឃុំ ក៏ដូចជាសមាជិកក្រុមប្រឹក្សាទាំងអស់បានបង្ហាញពីការយល់ឃើញចំពោះសៀវភៅនេះថា ជាឯកសារដ៏មានសារសំខាន់មួយ ដែលពួកគាត់អាចយកធ្វើមូលដ្ឋានក្នុងការទប់ស្កាត់អំពើហិង្សាក្នុងសហគមន៍របស់គាត់។



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនដល់មន្ត្រីមូលដ្ឋាននៅតាមឃុំសង្កាត់ក្នុងខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ប្រធានក្រុមប្រឹក្សាឃុំបានការម បាននិយាយថា «ក្មេងៗជំនាន់នេះ មិនយល់ដឹងពីប្រវត្តិសាស្ត្រពីអតីតកាលយើងឡើយ។ វាចេះតែបង្ករឿងឈ្លោះប្រកែកគ្នា ប្រព្រឹត្តអំពើមិនគប្បីក្នុងសង្គម។ ខ្ញុំព្រមានពួកវាច្រើនដងហើយ ហើយថ្ងៃក្រោយប្រសិនជាមានរឿងនេះកើតឡើងទៀត ខ្ញុំនឹងឲ្យវាអង្គុយអានសៀវភៅនេះ ដើម្បីឲ្យវាយល់ថាជីដូនជីតាវាលំបាកយ៉ាងណាកាលពីអតីតកាល។ ខ្ញុំយល់ថា ក្មេងៗទាំងនោះអាចកែប្រែគំនិតបន្តិចម្តងៗ ហើយវានឹងល្អប្រសើរឡើងនាពេលខាងមុខ»។

ប្រធានក្រុមប្រឹក្សាឃុំអង្គខ្នុរ ត្រពាំងក្រញូង បូរីជលសារ និងឃុំឧត្តមសុរិយា បានលើកឡើងដូចៗគ្នាថា គាត់នឹងអញ្ជើញមេភូមិទាំងអស់មកជួបជុំគ្នាដើម្បីឈ្វេងយល់អំពីអត្ថន័យនៅក្នុងសៀវភៅនេះ និងឲ្យផ្សព្វផ្សាយបន្តទៅកាន់អ្នកភូមិ ដើម្បីត្រិះរិះពិចារណាមុននឹងគិតពីការប្រព្រឹត្តអំពើហិង្សាទៅលើនរណាម្នាក់។

មេឃុំត្រពាំងក្រញូង និយាយដូច្នេះថា «ចាស់ៗខ្លះហាក់ដូចជាភ្លេចបាត់អស់នូវទុក្ខលំបាកដែលខ្លួនធ្លាប់ឆ្លងកាត់ ហើយបែរជាប្រព្រឹត្តអំពើហិង្សាលើគ្រួសារ និងអ្នកដទៃ។ ចំណែកឯក្មេងៗជំនាន់ក្រោយរឹតតែមិនដឹងទៀតថា ការតស៊ូដើម្បីគេចចេញពីសង្គ្រាម ជួបប្រទះការលំបាកយ៉ាងណាខ្លះ។ ដូច្នេះ ខ្ញុំនឹងឲ្យអ្នកទាំងនោះចំណាយពេលវេលាអានសៀវភៅនេះ ហើយឲ្យគាត់គិតគូរឡើងវិញពីមូលហេតុដែលនាំឲ្យកើតមានអំពើសម្លាប់មនុស្សយ៉ាងរង្គាលកាលពីរបបខ្មែរក្រហម។ ខ្ញុំចង់និយាយថា ការប្រើប្រាស់អំពើហិង្សាតូចក្តី ធំក្តី វានឹងបង្កទៅជាអសន្តិសុខសង្គម ហើយវាអាចក្លាយជាការប្រព្រឹត្តអំពើប្រល័យពូជសាសន៍»។

មេឃុំបូរីជលសារ និយាយថា «ខ្ញុំធ្លាប់បម្រើការជាប៉ូលិសជាតិក្នុងរបបសង្គមរាស្ត្រនិយម។ ខ្ញុំដឹងថា លោកទាំងពីរលំបាកណាស់ក្នុងការបង្រួបបង្រួមជាតិ និងដឹកនាំប្រទេសឲ្យចាកឆ្ងាយពីសង្គ្រាម។




ក្រុមការងាររមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនដល់មន្ត្រីមូលដ្ឋាននៅតាមឃុំសង្កាត់ក្នុងខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដូច្នេះក្នុងនាមជាប្រជាពលរដ្ឋល្អ យើងគួរគប្បីរួមគ្នាថែរក្សាសន្តិភាព និងកុំប្រព្រឹត្តអំពើហិង្សាដែលនាំឲ្យមានអស្ថិរភាពសង្គម។ សៀវភៅនេះ គឺជាគោលសម្រាប់មនុស្សទាំងអស់ពិចារណាថា តើគួរវិលត្រឡប់ទៅអតីតកាលវិញ ឬគួរឈានជើងឆ្ពោះទៅមុខទៀត ដោយមិនមានសង្គ្រាម»។

នៅតាមសាលាឃុំនីមួយៗដែលយើងបានទៅដល់ និងជួបដើម្បីចែកចាយសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សុទ្ធតែបានបង្កើតការពិភាក្សាដោយឥតគ្រោងទុក ពីការរំពឹកឡើងវិញពីប្រវត្តិអតីតកាលរបស់ខ្លួនឆ្លងកាត់របបខ្មែរក្រហម។ យើងបានអង្គុយស្តាប់ការជជែកពិភាក្សាគ្នាពីប្រវត្តិទាំងនោះយ៉ាងយកចិត្តទុកដាក់ និងបានរៀនសូត្រពីព្រឹត្តិការណ៍នានាដែលបានកើតឡើងតាមតំបន់នីមួយៗ។ ជាមួយគ្នានេះដែរ ក្រុមការងារយើងបានលើកទឹកចិត្តឲ្យគាត់ចែករំលែករឿងរ៉ាវទាំងនោះ ជាមួយក្មេងៗជំនាន់ក្រោយដែលបាន និងកំពុងស្នើសុំធ្វើកិច្ចការងារស្ម័គ្រចិត្តជាមួយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដែលនឹងប្រព្រឹត្តទៅនៅពាក់កណ្ដាលខែកញ្ញា ឆ្នាំ២០២៣ ខាងមុខនេះ។ ក្រុមការងារយើង ក៏បានស្នើសុំឲ្យអាជ្ញាធរឃុំទាំងអស់ ជួយសម្របសម្រួលដល់ក្រុមយុវជនស្ម័គ្រចិត្តទាំងនោះ ក្នុងការចុះទៅជួប និងសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតដែលស្ថិតនៅក្រោមការគ្រប់គ្រងពីអាជ្ញាធរឃុំ។

សូមបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានទទួលពាក្យស្នើសុំធ្វើជាអ្នកស្ម័គ្រចិត្តចំនួន១៤០ នាក់រួចហើយ មកពីស្រុកបូរីជលសារ ស្រុកត្រាំកក់ ស្រុកព្រៃកប្បាស និងស្រុកបាទី។ អ្នកទាំងនោះគឺជាក្មេងៗជំនាន់ក្រោយ ដែលភាគច្រើនមានអាយុក្រោម២៥ឆ្នាំ ហើយសព្វថ្ងៃកំពុងសិក្សានៅវិទ្យាល័យក្នុងខេត្ត និងមហាវិទ្យាល័យ។ មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ នឹងរៀបចំសិក្ខាសាលាមួយនៅដើមខែកញ្ញានេះ ដើម្បីតម្រង់ទិសអ្នកស្ម័គ្រចិត្តកម្ពុជាទាំងនោះ ឲ្យមានជំនាញក្នុងការចុះទៅជួបសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិកំណើតរបស់ខ្លួន។




ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនដល់មន្ត្រីមូលដ្ឋាននៅតាមឃុំសង្កាត់ក្នុងខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្មែរក្រហមចាត់តាំងខ្ញុំឱ្យធ្វើប្រធានក្រុម ដោយសារខ្ញុំអាចធ្វើការងារបានច្រើនមុខ

*សៀង កញ្ញា*



ជា លន់ អាយុ៧២ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជា លន់ អាយុ ៧២ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ កាលពីកុមារភាពខ្ញុំរៀននៅសាលាវត្តដើមបេង ប៉ុន្តែបច្ចុប្បន្នសាលានេះត្រូវបានប្តូរឈ្មោះមកជា សាលាផាន់ផន វិញ។ ខ្ញុំរៀនដល់ថ្នាក់ទី៩ កាលពីសង្គមចាស់។ ខ្ញុំគឺជាក្មេងកំព្រា ហើយត្រូវមីងយកមកចិញ្ចឹម ដោយសារគាត់មានកូនបង្កើតតែម្នាក់។ មីងរបស់ខ្ញុំបានយកខ្ញុំមកនៅជាមួយគ្រាន់បានជាគ្នា។

ឪពុករបស់ខ្ញុំស្លាប់ក្នុងជំនាន់ឥស្សរៈ នៅខេត្តបាត់ដំបង ដោយសារសម័យនោះ គាត់ធ្វើការងារខាងកាប់ដើមឈើធំៗ ហើយក្រោយមក គាត់ក៏ធ្លាក់ខ្លួនឈឺមើលមិនជារហូតដល់ស្លាប់។ ខ្ញុំគិតថាឪពុកខ្ញុំស្លាប់ដោយសារព្រាយដើមឈើកាប់គាត់។ ចំណែកឯម្តាយរបស់ខ្ញុំស្លាប់នៅក្នុងខេត្តពោធិ៍សាត់ ដោយសារអត់អាហារនៅក្នុងរបបខ្មែរក្រហម។

ខ្ញុំបានរៀបការនៅអាយុ១៧ឆ្នាំ ជាមួយបុរសម្នាក់ឈ្មោះ ជួរ ឈិន រស់នៅក្នុងភូមិដើមបេងជាមួយគ្នា។ ក្រោយពីរៀបការរួចហើយ ខ្ញុំមានកូន ២នាក់។ នៅឆ្នាំ១៩៧០ អាចារ្យ អ៊ុន មកហៅប្តី របស់ខ្ញុំឲ្យចូលធ្វើទាហាន លន់ នល់ ហើយប្តីរបស់ខ្ញុំក៏បានចាកចេញទៅ។ ក្រោយមក ខ្ញុំបានប្រាប់ប្តីរបស់ខ្ញុំឲ្យឈប់ធ្វើទាហាន លន់នល់ ព្រោះខ្ញុំដឹងថា ប្តីរបស់ខ្ញុំខ្លាចស្នូរកាំភ្លើងខ្លាំងណាស់។ ខ្ញុំមិនចង់ឲ្យប្តីរបស់ខ្ញុំទៅសមរភូមិទេ។

ខ្ញុំបានជិះម៉ូតូ សេអិល របស់ខ្ញុំទៅយកប្តីខ្ញុំនៅបន្ទាយទាហាននៅក្នុងស្រុកគិរីវង់។ ប្តីរបស់ខ្ញុំព្រមត្រឡប់មកផ្ទះជាមួយខ្ញុំ ហើយមេបញ្ជាការប្តីខ្ញុំ បានឲ្យកាំភ្លើងមួយដើមមកប្តីរបស់ខ្ញុំដាក់ជាប់ខ្លួនរហូតមកដល់ផ្ទះ។ មកដល់ឆ្នាំ១៩៧៤ ខ្ញុំនិងប្តីបានភៀសខ្លួនមករស់នៅទីក្រុងភ្នំពេញ និងប្រកបរបរលក់ម៉ូតូ។ យើងទាំងពីរនាក់ទិញម៉ូតូពីភ្នំពេញយកទៅលក់នៅខេត្តបាត់ដំបង ដោយដឹកតាមយន្តហោះឈ្នួល។ ខ្ញុំជួញដូរម៉ូតូបានតែពីរដើងប៉ុណ្ណោះ ក៏ត្រូវយោធាខ្មែរក្រហមចូលកាន់កាប់បានក្រុងភ្នំពេញ ហើយយើងទាំងពីរនាក់ក៏ជាប់នៅក្នុងខេត្តបាត់ដំបង។ ខ្ញុំតែងតែលាក់ប្រវត្តិ មិនឲ្យខ្មែរក្រហមនិងអ្នកជិតខាងដឹងថាប្តីរបស់ខ្ញុំធ្លាប់ធ្វើទាហានឡើយ។

ខ្ញុំនិងប្ដីរបស់ខ្ញុំរស់នៅក្នុងស្រុកមោង ដែលជាស្រុកកំណើតរបស់ឪពុកខ្ញុំ។ នៅក្នុងរបបខ្មែរក្រហម ប្រធានភូមិបានឲ្យខ្ញុំធ្វើការនៅរោងបាយ និងដឹកបាយសម្លឲ្យប្រជាជនដែលចេញទៅធ្វើការនៅតាមការដ្ឋានផ្សេងៗ។ នៅពេលនោះ ខ្ញុំគឺជាប្រជាជន ១៧ មេសា ប៉ុន្តែដោយសារខ្ញុំមានចិត្តល្អ មានសុជីវធម៌ល្អ ទើបប្រជាជនទូទៅស្រឡាញ់រាប់អានខ្ញុំ។ ចំណែកឯប្ដីរបស់ខ្ញុំ ប្រធានភូមិឲ្យគាត់ទៅនៅក្នុងផ្នែកសេដ្ឋកិច្ច គឺជាកន្លែងបើកអង្ករឲ្យអ្នកនៅតាមកងនីមួយៗ។

នៅពេលនោះ ខ្មែរក្រហមនៅក្នុងភូមិ នឹកស្មានថាខ្ញុំមិនចេះដកសំណាប ព្រោះខ្ញុំគឺជាប្រជាជនថ្មី ក៏សាកល្បងឲ្យខ្ញុំចុះទៅដកសំណាបម្នាក់ឯងឲ្យបានពីរផ្លូនក្នុងមួយថ្ងៃ។ ប៉ុន្តែខ្ញុំអាចធ្វើបាន ព្រោះខ្ញុំគឺជាកូនអ្នកស្រែស្រាប់ និងមិនរួញរាជាមួយការងារបែបនេះឡើយ។ ក្រោយមកទៀត ខ្មែរក្រហមបានឲ្យខ្ញុំទៅបុកអង្ករ ក៏ខ្ញុំចេះបុកអង្ករយ៉ាងស្ទាត់ជំនាញ ព្រមទាំងចេះបុកអង្ករបន្ទឹឡើងដូចជាសំឡេងភ្លេងពិរោះទៀត។ ពេលដែលប្រធានភូមិដឹងថា ខ្ញុំចេះធ្វើការងារច្រើនមុខ ក៏ចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានក្រុម។ ការងារប្រធានក្រុមមិនពិបាកដូចអ្នកដែលនៅក្រោមបង្គាប់នោះទេ។ ខ្ញុំគ្រាន់តែដើរមើល និងដើរប្រាប់សមាជិកក្រុមតែប៉ុណ្ណោះ។ ជីវិតខ្ញុំកាលពីជំនាន់នោះ មិនសូវលំបាកពេកទេ។ នៅតំបន់របស់ខ្ញុំរស់នៅមានអាហារហូបចុកគ្រប់គ្រាន់ និងមិនខ្វះខាតឡើយ។ បន្ទាប់មក ឮដំណឹងថា កងទ័ពវៀតណាមវាយចូលមកប្រទេសកម្ពុជាដើម្បីជួយរំដោះប្រជាជនចេញពីរបបខ្មែរក្រហម ទើបខ្ញុំនិងប្ដីនាំគ្នាត្រឡប់មកស្រុកវិញ។ យើងបានធ្វើដំណើរអស់រយៈពេល ២៨ថ្ងៃ ចេញពីខេត្តបាត់ដំបង ទើបមកដល់ស្រុកគិរីវង់។

បន្ទាប់មក ប្ដីរបស់ខ្ញុំត្រូវបានប្រជាជនស្នើឲ្យធ្វើជាមេភូមិ ព្រោះប្ដីរបស់ខ្ញុំគឺជាមនុស្សស្លូតត្រង់ ហើយថែមទាំងមានចំណេះដឹងទៀត។ ក្រោយមក ប្ដីរបស់ខ្ញុំបានស្លាប់នៅក្នុងឆ្នាំ១៩៨៤ ដោយសារកងទ័ពខ្មែរក្រហមបាញ់ នៅពេលដែលប្ដីរបស់ខ្ញុំទៅចូលរួមក្នុងផែនការ «ក៥» ។ នៅពេលដែលប្ដីរបស់ខ្ញុំស្លាប់ ខ្ញុំទើបតែមានកូនខ្ចីមួយទៀត ដែលមានអាយុទើបតែមួយខែ។ ខ្ញុំគ្មានកម្លាំងធ្វើអ្វីឡើយ ក្រៅពីយំសោកស្ដាយស្រណោះប្ដី។ បន្ទាប់ពីបាត់បង់ប្ដី ខ្ញុំខិតខំប្រឹងប្រែងរកស៊ីដើម្បីចិញ្ចឹមកូនទាំង ៧ នាក់។ ក្រោយមក ខ្ញុំគិតថា ប្ដីរបស់ខ្ញុំស្លាប់ដោយបុព្វហេតុជាតិ ដូច្នេះខ្ញុំក៏បន្តការងារពីប្ដីដើម្បីជួយអភិវឌ្ឍន៍ភូមិឃុំឲ្យបានប្រសើរឡើង ហើយពេលបច្ចុប្បន្នខ្ញុំគឺជាសមាជិកភូមិដើមបេង ទទួលបន្ទុកការងារយេនឌ័រ។



ជា លន់ ផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា កាលពីខែសីហា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ជា លន់ (រូបឈរកណ្ដាល) ទទួលប្រអប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ង៉ែត មោង្ស ៖ អតីតទាហានកន្សែងស

រឹម ស្រីស្រស់



ង៉ែត មោង្ស សព្វថ្ងៃរស់នៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ង៉ែត មោង្ស អាយុ៧៧ឆ្នាំ ប្រកបរបរធ្វើស្រែចម្ការ។ ខ្ញុំកើតនៅភូមិភ្នំដិន ឃុំភ្នំដិន ស្រុកគិរីវង់ ខេត្តតាកែវ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤នាក់ ហើយសព្វថ្ងៃបងប្អូនរបស់ខ្ញុំនៅរស់តែ២នាក់ប៉ុណ្ណោះ។ កាលពីកុមារភាព ខ្ញុំរស់នៅជាមួយឪពុកម្តាយ និងចូលរៀននៅសាលាក្នុងភូមិភ្នំដិន ឃុំភ្នំដិន ស្រុកគិរីវង់ ខេត្តតាកែវ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១១ទេ។ នៅឆ្នាំ១៩៥៩ ខ្ញុំបានឈប់រៀន ហើយបានមកជួយធ្វើស្រែចម្ការឪពុកម្តាយ ព្រោះឪពុកម្តាយរបស់ខ្ញុំមិនមានកម្លាំងគ្រប់គ្រាន់។

នៅឆ្នាំ១៩៦៧ ខ្ញុំបានចូលធ្វើទាហានកន្សែងសតាមការអូសទាញពីអ្នកនៅក្នុងភូមិ ហើយម៉្យាងទៀត ខ្ញុំក៏មានបំណងចង់ចូលដែរដើម្បីជាតិមាតុភូមិ។ យូរៗម្តង ខ្ញុំបានចូលរួមប្រជុំជាមួយសមាជិកឯទៀតនៅក្នុងអង្គភាព ហើយក្រោយពីប្រជុំ គឺខ្ញុំស្នាក់នៅផ្ទះ និងដើរធ្វើការតាមភូមិឃុំ ជាពិសេសភូមិឃុំដែលនៅជាប់ព្រំដែនវៀតណាម។ សមាជិករបស់ទាហានកន្សែងសមានទាំងខ្មែរក្រោម និងខ្មែរលើ។ កងរបស់ខ្ញុំគឺមានឈ្មោះ បេ.សេ.១១៦ (BC116)។

បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ កងទ័ពកន្សែងសបានសហការជាមួយកងទ័ព លន់ នល់ និងធ្វើសកម្មភាពកាន់តែផុសផុលជាងមុន។ នៅឆ្នាំ១៩៧២ ខ្ញុំបានរៀបការប្រពន្ធ។ បន្ទាប់ពីរៀបការបានរយៈពេល៩ខែ យោធាខ្មែរក្រហម បានចូលមកកាន់កាប់តំបន់មួយចំនួននៃខេត្តតាកែវ។ ខ្ញុំជាមួយប្រពន្ធ និងកូនម្នាក់របស់ខ្ញុំបានភៀសខ្លួនទៅប្រទេសវៀតណាម។ អ្នកភូមិជាច្រើននាក់ក៏បានភៀសខ្លួនចេញដំណាលខ្ញុំដែរ។ ខ្ញុំទៅរស់នៅភូមិព្រៃស្វាយ ឃុំព្រៃស្វាយ ស្រុកស្វាយទង (ឬស្រុកទីតូង) ខេត្តមាត់ជ្រូក (ឬខេត្តចូវដុក)។ នៅទីនោះ ភាគច្រើនប្រជាជនខ្មែរកម្ពុជាក្រោមរស់នៅ។

ខ្ញុំទទួលបានអំណោយពីរដ្ឋអំណាចវៀតណាម ហើយកញ្ចប់អំណោយដែលខ្ញុំទទួលបាន គឺសរសេរអក្សរយូអេសអេ (USA)។ ខ្ញុំយល់ថា អំណោយទាំងនោះគឺជាជំនួយរបស់អាមេរិកាំង។ ក្រោយពីទទួលអំណោយប្រចាំខែ ខ្ញុំនិងគ្រួសារខិតខំរកស៊ីធ្វើស្រែចម្ការលើដីដែលរដ្ឋអំណាចវៀតណាមផ្តល់ឲ្យ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមប្រកាសថា នឹងធ្វើការដោះដូរ

ប្រជាជនជាមួយនឹងវៀតណាម។ ប្រជាជនខ្មែរទាំងអស់ដែលបានភៀសខ្លួនទៅប្រទេសវៀតណាមតាំងពីឆ្នាំ១៩៧៤ ក៏ត្រូវវិលត្រឡប់មកស្រុកកំណើតវិញដែរ។ ពេលនោះខ្ញុំបានត្រឡប់មកប្រទេសកម្ពុជាវិញ។ មកដល់ព្រំដែន ខ្ញុំមិនឃើញមានជនជាតិវៀតណាមណាម្នាក់ឆ្លងកាត់ព្រំដែនចូលក្នុងប្រទេសរបស់ខ្លួនឡើយ។ ខ្មែរក្រហមបានយកឡានមកទទួលខ្ញុំ។ អ្នកបើកឡានមិនបានឈប់នៅភូមិកំណើតរបស់ខ្ញុំនៅស្រុកគិរីវង់ឡើយ គឺបើកបង្ហួសទៅកាន់ស្រុកត្រាំកក់ជាកន្លែងដែលខ្ញុំស្នាក់នៅពេញមួយរបបខ្មែរក្រហម។ ខ្ញុំត្រូវបានអ្នកបើកបរខ្មែរក្រហមឲ្យចុះពីលើឡាន និងឲ្យស្នាក់នៅបណ្ដោះអាសន្ននៅភូមិខ្ពបត្របែក ឃុំអូរសារាយ មុននឹងបញ្ជូនខ្ញុំទៅកាន់ភូមិត្រពាំងដងទឹកបន្តទៀត។

មកដល់ដំបូង ខ្មែរក្រហមមិនឲ្យខ្ញុំហូបឆ្អែតទេ។ ប្រធានកងប្រើខ្ញុំឲ្យធ្វើស្រែ និងភ្ជួររាស់។ នៅពេលដែលខ្ញុំកំពុងធ្វើស្រែ ខ្ញុំឃើញកម្មាភិបាលខ្មែរក្រហមបណ្ដើរមនុស្សទាំងខ្សែកាត់តាមវាលស្រែចូលទៅក្នុងព្រៃ។ ខ្ញុំមិនដឹងថាកម្មាភិបាលខ្មែរក្រហមយកអ្នកទាំងនោះទៅកាន់ទីណាឡើយ។ ខ្ញុំគិតថាប្រហែលជាកម្មាភិបាលខ្មែរក្រហមនាំយកអ្នកទាំងនោះទៅសម្លាប់ចោលហើយ។ ខ្ញុំរស់នៅ និងធ្វើការងារគ្រប់យ៉ាងតាមតែកម្មាភិបាលប្រើឲ្យធ្វើ។ ខ្ញុំមិនដែលប្រកែក ឬស្ដីកស្រពន់ឡើយ។ ខ្ញុំតែងតែលាក់ប្រវត្តិរូបរបស់ខ្ញុំដែលធ្លាប់ធ្វើជាទាហានកន្សែងស។ ខ្ញុំដឹងច្បាស់ថា ប្រសិនបើខ្មែរក្រហមដឹងថាខ្ញុំគឺជាទាហានកន្សែងស ខ្ញុំប្រាកដជាស្លាប់ចោលប្រពន្ធកូនជាមិនខាន។

នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវផ្លាស់ប្ដូរទីកន្លែងរស់នៅម្ដងទៀត គឺមករស់នៅភូមិត្រាំកក់ ឃុំត្រាំកក់ ជាកន្លែងដែលខ្ញុំបានឃើញមានការបាចត្រាក់ពីលើយន្តហោះ។ ខ្ញុំបានរើសត្រាក់នោះមកអាន ទើបដឹងថា មានការវាយរំដោះប្រជាជនកម្ពុជាចេញពីរបបខ្មែរក្រហម។ ភ្លាមៗបន្ទាប់ពីការបាចត្រាក់ កម្មាភិបាលខ្មែរក្រហមបានដើរប្រមូលត្រាក់ទាំងនោះពីប្រជាជន និងបានហាមប្រជាជនមិនឲ្យជជែកគ្នាពីអត្ថន័យដែលសរសេរនៅក្នុងត្រាក់នោះឡើយ។

មិនយូរប៉ុន្មានប្រទេសជាតិត្រូវបានរំដោះ ហើយខ្ញុំបានវិលត្រឡប់មកភូមិកំណើតវិញ។ ខ្ញុំរស់នៅឃុំភ្នំដិន ស្រុកគិរីវង់ បានមួយរយៈពេលខ្លី ក៏ត្រូវបានកងទ័ពវៀតណាមចាប់ខ្លួនយកទៅសួរចម្លើយ និងដាក់គុក ព្រោះកងទ័ពវៀតណាមទាំងនោះសង្ស័យថា ខ្ញុំគឺជាកម្មាភិបាលខ្មែរក្រហម។ កងទ័ពវៀតណាមយកកាំភ្លើងវាយ សួរចម្លើយខ្ញុំថា តើខ្ញុំចូលខ្មែរក្រហមតាំងពីពេលណា? និងដឹកនាំកងកម្លាំងបានប៉ុន្មានឆ្នាំហើយ? ខ្ញុំបានបដិសេធ និងប្រាប់ថា ខ្ញុំគឺជាប្រជាជនមិនមែនខ្មែរក្រហមទេ និងមិនដឹកនាំកម្លាំងអ្វីឡើយ។ ខ្ញុំត្រូវជាប់ឃុំឃាំងនៅសាលាបឋមសិក្សាទន្លាប់អស់រយៈពេល១៦ថ្ងៃ។ បន្ទាប់មក ខ្ញុំត្រូវបានដោះលែងឲ្យមករស់នៅជួបជុំប្រពន្ធកូនវិញ។ ខ្ញុំចាប់ផ្ដើមប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត។ មួយរយៈក្រោយមក គ្រួសាររបស់ខ្ញុំបានស្នើសុំផ្លាស់ប្ដូរទីលំនៅពីឃុំភ្នំដិន មកនៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ រហូតមកដល់សព្វថ្ងៃ។



ង៉ែត មោងស្រ ទទួលប្រអប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម៉ម វ៉ាន់ស៊ី ៖ នារីពេទ្យខ្មែរក្រហម

**ផាន់ ឌីន**



ម៉ម វ៉ាន់ស៊ី អាយុ៦៧ឆ្នាំ រស់នៅភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ម៉ម វ៉ាន់ស៊ី អាយុ៦៧ឆ្នាំ បច្ចុប្បន្នរស់នៅភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានបងប្អូនចំនួន៦នាក់ និងស្លាប់អស់ចំនួន៣នាក់។ ខ្ញុំគឺជាកូនទី៣ក្នុងគ្រួសារ។ ម្ដាយខ្ញុំស្លាប់នៅឆ្នាំ១៩៧០ ហើយឪពុកនិងប្ដីខ្ញុំស្លាប់នៅឆ្នាំ១៩៧៩។

កាលពីអាយុ៧ឆ្នាំ ខ្ញុំចូលរៀននៅសាលាវត្តត្រពាំងធំខាងត្បូង។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ ក៏ឈប់រៀននៅឆ្នាំ១៩៧០ ពេលដែលកើតមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ។ បន្ទាប់ពីឈប់រៀន ខ្ញុំជួយការងារឪពុកម្ដាយនៅផ្ទះ។ ក្រោយមកប្រធានភូមិឲ្យខ្ញុំទៅចូលរួមលើកទំនប់ទឹកនៅខ្ពបត្របែក ដើម្បីទប់ទឹកហូរពីលើភ្នំទុកធ្វើស្រែប្រាំង។

នៅឆ្នាំ១៩៧៣ ខ្ញុំលែងទៅលើកទំនប់ ហើយប្ដូរមកធ្វើជានារីពេទ្យវិញ។ ខ្ញុំរៀនវិជ្ជាពេទ្យពីកម្មាភិបាលមកពីហាណូយពីរនាក់គឺ តាផល និង តាង៉ុយ។ ទីតាំងពេទ្យនៅពេលនោះ គឺស្ថិតនៅក្នុងព្រៃភ្នំក្បែរស្ទឹងខ្ពបត្របែក។ កិច្ចការងាររបស់ខ្ញុំគឺដើររកឫសឈើ មើមឈើ និងដើមឈើដែលអាចយកមកផ្សំធ្វើជាថ្នាំបុរាណបាន។ ការធ្វើដំណើរទៅរកថ្នាំជួនកាលខ្ញុំជិះដំរីជាមួយកម្មាភិបាលខ្មែរក្រហមឯទៀត ជួនកាលខ្ញុំដើរពីភ្នំមួយទៅភ្នំមួយស្វែករកឱសថបុរាណ។ ខ្ញុំចេះផ្សំថ្នាំ ចេះបិតស្រាពីឫសឈើ មើមឈើ និងដើមឈើ។ ការផលិតស្រានេះ គឺទីមួយដើម្បីបង្កើតទៅជាអាល់កុលសម្រាប់លាងរបួស។ ទីពីរ គឺដើម្បីលាយជាមួយឱសថផ្សេងទៀតដើម្បីផ្សំថ្នាំគ្រាប់ ដែលកាលនោះគេច្រើនហៅថា «ថ្នាំអាចម៍ទន្សាយ» ហើយទីបី គឺសម្រាប់ធ្វើជាស្រាសម្រាប់ផឹក។ ឫសឈើ និងឱសថដែលខ្ញុំរកមកផ្សំធ្វើថ្នាំមានដូចជា ឈើគ្រាវ ឈើអែម ឈើពពេល និងមើមរំដេង។ ខ្ញុំយកឈើទាំងនោះមកថ្លឹងដើម្បីកំណត់បរិមាណតាមក្បួនខ្នាតដែលខ្ញុំរៀនពីតាផល និងតាង៉ុយ។ បន្ទាប់មក ខ្ញុំយកចំនួនដែលបានកំណត់នេះទៅលាយជាមួយស្ករ និងចាក់មេស្រាលាយឲ្យសព្វទុកសម្រាប់ធ្វើជាថ្នាំបំបាត់ការឈឺចុករោយ។ ចំពោះថ្នាំគ្រុនចាញ់គឺ ទីមួយ ខ្ញុំយករុក្ខជាតិណាដែលមានរសជាតិល្វីងៗដាក់ខ្ទះស្ងោរទឹកបីយកទឹកមួយ។ ទីពីរ ខ្ញុំស្រង់យកកាករុក្ខជាតិទាំងនោះចេញរួចរម្ងាស់បន្តទៀតរហូតដល់ចុងក្រោយនៅសល់ទឹកត្រឹមតែមួយស្លាបព្រាបាយប៉ុណ្ណោះ។ ទីបី ខ្ញុំយកទឹក

នោះទៅលាយជាមួយមេដ្យាមី រួចកូរឲ្យសព្វមុននឹងយកទៅហាលថ្ងៃឲ្យស្ងួត។ ចុងក្រោយ គឺសូនថ្នាំនោះឲ្យទៅជាគ្រាប់ថ្នាំតូចៗដើម្បីទុកព្យាបាល។ រាល់ថ្នាំរបស់ក្រុមខ្ញុំផលិតបាន គឺចែកចាយទូទាំងភូមិភាគ និងមានដាក់លក់នៅតាមទីផ្សារផង។ អ្នកភូមិអាចយកលុយមកទិញថ្នាំទាំងនេះ ហើយលុយដែលបានមកពីការលក់ថ្នាំ គឺត្រូវយកទៅទិញសម្ភារផ្សេងៗដើម្បីបម្រើដល់វិស័យពេទ្យរបស់យើង។

នៅឆ្នាំ១៩៧៤ បន្ទាប់ពីតាផល និងតាង៉ុយ ត្រូវបានចាប់ខ្លួន ខ្ញុំត្រូវបានផ្លាស់ចេញពីកន្លែងផលិតថ្នាំនៅក្បែរស្ទឹងខ្ពបត្របែក ទៅធ្វើការនៅមន្ទីរពេទ្យធំលេខ២២ ឬ ព-២២ វិញ។ ខ្ញុំមិនដឹងថាតាផល និងតាង៉ុយ ស្លាប់ឬរស់ទេ។ ទីតាំងមន្ទីរ ព-២២ ស្ថិតនៅក្នុងវត្តពោធិ៍ម្រាល។ នៅទីនោះ មានទាហានរបួសច្រើនណាស់ដែលត្រូវថែទាំ។ ខ្ញុំគឺជាអ្នកលាងរបួស និងចាក់ថ្នាំឲ្យអ្នកជំងឺ។ ខ្ញុំធ្វើការនៅទីនោះជិតមួយឆ្នាំ។ ខ្ញុំមិនដែលបានឃើញទាហានណាម្នាក់ស្លាប់នៅក្នុងមន្ទីរពេទ្យទេ។

នៅឆ្នាំ១៩៧៥ អង្គការបានផ្លាស់ប្តូរទីកន្លែងធ្វើការរបស់ខ្ញុំម្តងទៀត។ អង្គការបានបញ្ជូនខ្ញុំឲ្យទៅធ្វើជានារីពេទ្យនៅភ្នំជីសូរ។ ប្រធានមន្ទីរពេទ្យឈ្មោះសមមិត្ត ហាក់ និងសមមិត្ត ស៊ិង។ នៅទីនោះ ក៏ដូចនៅពោធិ៍ម្រាលដែរ។ អ្នកជំងឺគឺសុទ្ធតែជាយោធាត្រូវរបួសនៅសមរភូមិ។ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវអង្គការបញ្ជូនឲ្យមកទីរួមខេត្តតាកែវ។ ខ្ញុំភ័យណាស់ ព្រោះពេលនោះមានព្រឹត្តិការណ៍ចាប់ខ្លួនកម្មាភិបាលខ្មែរក្រហមថ្នាក់លើច្រើននាក់ រួមទាំងប្រធានមន្ទីរពេទ្យដែលខ្ញុំកំពុងធ្វើការជាមួយ។ ខ្ញុំខ្លាចអង្គការចាប់ខ្ញុំដោយសារជាប់ពាក់ព័ន្ធ។ តាមពិតអង្គការហៅខ្ញុំឲ្យមកទីរួមខេត្តតាកែវ គឺដើម្បីរៀបការ។ ប្តីរបស់ខ្ញុំ គឺជាអ្នកស្នើសុំខ្ញុំរៀបការ ព្រោះគាត់គឺជាយុទ្ធជនរបួសដែលខ្ញុំធ្លាប់បានលាងរបួសឲ្យគាត់កាលពីពេលកន្លងទៅ។ គាត់ស្រឡាញ់ខ្ញុំតាំងពីពេលនោះមក។ មុនដំបូង ខ្ញុំប្រកែកមិនព្រមរៀបការជាមួយគាត់ទេ។ ប៉ុន្តែបន្ទាប់ពីមានការស្តីបន្ទោសពី តារ៉ែន គឺជាប្រធានកងពលរួចមក ខ្ញុំក៏សុខចិត្តរៀបការជាមួយប្តីរបស់ខ្ញុំ។ បន្ទាប់ពីរៀបការរួច ខ្ញុំនិងប្តីបានមករស់នៅស្រុកកោះធំវិញ។

នៅឆ្នាំ១៩៧៨ ខ្ញុំមានផ្ទៃពោះ និងបង្កើតបានកូនប្រុសម្នាក់។ នៅឆ្នាំ១៩៧៩ ខ្ញុំបានត្រឡប់ស្រុកកំណើតរបស់ខ្ញុំវិញ ពេលដែលកូនខ្ញុំមានអាយុ៧ខែ។ ចាប់តាំងពីនោះមកខ្ញុំបានបែកពីប្តី ហើយក្រោយមកខ្ញុំបានទទួលដំណឹងថា ប្តីរបស់ខ្ញុំបានស្លាប់នៅលើភ្នំស្រង់ដោយមូលហេតុទំនាស់ផ្ទៃក្នុងខ្មែរក្រហម។ ខ្ញុំមិនបានទៅយកសពប្តីរបស់ខ្ញុំទេ។ ខ្ញុំបានចិញ្ចឹមកូនខ្ញុំរហូតដល់ធំ និងមានការងារនៅទីក្រុងភ្នំពេញនាពេលបច្ចុប្បន្ន។



ពេទ្យបដិវត្តន៍របស់ខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ចាប គីមណា ៖ កងនារីក្នុងរបបខ្មែរក្រហម

*ស៊ៀង កញ្ញា*



ចាប គីមណា អាយុ៧០ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ចាប គីមណា អាយុ៧០ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ចាប ឃីត និងម្តាយឈ្មោះ សេង សំ ។ ខ្ញុំមានបងប្អូនបង្កើតចំនួន១០នាក់។ សព្វថ្ងៃនៅរស់តែប្អូននាក់ប៉ុណ្ណោះ ដោយសារក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្អូនបង្កើតរបស់ខ្ញុំប្រាំនាក់ បានចូលធ្វើកងទ័ពខ្មែរក្រហមតាមការស្នើសុំរបស់ប្រធានភូមិ ហើយចាប់តាំងពីចេញពីផ្ទះទៅធ្វើទ័ពរួចមក ប្អូនរបស់ខ្ញុំទាំងប្រាំនាក់មិនដែលឃើញវិលត្រឡប់មកផ្ទះវិញទេ រហូតមកទល់សព្វថ្ងៃនេះ។ ខ្ញុំមិនដឹងថាប្អូនរបស់ខ្ញុំនៅឯណា និងស្លាប់ឬរស់នោះទេ។

បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញមានប្រជាជនថ្មីជាច្រើនបានមកដល់ភូមិរបស់ខ្ញុំ។ ខ្ញុំមិនហ៊ានសួរនាំអ្នកទាំងនោះទេ ព្រោះខ្លាចខ្មែរក្រហមយកខ្ញុំទៅសម្លាប់ចោល។ ទាំងប្រជាជនមូលដ្ឋាន និងប្រជាជនដែលជម្លៀសមកថ្មី គឺត្រូវកម្មាភិបាលខ្មែរក្រហមប្រើឲ្យធ្វើការដូចៗគ្នា។ កាលនោះ ប្រជាជនទាំងអស់ត្រូវបានកម្មាភិបាលខ្មែរក្រហមបែងចែកឲ្យនៅតាមកងរៀងៗខ្លួនរួមមាន កងនារី, កងយុវជន, កងកុមារ, កងមេម៉ាយ និងកងបុរស។ កងយុវជនត្រូវបានខ្មែរក្រហមចាត់តាំងឲ្យរែកដីដំបូកដាក់តាមវាលស្រែ។ កងកុមារត្រូវបានខ្មែរក្រហមឲ្យដើររើសអាចម៍គោ សម្រាប់ដាក់ស្រែ។ ខ្ញុំធ្វើការនៅក្នុងកងនារី មានភារកិច្ចរែកដីនិងជីកប្រឡាយ។ ខ្ញុំមិនដែលទទួលអាហារហូបចុកគ្រប់គ្រាន់ឡើយ ហើយខ្ញុំមានតែសម្លៀកបំពាក់មួយសម្រាប់ប៉ុណ្ណោះ។

នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមចូលមកវាយខ្មែរក្រហម ខ្ញុំនិងកងនារីទាំងអស់នាំគ្នារត់ឡើងភ្នំ។ ខ្ញុំបានបែកគ្នាជាមួយឪពុកម្តាយ និងបងប្អូនទាំងអស់។ ប្រហែលមួយខែក្រោយមក ទើបខ្ញុំវិលត្រឡប់មកកាន់ស្រុកកំណើតវិញ។ នៅតាមផ្លូវមកកាន់ស្រុកកំណើត កងទ័ពវៀតណាមបានឲ្យអង្ករ និងរបស់របរខ្លះទៀតសម្រាប់ដោះស្រាយពេលធ្វើដំណើរមកផ្ទះ។ មកដល់ភូមិកំណើត ខ្ញុំប្រកបរបរធ្វើស្រែចម្ការនៅលើដីស្រែដែលរដ្ឋអំណាចបែងចែកឲ្យ។ នៅឆ្នាំ១៩៧៩ដដែល ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំគឺជាទាហានកម្ពុជាក្រោមឈ្មោះ កន សារិន។ កាលនោះខ្ញុំអាយុ២៧ឆ្នាំហើយ។

សព្វថ្ងៃ ខ្ញុំមានកូន៩នាក់។ កូនៗរបស់ខ្ញុំមានប្តីប្រពន្ធអស់ហើយ ហើយខ្ញុំក៏មិនពិបាករត់លុយ ឬខំធ្វើស្រែដូចពីមុនទៀតទេ ព្រោះមានកូនប្រុសស្រីចិញ្ចឹម។ ពេលខ្លះ ខ្ញុំបាននិយាយរឿងរ៉ាវដែលខ្ញុំធ្លាប់ឆ្លងកាត់ពីសម័យខ្មែរក្រហមប្រាប់ទៅកូនៗ។ ពេលស្តាប់រឿងរ៉ាវទាំងនោះហើយ កូនរបស់ខ្ញុំមានអារម្មណ៍អាណិតខ្ញុំជាខ្លាំង។ កូនខ្លះយំពេលស្តាប់ព្រឹត្តិប្រវត្តិរបស់ខ្ញុំ។ សព្វថ្ងៃនេះ ខ្ញុំនិងប្តីគិតតែធ្វើបុណ្យទាន សន្សំកុសល ដើម្បីបន់ស្រន់កុំឲ្យកើតក្នុងរបបដូចខ្មែរក្រហមទៀត។

# ញឹម សំកើ ៖ គ្រួសារខ្ញុំត្រូវជម្លៀសទៅកាន់ស្រុក១០៩ ដោយសារកំហឹងរបស់កូនស្រីតាម៉ុក

ផេង ពង្សរ៉ាស៊ី



ញឹម សំកើ រស់នៅក្នុងភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ (ផេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ញឹម សំកើ បាននិយាយទាំងអស់សំណើចនៅក្រោមរោងលំហែប្រក់ស័ង្កសីនៅចំហៀងផ្ទះ ដោយបែរមុខទៅរកប្រពន្ធរបស់គាត់ឈ្មោះ ណុប សំ អាយុ៧៤ឆ្នាំថា ការជម្លៀសប្រជាជនមួយភូមិចេញទៅស្រុក១០៩ គឺកើតចេញពីកំហឹងរបស់កូនស្រីតាម៉ុកឈ្មោះ ខុម ដែលជាគណៈឃុំត្រពាំងធំខាងត្បូងក្នុងអំឡុងឆ្នាំ១៩៧៧។ ប្រពន្ធរបស់ សំកើ ក្នុងសម្លៀកបំពាក់ជាអ្នកស្រែប្រ ឡាក់ដីស្រមក បានបង្ហាញទឹកមុខហួសចិត្ត និងមិនបានតបតអ្វីឡើយក្នុងពេលដែលប្ដីរបស់គាត់កំពុងងាកមើលគាត់ និងនិយាយពីរឿងនេះ។ ឆ្នាំនេះ សំកើ មានអាយុ៧៧ឆ្នាំហើយ។ គាត់មិនប្រកបរបរអ្វីទេ ក្រៅពីជួយការងារស្រែចម្ការនៅជុំវិញផ្ទះរបស់គាត់នៅក្នុងភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ សំកើ បានរៀបរាប់ពីហេតុការណ៍ដ៏ហួសចិត្តនេះថា ៖

«នៅឆ្នាំ១៩៧៧ មិនចាំខែ តាម៉ុក ហៅតា១០៥ បានចូលមកកាន់ឃុំត្រពាំងធំខាងត្បូង ដែលជាស្រុកកំណើត ស្របពេលដែលកូនស្រីគាត់ឈ្មោះ (យាយ) ខុម កាលនោះគឺជាគណៈឃុំត្រពាំងធំខាងត្បូង កំពុងចែកខោអាវចាស់ៗដែលជាខោអាវគេប្រើរួច ដល់ប្រជាជនដែលកំពុងប្រូតស្រូវនៅភូមិត្រពាំងស្នាយ។ តាម៉ុក បានចូលមកកន្លែងដែលកូនគាត់កំពុងចែកខោអាវ។ គ្រាន់តែឃើញ តាម៉ុក មកដល់ភ្លាម យាយ អ៊ុន ប្រពន្ធតា ស៊ុក បានស្ទុះទៅជួបគាត់រួចរាយការណ៍ថាប្រជាជនក្នុងភូមិនេះក្រណាស់ខ្វះខាត និងគ្មានអ្វីហូបគ្រប់គ្រាន់ឡើយ។ ដល់អ៊ីចឹង! តាម៉ុក ខឹងណាស់ ហើយក៏ហៅ ខុម មកស្ដីឲ្យ (ស្ដីបន្ទោស) ថា ខុមអត់ចេះមើលប្រជាជនធ្វើឲ្យប្រជាជនត្អូញត្អែរប្រាប់គាត់ពីរឿងខ្វះខាត។ ខុម ហ្នឹងគេខឹងរួចចេញទៅបាត់។ ភ្លាមៗក្រោយមក គេក៏មកប្រាប់ឲ្យប្រជាជនទាំងអស់រស់នៅភូមិត្រពាំងស្នាយ ហ្នឹងឲ្យផ្លាស់ប្ដូរទីលំនៅទៅកាន់ភូមិដើមបេង ឃុំដើមបេង ខាងលិចភ្នំដិន ស្ថិតក្នុងស្រុក១០៩ ទាំងអស់គ្នា ហ្នឹងទៅ។ ប្រជាជនគ្រប់គ្នា សុទ្ធតែដឹងថាការផ្លាស់ប្ដូរទីលំនៅនេះ គឺផ្ដើមចេញពីកំហឹងរបស់ ខុម ចំពោះសេចក្ដីរាយការណ៍របស់ យាយ អ៊ុន ប្រាប់ដល់ឪពុករបស់គាត់។ កាលនោះ ខ្ញុំនិងប្រពន្ធកូនខ្ញុំ មានរទេះមួយ។ យើងធ្វើដំណើរតាមរទេះគោ ហ្នឹងរហូតទាល់តែដល់ភូមិបេង។ ពួកយើងធ្វើដំណើរដង្ហែគ្នាចាកចេញពីភូមិតាមថ្នល់ជាតិឆ្ពោះទៅស្រុក១០៩។ នៅតាមផ្លូវ យើងមានអង្ករបន្តិចបន្តួចគ្រាន់នឹងដាំបាយហូប។ ត្រឹមតែរយៈពេលមួយថ្ងៃទេ ពួកយើងបានទៅដល់ភូមិបេង ជាកន្លែងដែលពួកយើងរស់នៅអស់

រយៈពេលជាងមួយឆ្នាំ។ នៅទីនោះ គេឲ្យពួកយើងស្នាក់នៅក្នុងខ្ទមតូចៗជាច្រើនដែលបានត្រៀមទុករួចជាស្រេចៗ ខ្ញុំស្នាក់នៅក្នុងខ្ទមប្រក់ស្លឹក និងជញ្ជាំងពាសស្លឹកដូងៗ គាហ្វូនជាមនុស្សទៅពីស្រុកត្រាំកក់នេះ គឺជាគណៈឃុំដើមបេង។ យើងស្គាល់គ្នា ហើយ គាហ្វូនក៏មិនបានធ្វើបាបអ្វីដល់យើងច្រើនពេកដែរ។ ពួកយើងភាគច្រើនហូបតែបបរទេ។ ជួនកាលហូបបបរលាយពោតក្រហម។ ជួនកាលហូបបាយលាយមើមក្តួចៗ ប្រពន្ធខ្ញុំជាអ្នកលាងក្តួច និងភ្លក់ក្តួចមុននឹងយកទៅលាយជាមួយបាយចែកឲ្យអ្នកផ្សេងទៀត»។

ស្ថិតក្នុងស្រុក១០៩ ញ៉ឹម សំកើ និងគ្រួសារ មិនដែលបានចាកចេញពីកន្លែងដែលគាត់ស្នាក់នៅ និងទៅធ្វើការនៅកន្លែងផ្សេងឡើយ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ សំកើ បាននិយាយថា គាត់ពុំដែលឃើញអ្នកស្រុក១០៩ណាម្នាក់ទាល់តែសោះ។ សំកើ បានសន្និដ្ឋានថា អ្នកទាំងនោះបានចាកចេញពីស្រុកកំណើតរបស់ខ្លួនទៅនៅឆ្ងាយ ប៉ុន្តែមិនដឹងទៅកាន់ទីកន្លែងណា។

នៅឆ្នាំ១៩៧៩ សំកើ និងគ្រួសារបានវិលត្រឡប់មកកាន់ស្រុកកំណើតរបស់ខ្លួនវិញតាមរទេះគោរបស់គាត់ដដែល។ នៅតាមផ្លូវត្រឡប់មកផ្ទះ គាត់និងគ្រួសារត្រូវបានឃាត់សួរនាំម្តងនៅដំណាក់ក្រសាំង។ បន្ទាប់មក គាត់បានធ្វើដំណើរមកដល់ស្រុកកំណើត និងបន្តដំណើរទៅកាន់ស្រុកកំណើតឪពុកក្មេកនៅឃុំស្រែចែង ស្រុកជុំគិរី ខេត្តកំពត ដើម្បីស្នាក់នៅជាបណ្តោះអាសន្ន មុនពេលដែលគាត់វិលត្រឡប់មកកាន់ស្រុកកំណើតវិញនៅក្នុងរដូវច្រូតឆ្នាំ១៩៧៩។ «នៅរដូវច្រូត ឆ្នាំថោះ ខ្ញុំនិងប្រពន្ធបានចេញដំណើរមកស្រុកកំណើត ដោយសារកងទ័ពវៀតណាមចូលមកវាយបណ្តេញខ្មែរក្រហមយ៉ាងប្រសេចប្រសាចពេញស្រុក១០៩។ យើងបានមកដល់ដំណាក់ក្រសាំង ហើយត្រូវខ្មែរក្រហមឃាត់ដំណើរ សួរនាំពីការចាកចេញរបស់ខ្ញុំ។ ពេលខ្ញុំមកដល់ស្រុកកំណើតឪពុកមាខាងប្រពន្ធខ្ញុំបានឃាត់មិនឲ្យខ្ញុំរត់ទៀតទេ ប៉ុន្តែខ្ញុំមិនស្តាប់គាត់។ ខ្ញុំបានលួចរត់ទៅកាន់ស្រុកឪពុកក្មេកខ្ញុំនៅឃុំស្រែចែង ស្រុកជុំគិរី ខេត្តកំពត។ ខ្ញុំស្នាក់នៅទីនោះបីបួនខែទៀត ទើបខ្ញុំសម្រេចចិត្តចាកចេញមកកាន់ស្រុកវិញ។ ពេលធ្វើដំណើរមកដល់វត្តចកក្នុងស្រុកជុំគិរីដដែល ប្រពន្ធខ្ញុំឈឺពោះឆ្លងទន្លេកូនស្រីទី៤។ ខ្ញុំបានដើររកឆ្មបមកបង្កើត រហូតទាល់តែជួប ហើយពេទ្យឆ្មបនោះបានជួយសម្រាលកូនរបស់ខ្ញុំបានជោគជ័យ។ ពួកយើងបានមកដល់ស្រុកកំណើតវិញ និងបានកសាងជីវិតនិងគ្រួសារឡើងវិញរហូតដល់ពេលនេះ។»

សំកើ មិនដែលនិយាយរឿងរ៉ាវរបស់គាត់ឆ្លងកាត់របបខ្មែរក្រហមប្រាប់ទៅកូនៗរបស់គាត់ឡើយ ព្រោះគាត់គិតថាជាការឥតប្រយោជន៍ និងជាកំហឹងរបស់បុគ្គលម្នាក់ដែលធ្វើឲ្យប្រជាជនដែលមិនដឹងអ្វីទាល់តែសោះត្រូវជម្លៀសចេញពីស្រុកកំណើត។ គាត់ក៏មិនបានដឹងដែរថា តើ ខុម ដែលជាកូនរបស់គាម៉ុក មានវាសនាយ៉ាងដូចម្តេចដែរ? ហើយក៏មិនបានចាប់ទោសអួសដំណើរអ្វីដល់ ខុម ក្នុងពេលនោះដែរ ព្រោះគាត់សំអាងថា ខុម គឺជាកម្មាភិបាលថ្នាក់លើម្នាក់ ដែលមានសិទ្ធិក្នុងការធ្វើអ្វីគ្រប់បែបយ៉ាងបានតាមអំពើចិត្ត។ ផ្ទុយទៅវិញ សំកើ បែរជាហួសចិត្ត និងអស់សំណើចនៅពេលដែលគាត់រំឭករឿងនេះប្រាប់យើង ក្នុងអំឡុងពេលជាង៤៣ឆ្នាំក្រោយរបបខ្មែរក្រហមដួលរលំទៅ។



ជួរភ្នំដំរីរមៀល ស្ថិតនៅស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គី ហៀង ៖ ខ្ញុំចូលធ្វើទ័ពខ្មែរក្រហមដោយសារកំហឹង

**ផេង ពង្សរ៉ាស៊ី**



គី ហៀង សព្វថ្ងៃរស់នៅភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

គី ហៀង កើតក្នុងគ្រួសារក្រីក្រមួយកាលពីទសវត្សរ៍ឆ្នាំ១៩៥០។ គាត់មិនបានរៀនសូត្រជ្រៅជ្រះដូចក្មេងឯទៀតក្នុងភូមិឡើយ។ ហៀង នៅតែរំពុកពីរឿងនេះថា គាត់ខ្មាស់ក្មេងឯទៀតណាស់ និងមិនហ៊ានលេចមុខឲ្យអ្នកទាំងនោះឃើញឡើយ ព្រោះគាត់មិនបានបន្តការសិក្សាទៀតដោយសារឪពុកម្តាយក្រីក្រ។ នៅក្នុងបន្ទុកឪពុកម្តាយ ហៀង តែងតែជួយសម្រាលការងារផ្ទះជំនួសឪពុកម្តាយ ដូចជា ធ្វើស្ករត្នោត និងធ្វើស្រែ។ នៅឆ្នាំ១៩៧១ ហៀង បានរៀបការតាមឪពុកម្តាយផ្សំផ្គុំឲ្យ។ នៅឆ្នាំ១៩៧៣ ហៀង បានចេញទៅធ្វើបដិវត្តន៍ ក្នុងពេលដែលគាត់មានកូនពីរនាក់ក្នុងបន្ទុក។ គាត់បានចាកចោលប្រពន្ធនិងកូន ដោយសារតែកំហឹងវណ្ណៈ និងចង់បានសង្គមមួយដែលគ្មានវណ្ណៈជិះជាន់។ ខាងក្រោមនេះ គឺជាការរៀបរាប់របស់ ហៀង អំពីដំណើរជីវិតចាកចេញពីផ្ទះដើម្បីបដិវត្តន៍ និងរឿងរ៉ាវជីវិតជាយុទ្ធជនដែលចាប់ផ្តើមពីយុទ្ធជនបម្រើខ្មែរក្រហម រហូតដល់យុទ្ធជនប្រយុទ្ធប្រឆាំងនឹងខ្មែរក្រហមវិញ៖

## ស្ម័គ្រចិត្តចូលបម្រើកងទ័ពដោយសារកំហឹងវណ្ណៈ

នៅឆ្នាំ១៩៧៣ គី ហៀង បានស្ម័គ្រចិត្តចូលបម្រើកងទ័ពខ្មែរក្រហម ដោយសារមិនពេញចិត្តចំពោះព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ និងស្អប់ខ្ពើមភាពខែងរ៉ែងរបស់មេទ័ពនៃរបប លន់ នល់ ឈ្មោះ ហ៊ុន ទីម ដែលតែងតែបង្ហាញភាពអស្ចារ្យរបស់ខ្លួនក្នុងការដឹកនាំទ័ពវាយកងកម្លាំងខ្មែរក្រហមនៅតាមជើងភ្នំដំរីរមៀលកាលពីអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៧០។ «ខ្ញុំឃើញមេទាហាន លន់ នល់ ម្នាក់ឈ្មោះ ហ៊ុន ទីម ដើរកាន់ឈើច្រត់នៅពីមុខកងទ័ពរបស់គាត់ ចេញពីវាយប្រហារកងកម្លាំងខ្មែរក្រហមនៅក្នុងព្រៃកាត់តាមភូមិខ្ញុំ ហើយមើលទៅគាត់បញ្ចេញបុកពាក្រអឺតក្រទមណាស់។ នរណាៗក៏ខ្លាចគាត់ដែរ។ កាលពីមានព្រឹត្តិការណ៍បាតុកម្មនៅអង្គតាសោមថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ តា ហ៊ុន ទីម នេះបានបាញ់សម្លាប់សិស្សនិស្សិត និងប្រជាជនដែលចូលរួមធ្វើបាតុកម្មច្រើននាក់ណាស់។ ខ្ញុំមិនពេញចិត្តចំពោះបុកពាដូច្នេះទេ ហើយក៏មិនចង់ឃើញគាត់ដើរប្រផេងប្រផាងនៅក្នុងភូមិខ្ញុំតទៅទៀតដែរ»។

គី ហៀង បានចាកចេញពីផ្ទះនៅវេលាម៉ោងប្រហែល៩ព្រឹក ឆ្ពោះទៅកាន់មន្ទីរឃុំត្រពាំងធំខាងត្បូង ដើម្បីសុំចុះឈ្មោះចូលបម្រើកងទ័ពខ្មែរក្រហម។ គណៈឃុំឈ្មោះ ហួន និង ចិន ជាអ្នកទទួល ហៀង ឲ្យចូលបម្រើបដិវត្តន៍។ ទៅជាមួយ ហៀង មានឈ្មោះ សុន (បច្ចុប្បន្នជាមេភូមិមួយក្នុងឃុំត្រពាំងធំខាងត្បូង), លីន (ស្លាប់), ម៉ៅ ម៉ាក (ស្លាប់), ឃឹម ថន (នៅរស់) និង យា មាន (ស្លាប់)។ ដំបូងឡើយ អ្នកទាំង៦នាក់ ត្រូវបញ្ជូនទៅកាន់មន្ទីរស្រុកដើម្បីរៀនក្បួនយុទ្ធសាស្ត្រ និងចូលធ្វើជាកងទ័ពស្រុកត្រាំកក់។ បន្ទាប់មក អ្នកទាំងនោះត្រូវបានបញ្ជូនទៅកាន់តំបន់១៣ ដើម្បីត្រៀមប្រយុទ្ធជាមួយទាហាន លន់ នល់។ «ខ្ញុំបានចេញពីផ្ទះនៅម៉ោង៩ព្រឹក នាថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៣។ ខ្ញុំបានស្ម័គ្រចិត្តចូលបម្រើកងទ័ពខ្មែរក្រហម។ ខ្ញុំបានបបួលគ្នា៥នាក់ទៀតគឺ សុន, លីន, ម៉ៅ ម៉ាក, ឃឹម ថន និង យា មាន ទៅជាមួយដើម្បីបានជាគ្នា។ ខ្ញុំចូលនៅមន្ទីរឃុំត្រពាំងធំខាងត្បូង ដោយមាន តា ហួន និង តាចិន គណៈឃុំ ជាអ្នកទទួលពួកខ្ញុំ។ ក្នុងចំណោមគ្នាខ្ញុំទាំង៦នាក់ មកដល់បច្ចុប្បន្ននេះ ស្លាប់អស់បីនាក់ហើយគឺ លីន, ម៉ាក និងមាន។ កាលពីខ្ញុំចូលធ្វើកងទ័ពដំបូង ខ្ញុំត្រូវមេបញ្ជាការយោធាស្រុកបញ្ជូនឲ្យចូលរៀនក្បួនសឹកនៅដកសាប ក្នុងឃុំសំរោង ស្រុកត្រាំកក់ ហើយមេបញ្ជាការគឺជាអ្នកបង្រៀនផ្ទាល់។ កាលនោះ ខ្ញុំស្ថិតនៅក្នុងកងស្រុកត្រាំកក់ (យោធាស្រុក)។ មេរៀនដែលខ្ញុំបានរៀនគឺ របៀបលួន និងក្រាប របៀបបាញ់ របៀបដោះគ្រាប់ និងមនោគមវិជ្ជាបដិវត្តន៍»។

## បម្រើការនៅអង្គភាព៣៣០ តំបន់១៣

ហៀង បានចូលរួមធ្វើសង្គ្រាមជាច្រើនសមរភូមិនៅក្នុងស្រុកត្រាំកក់ និងស្រុកគិរីវង់ មុនពេលដែលប្រទេសជាតិត្រូវធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមភាគច្រើនត្រូវបានរំសាយ និងបញ្ជូនមកកាន់ស្រុកកំណើតវិញដើម្បីចូលរួមបង្កបង្កើនផល ហើយមានតែកងទ័ពភាគតិចតែប៉ុណ្ណោះ ដែលទទួលបានការផ្លាស់ប្តូរតួនាទី ឬកន្លែងធ្វើការ។ «ខ្ញុំត្រូវអង្គការថ្នាក់លើផ្ទេរភារកិច្ចឲ្យមកធ្វើការនៅក្នុងអង្គភាព៣៣០ជាអង្គភាពបម្រើការខាងផ្នែករោងចក្រឧស្សាហកម្មរបស់តំបន់១៣វិញ។ អង្គភាពនេះ មានទីតាំងស្ថិតនៅក្នុងខេត្តតាកែវ។ ខ្ញុំធ្វើការនៅទីនោះអស់រយៈពេលជាងបីឆ្នាំ ទើបអង្គការស្នើខ្ញុំឲ្យទៅរៀនខាងមុខជំនាញវារីអគ្គិសនីនៅភ្នំពេញ និងកំពង់ស្ពឺ ត្រង់ចំណុចទំនប់រលាំងជ្រៃ ជាមួយជំនាញការចិន។ ខ្ញុំចេញពីអង្គភាព៣៣០ នៅក្នុងរដូវប្រាំងឆ្នាំ១៩៧៨។ ខ្ញុំធ្លាប់ទទួលបានការតែងតាំងជាជំនួយការអង្គភាព បន្ទាប់ពីអង្គការថ្នាក់លើចាប់ខ្លួន យោគ គឺជាប្រធានអង្គភាព និង សុខ ជាអនុប្រធានអង្គភាព កាលពីឆ្នាំ១៩៧៧។ ក្នុងតំណែងជាជំនួយការ ខ្ញុំបានធ្វើការយ៉ាងជិតស្និទ្ធជាមួយ លាង គឺជាប្រធានអង្គភាពដែលទើបនឹងផ្លាស់មក និង វ៉ាន់ គឺជាអនុប្រធាន រហូតដល់គាត់មានការផ្លាស់ប្តូរមករៀនសូត្របន្ត»។

## វិលចូលបម្រើការជាកងទ័ពខ្មែរក្រហមម្តងទៀត និងបង្កើតកងថ្មី

ក្នុងព្រឹត្តិការណ៍ច្របូកច្របល់នៅចុងឆ្នាំ១៩៧៨ ជាពេលដែល ហៀង កំពុងបន្តការសិក្សាផ្នែកវារីអគ្គិសនីនៅរលាំងជ្រៃ។ កម្មាភិបាលខ្មែរក្រហមទាំងអស់បានរត់បោលផ្លូវ និងភារកិច្ចរបស់ខ្លួន ហើយរត់ភៀសខ្លួនទៅកាន់ទិសដៅចុងក្រោយរបស់ខ្លួននៅភាគខាងលិចប្រទេសកម្ពុជា។ ហៀង និងសមមិត្តរួមជំនាន់ បានរត់ភៀសខ្លួនទៅភាគខាងលិចដូចកម្មាភិបាលខ្មែរក្រហមផ្សេងទៀត។ គាត់បានធ្វើដំណើរកាត់តាមបុសដង់ អន្លង់ភ្លៀវ និងឆ្លងកាត់តាមផ្លូវជាតិលេខ៤ ឆ្ពោះទៅទិសខាងលិច។ ក្នុងពេលដែលកំពុងភៀសខ្លួននៅតាមផ្លូវ ហៀង និងអ្នកឯទៀតបានជួបមេបញ្ជាការវរសេនាធំ (មិនចាំលេខ) ឈ្មោះ ប៊ូវ៉ាន ហើយត្រូវ ប៊ូវ៉ាន បញ្ចុះបញ្ចូលឲ្យចូលក្នុងជួរ

កងទ័ពឡើងវិញ ដើម្បីតស៊ូប្រយុទ្ធប្រឆាំងជាមួយនឹងវត្តមានរបស់កងទ័ពវៀតណាមដែលកំពុងវាយរុញច្រានកងទ័ពខ្មែរក្រហមឲ្យចុះចាញ់។ ប៉ូវ៉ាន បានបំពាក់អាវុធដល់ ហៀង និងយុទ្ធមិត្តឯទៀត ព្រមទាំងបានបង្កើតកងថ្មីមួយទៀតឈ្មោះថា «កងពិសេស» ឬ «កងគ្មានលេខ»។ កងនេះ ត្រូវបានបង្កើតឡើងភ្លាមៗ និងមិនមានការចាត់តាំងត្រឹមត្រូវពីថ្នាក់ដឹកនាំភូមិភាគ ឬតំបន់ឡើយ ហើយកងទ័ពដែលមាននៅក្នុងកងនេះ ក៏មិនមានគ្នាច្រើនដែរ។

## បរាជ័យចុងក្រោយ និងការវិលត្រឡប់មកស្រុកកំណើត

បន្ទាប់ពីបង្កើតបានកងថ្មីរួចហើយ កងនេះបានអនុវត្តក្បួនសឹកមួយឈ្មោះថា «ប្រែះស៊ីដែក» ដើម្បីបំផ្លាញ ឬបង្អាក់ដំណើរកងទ័ពវៀតណាមដែលដេញវាយកងទ័ពខ្មែរក្រហមពីក្រោយ។ តាមការឲ្យដឹងពី ហៀង ថា សង្គ្រាមប្រែះស៊ីដែក គឺសំដៅលើសង្គ្រាមឆ្មក់ ឬសង្គ្រាមវាយដកៗ ឬសង្គ្រាមឈ្លប។ នៅដើមឆ្នាំ១៩៧៩ ហៀង និងកងពិសេស រួមទាំង ប៉ូវ៉ានផង បានចាញ់សង្គ្រាម និងបានដកថយរហូតដល់ភាគខាងលិចប្រទេស។ ក្រោយមក កងពិសេស ឬកងគ្មានលេខ ត្រូវបានរំលាយ។ ប៉ូវ៉ាន បានស្លាប់ដោយសារជំងឺរបស់ខ្លួនឯង។ អ្នកឯទៀតបានចាកចេញទៅកាន់ទីកន្លែងផ្សេងៗដែលពួកគេចង់ទៅ។ ហៀង បានវិលត្រឡប់មកផ្ទះវិញជាមួយបងប្រុសបង្កើត។ នៅតាមផ្លូវ បងប្រុសរបស់ ហៀង បានស្លាប់ ហើយគាត់បានធ្វើដំណើរទៅដល់ខេត្តកោះកុង ជាកន្លែងដែលគាត់ត្រូវបានចាប់ខ្លួនដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ គាត់ត្រូវបានបញ្ជូនមកកាន់កំពង់សោម ដើម្បីឃុំឃាំង។ នៅខែកក្កដា ឆ្នាំ១៩៧៩ ហៀង ត្រូវបានដោះលែងឲ្យវិលត្រឡប់មកស្រុកកំណើតវិញ។ មុនពេលដោះលែង ហៀង ទទួលបានលិខិតមួយច្បាប់ចេញដោយអាជ្ញាធរខេត្តកំពង់សោម និងមានបោះត្រាក្រហមពីជនាញការវៀតណាមប្រចាំនៅខេត្តនោះ ដើម្បីឲ្យ ហៀង ប្រើប្រាស់ជាលិខិតបើកផ្លូវសម្រាប់ការធ្វើដំណើរត្រឡប់មកផ្ទះសម្បែងវិញរបស់គាត់។

## ចូលកាន់អាវុធម្តងទៀត ប្រយុទ្ធប្រឆាំងនឹងក្រុមឧទ្ទាមខ្មែរក្រហម

នៅឆ្នាំ១៩៨៣ ហៀង ត្រូវបានស្នើឲ្យចូលធ្វើជាប្រធានភូមិត្រពាំងតាសោម និងគ្រប់គ្រងកងសេនាជនភូមិ។ តាំងពីមានការចាត់តាំងមក ហៀង ពុំសូវបានស្នាក់នៅផ្ទះនៅពេលយប់ទេ។ ហៀង និងសេនាជនក្នុងភូមិ ត្រូវទទួលបន្ទុកយាមកាមភូមិ និងត្រៀមប្រយុទ្ធគ្រប់ពេលជាមួយក្រុមឧទ្ទាមខ្មែរក្រហមដែលមានមូលដ្ឋាននៅក្នុងព្រៃនាជើងភ្នំដំរីរមៀល។ ភារកិច្ចនេះ ត្រូវ ហៀង កាន់ក្តាប់រហូតដល់គាត់ទទួលបានការប្រកាសថ្មីមួយទៀតថាជាកងជីវពលប្រចាំស្រុកត្រាំកក់ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៩៨ និងចេញប័ណ្ណប្រើប្រាស់ចុះហត្ថលេខាដោយវរសេនីយ៍ឯក កង សំអឿន។ ប័ណ្ណដដែលនេះ បានបញ្ជាក់ថា ហៀង ទទួលបានការប្រើប្រាស់អាវុធប្រភេទអាកា លេខ៦៦១៦ សម្រាប់ការពារភូមិឃុំពីការវាយឆ្មក់នានាពីទ័ពព្រៃខ្មែរក្រហមដែលមានទីតាំងស្ថិតនៅខាងជើងភ្នំដំរីរមៀល។ សុពលភាពនៃការប្រើប្រាស់អាវុធ និងប័ណ្ណសម្គាល់របស់ ហៀង បានបញ្ចប់នៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨។

## ជីវិតសាមញ្ញនាពេលបច្ចុប្បន្ន

សព្វថ្ងៃ ហៀង មានអាយុ៧២ឆ្នាំហើយ។ គាត់បានស្នើសុំឈប់បម្រើការជាមេភូមិនៅឆ្នាំ២០១៨ បន្ទាប់ពីគាត់បានបម្រើការជាមេភូមិអស់រយៈពេលជាង៣០ឆ្នាំរួចមក។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ ក៏គាត់នៅតែជាអ្នកជួយជ្រោមជ្រែង និងចាត់ចែងការងារនៅក្នុងភូមិដដែល។ ជារៀងរាល់ថ្ងៃសីល ហៀង តែងទៅកាន់វត្តអារាមដែលនៅក្បែរផ្ទះរបស់គាត់ ស្ថិតនៅជាប់នឹងជើងភ្នំដំរីរមៀល ដើម្បីសុំសីល និងរៀបចំកម្មវិធីសាសនាផ្សេងៗ។ ហៀង បានប្រាប់ថា ជីវិតគាត់នាពេលបច្ចុប្បន្ននេះ គឺគិតតែពីការសាងបុណ្យកុសលដើម្បីគាត់ទទួលបានការតបស្នងមកវិញនូវសេចក្តីសុខផ្លូវអារម្មណ៍ និងផ្លូវចិត្ត។

# ធឹក ង៉ែត ៖ កងនារីរែកអំបិល

រៀបរៀង ស្រីពេជ្រ



ធឹក ង៉ែត អាយុ៦៥ឆ្នាំ រស់នៅភូមិស្រែពោធិ៍ ឃុំចារ ស្រុកព្រៃកប្បាស ខេត្តតាកែវ កំពុងរៀបរាប់បទពិសោធន៍ជីវិតឆ្លងកាត់របបខ្មែរក្រហមទៅកាន់អ្នកស្ម័គ្រចិត្ត មជ្ឈមណ្ឌលឯកសារខេត្តតាកែវ។
(ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ធឹក ង៉ែត អាយុ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិស្រែពោធិ៍ ឃុំចារ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីយោធាខ្មែរក្រហមឡើងកាន់អំណាច ខ្មែរក្រហមបានធ្វើបាបខ្ញុំ និងក្រុមគ្រួសារខ្ញុំ ព្រោះដឹងថាបងប្រុសរបស់ខ្ញុំគឺជាអតីតទាហាន លន់ នល់។ ខ្មែរក្រហមបានជម្លៀសប្រពន្ធកូនបងប្រុសរបស់ខ្ញុំដែលធ្លាប់ធ្វើទាហាន លន់ នល់ ទៅកាន់ខេត្តបាត់ដំបង។ ចំណែកខ្ញុំត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការងាររែកអំបិល។ ខ្ញុំតែងតែប្រុងប្រយ័ត្ននូវរាល់សកម្មភាពសព្វគ្រប់បែបយ៉ាង តាមដែលអាចធ្វើទៅបាន។ ខ្ញុំខិតខំធ្វើការងារជូនអង្គការមិនហ៊ានសម្រាកទេ សូម្បីតែពេលខ្ញុំឈឺ។ ខ្ញុំធ្វើការរហូតទាល់តែដួលសន្លប់នៅ ហ្នឹងកន្លែង ទើបប្រធានកងបញ្ជូនខ្ញុំទៅកាន់មន្ទីរពេទ្យ។ ខ្ញុំសម្រាកនៅពេទ្យបានពីរយប់ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យមកធ្វើការងារដូចធម្មតាវិញ។ ខ្ញុំរែកអំបិលបីគោនក្នុងមួយថ្ងៃដោយសារ មានអ្នកខ្សឹបប្រាប់ខ្ញុំថា ប្រសិនបើមិនខំប្រឹងធ្វើការងារទេប្រយ័ត្នអង្គការយក

ទៅសម្លាប់ចោល។ ក្រោយពីធ្វើការនៅស្រែអំបិល អង្គការបានចាត់តាំងខ្ញុំឲ្យឃ្វាលក្របី, វេញខ្សែគោ, ធ្វើបង្គីក្នុងមួយថ្ងៃឲ្យបាន១២គូ និងបន្សាំគោស្ទាវចំនួន២៥នឹមដើម្បីភ្ជួរស្រែ។ គ្រប់ការងារដែលខ្មែរក្រហមបានដាក់ឲ្យ គឺខ្ញុំធ្វើបានទាំងអស់ដោយមិនហ៊ានប្រកែកប្លុកប៉ាំ ឡើយ ព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោល។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំត្រូវផ្លាស់មកធ្វើការងារជាកងដឹកជញ្ជូន វិញចំណែកការហូបចុក ខ្ញុំទទួលបានតែបបរាវដែលមានតែអង្ករប៉ុន្មានគ្រាប់ប៉ុណ្ណោះ។ ថ្ងៃខ្លះ ពេលដែលខ្ញុំចេញទៅឃ្វាលក្របី ខ្ញុំបានដើររើសត្នោតទុំយកមកហូបបន្ថែម។

រឿងរ៉ាវដែលខ្ញុំឈឺចាប់និងចងចាំមិនអាចបំភ្លេចបានគឺ ខ្មែរក្រហមបានធ្វើទារុណកម្មនិងចាក់ថ្នាំសម្លាប់ឪពុករបស់ខ្ញុំ ដោយខ្មែរក្រហមចោទគាត់ថា គឺជាក្រុមមូលធនកាលពីជំនាន់មុន។ ចំណែក បងប្រុសរបស់ខ្ញុំនិងប្រពន្ធត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល ដោយសារតែមានថ្ងៃមួយកូនរបស់ពួកគាត់ចង់ហូបត្រី ហើយពួកគាត់លួចចេញទៅរកត្រីឲ្យកូនហូបរហូតហួសម៉ោងធ្វើការ។ ខ្ញុំបានស្វែងរកក្មួយដែលកងនារីយកទៅចិញ្ចឹម ប៉ុន្តែខ្ញុំរកមិនឃើញ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ខ្ញុំបានទៅរស់នៅជំរំ ហើយឆ្លៀតចូលទៅសួររកក្មួយដែលបាត់ខ្លួននៅអង្គការកាកបាទក្រហមនៅជំរំ ប៉ុន្តែរកមិនឃើញ។

ក្រោយមកខ្ញុំបានរៀបការ និងខិតខំរកប្រាក់។ ខ្ញុំបានត្រឡប់មកស្រុកកំណើតប្រកបរបរធ្វើស្រែ រហូតមកដល់សព្វថ្ងៃ។ ទោះបីយ៉ាងណាក៏ដោយ ក៏ខ្ញុំរស់នៅប្រកបដោយភាពរីករាយ និងមានសិទ្ធិសេរីភាពគ្រប់គ្រាន់ក្នុងការប្រកបការងារផ្សេងៗ។



ធីក ង៉ែត ទទួលប្រអប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តតាកែវ។ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# មួយទសវត្សរ៍ធ្វើទាហានបីរបប

ផេង ពង្សរ៉ាស៊ី



គង់ ស៊ិន សព្វថ្ងៃរស់នៅភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាចាស់ទុំនៅក្នុងភូមិដែលមានសុខភាពល្អ មានមាឌមាំ រួមជាមួយការចងចាំផង គង់ ស៊ិន បានរំឭកអំពីប្រវត្តិផ្ទាល់ខ្លួន បទពិសោធន៍ជីវិតឆ្លងកាត់សង្គ្រាមនៅក្នុងទឹកដីប្រទេសវៀតណាម និងកម្ពុជា កាលពីអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ថា៖

នៅឆ្នាំ២០២២នេះ ខ្ញុំមានអាយុ៧៨ឆ្នាំហើយ ហើយបច្ចុប្បន្ន ខ្ញុំរស់នៅភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ ខ្ញុំមានស្រុកកំណើតនៅឃុំយ៉ិនទង ស្រុកយ៉ាន់យ៉ាវ ខេត្តមាត់ជ្រូក កម្ពុជាក្រោម (បច្ចុប្បន្នប្រទេសវៀតណាម)។ ខ្ញុំនិងប្រពន្ធកូន ព្រមទាំងឪពុកម្តាយ បានមករស់នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧៨ បន្ទាប់ពីកងកម្លាំងខ្មែរក្រហមបានវាយលុកលុយចូលដល់ទឹកដីដែលជាស្រុកកំណើតរបស់ខ្ញុំ និងបានកៀរប្រជាជនកម្ពុជាក្រោមស្ទើរតែទាំងអស់ឲ្យមកកាន់ប្រទេសកម្ពុជា ដើម្បីចូលរួមធ្វើស្រែចម្ការ និងកសាងបដិវត្តន៍ជាមួយខ្មែរក្រហម។ ដោយសារខ្ញុំធ្លាប់មានបទពិសោធន៍បម្រើជាទាហានរបស់ធីវគីនៅវៀតណាម ខ្ញុំបានស្ម័គ្រចិត្តចូលធ្វើកងទ័ពខ្មែរក្រហមប្រឆាំងនឹងវៀតណាម បន្ទាប់ពីបានមកស្នាក់នៅក្នុងប្រទេសកម្ពុជាត្រឹមតែរយៈពេលជាងពីរខែប៉ុណ្ណោះ។

ខ្ញុំបានវិលត្រឡប់ទៅកាន់ទឹកដីកម្ពុជាក្រោមវិញ ដើម្បីប្រយុទ្ធជាមួយកងកម្លាំងវៀតណាម តាមទិសដៅកំណត់របស់កងទ័ពខ្មែរក្រហមនៅលើភ្នំមួយចំនួនដែលស្ថិតនៅក្នុងប្រទេសវៀតណាម។ ក្រោយពីវិលត្រឡប់ពីសមរភូមិវិញ កងទ័ពវៀតណាមបានវាយចូលមកប្រទេសកម្ពុជាដើម្បីផ្តួលរំលំរបបខ្មែរក្រហម។ ខ្ញុំបានដោះសម្លៀកបំពាក់យោធាខ្មែរក្រហមចោល និងបាននាំប្រពន្ធកូនមកកាន់ស្រុកគិរីវង់ ខេត្តតាកែវ ដែលខ្ញុំកំពុងរស់នៅនាពេលបច្ចុប្បន្ននេះ។ ដំបូង ខ្ញុំគិតថា ខ្ញុំស្នាក់នៅទីនេះតែត្រឹមរយៈពេលខ្លីប៉ុណ្ណោះ ព្រោះខ្ញុំនិងក្រុមគ្រួសារចង់វិលត្រឡប់ទៅកាន់ស្រុកកំណើតវិញ។ ប៉ុន្តែបន្ទាប់ពីរស់នៅអស់រយៈពេលប៉ុន្មានឆ្នាំក្រោយមក ខ្ញុំក៏សម្រេចចិត្តឈប់វិលត្រឡប់ទៅរស់នៅឯស្រុកកំណើតវិញ ហើយបន្តរស់នៅក្នុងភូមិព្រៃតាម៉ៅរហូតមកដល់បច្ចុប្បន្ន។ សព្វថ្ងៃ ខ្ញុំមិនប្រកបរបរអ្វីឡើយ ក្រៅពីដាក់ចិត្តដាក់កាយធ្វើបុណ្យ ថែរក្សាវត្តអារាម និងសុំសីលទាន។

ទាក់ទងនឹងប្រវត្តិចូលរួមធ្វើសង្គ្រាមរបស់ខ្ញុំគឺ ខ្ញុំធំដឹងក្តីឡើងនៅក្នុងទឹកដីវៀតណាម (កម្ពុជាក្រោម)។ ខ្ញុំចេះនិយាយភាសាវៀតណាម និងភាសាខ្មែរច្បាស់លាស់។ ខ្ញុំចេះអាននិងសរសេរអក្សរខ្មែរ ដោយសារខ្ញុំបានចូលរៀនជាមួយព្រះសង្ឃនៅវត្តខ្មែរមួយក្នុងទឹកដីវៀតណាម។ ដោយសារកើតមានសង្គ្រាមជាហូរហែនៅក្នុងប្រទេសវៀតណាមរវាង

វៀតណាមខាងជើង និងវៀតណាមខាងត្បូង ធ្វើឲ្យការរស់នៅរបស់ខ្ញុំពិបាកខ្លាំងណាស់។ ក្មេងជំទង់ៗដូចខ្ញុំ ត្រូវកំណែនឲ្យធ្វើទាហានវៀតណាម ដើម្បីចូលរួមប្រយុទ្ធប្រឆាំងជាមួយកងទ័ពវៀតណាមខាងជើង (ហាណូយ)។ ខ្ញុំខ្លាចកំណែនទាហាននេះណាស់។ ខ្ញុំបានឈប់រៀន និងបានរត់មកកាន់ប្រទេសកម្ពុជា។

នៅកម្ពុជា ខ្ញុំបានមកស្នាក់នៅផ្ទះពូរបស់ខ្ញុំស្ថិតនៅក្នុងឃុំភ្នំដិនមួយរយៈពេលខ្លីប៉ុណ្ណោះ មុននឹងខ្ញុំត្រូវបានបញ្ចុះបញ្ចូលឲ្យចូលធ្វើជាទាហាន លន់ នល់។ ខ្ញុំមិនចាំឆ្នាំដែលខ្ញុំចូលទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថារបប លន់ នល់ បានកាន់កាប់ប្រទេសហើយ។ ខ្ញុំធ្វើទាហាន លន់ នល់ បានប្រហែលមួយឆ្នាំ ក៏សម្រេចចិត្តវិលត្រឡប់ទៅកាន់ស្រុកកំណើតនៅកម្ពុជាក្រោមវិញ ព្រោះខ្ញុំឮដំណឹងថា ស្ថានភាពនៅទីនោះប្រក្រតីឡើងវិញហើយ។

ទៅដល់ស្រុកកំណើតនៅកម្ពុជាក្រោម ខ្ញុំបានរៀបការប្រពន្ធ។ នៅពេលដែលខ្ញុំមានកូនពីរនាក់ទៅហើយ ស្ថានភាពស្រុកទេសហាក់ដូចជាវិលត្រឡប់ទៅរកស្ថានការណ៍ចលាចលដូចកាលពីប៉ុន្មានឆ្នាំមុនវិញ។ លើកនេះ ខ្ញុំមិនសម្រេចចិត្តរត់មកប្រទេសកម្ពុជាជាលើកទីពីរទេ ព្រោះខ្ញុំមានប្រពន្ធនឹងកូនហើយ។ ខ្ញុំទ្រាំរស់នៅទាំងភិតភ័យនៅស្រុកកំណើតឯកម្ពុជាក្រោម។ ដោយមិនអាចគេចផុតពីកំណែនទាហានបាន ខ្ញុំបានសម្រេចចិត្តចូលបម្រើជាកងទ័ពរបស់វៀតណាម។ ខ្ញុំត្រូវបានទាហានវៀតណាមឲ្យជ្រើសរើសកងពលដែលខ្ញុំពេញចិត្ត។ ខ្ញុំបានជ្រើសរើសកងពល «ស៊ីដង់បៃ» មានការតព្វកិច្ចវាយប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាមខាងជើង (ហាណូយ) នៅចម្ងាយប្រហែល៣០គីឡូម៉ែត្រពីស្រុកកំណើតខ្ញុំ។ ខ្ញុំស្ថិតនៅក្នុងកងកាំភ្លើងធំ និងនៅជានីរសារផ្ទាល់ជាមួយប្រធានកងពល។ ខ្ញុំស្លៀកសម្លៀកបំពាក់ត្រេអ៊ី មានស្លាកសញ្ញារូបផ្ទ្រើយ៍ និងលេខ៧។ ខ្ញុំបានចូលប្រយុទ្ធច្រើនសមរភូមិណាស់ មុននឹងខ្ញុំលួចរត់ត្រឡប់មកកាន់ស្រុកកំណើតជួបប្រពន្ធ និងកូនវិញ។ ខ្ញុំនៅបម្រើការនៅក្នុងកងពល ស៊ីដង់បៃ អស់រយៈពេលជាងមួយឆ្នាំ។

នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានខ្មែរក្រហមកៀរឲ្យមកកាន់ប្រទេសកម្ពុជា ដើម្បីចូលរួមកសាងប្រទេស។ មុនដំបូង ខ្ញុំបានដឹងថាកងទ័ពវៀតណាមនៅតាមព្រំដែនដកថយចូលទៅក្នុងប្រទេសរបស់ខ្លួនវិញហើយ។ បន្ទាប់មក ខ្ញុំឃើញមានវត្តមានកងទ័ពខ្មែរក្រហមចូលលុកលុយពេញស្រុកកំណើតរបស់ខ្ញុំ ហើយប្រាប់ឲ្យប្រជាជនទាំងអស់ធ្វើដំណើរទៅកាន់ប្រទេសកម្ពុជាវិញ។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងពីស្រុកកំណើតនៅកម្ពុជាក្រោម រហូតដល់ស្រុកគិរីវង់ ខេត្តតាកែវ។ ខ្ញុំបានស្នាក់នៅវត្តប្រើសអស់រយៈពេលជាងពីរខែ។

ក្រោយមក ដោយសារ ខ្ញុំនិងប្រពន្ធកូនមិនមានអ្វីហូបគ្រប់គ្រាន់ ទើបខ្ញុំសម្រេចចិត្តស្នើសុំចូលបម្រើជាកងទ័ពខ្មែរក្រហម។ បន្ទាប់ពីចូលកងទ័ពភ្លាម ខ្ញុំត្រូវចាត់តាំងឲ្យចេញទៅប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅក្នុងទឹកដីវៀតណាម។ ក្រុមខ្ញុំមានគ្នា ៦៩ នាក់។ យើងបានទៅដល់គោលដៅដំបូងនៅលើភ្នំពពាយ រួចបន្តទៅកាន់ទីតាំងបន្ទាប់គឺស្ថិតនៅខាងលិចបាជុក និងភ្នំអកយំ ក្នុងស្រុកស្វាយទង ខេត្តមាត់ជ្រូក។ នៅទីនោះ ក្រុមខ្ញុំចំនួន៦០នាក់បានដាក់ពង្រាយគ្នានៅលើភ្នំនោះនិងនៅតាមចង្កេះភ្នំ ដើម្បីការពារទឹកដីដែលយើងយកបាន។ ខ្ញុំ និងទាហានសេសសល់៨នាក់ទៀត បានចុះពីលើភ្នំអកយំ ធ្វើដំណើរឆ្ពោះមកកាន់មូលដ្ឋានទ័ពនៅក្នុងវត្តប្រើសវិញ ដើម្បីរាយការណ៍ពីលទ្ធផល និងស្នើសុំផែនការបន្ទាប់។ នៅពេលដែលពួកខ្ញុំមកដល់វត្តប្រើស ទើបដឹងថា កងកម្លាំងវៀតណាមបានវាយចូលមកដល់ទឹកដីខ្មែរ និងវាយបណ្តេញកងកម្លាំងខ្មែរក្រហមចេញអស់ហើយ។ ខ្ញុំបានដោះសម្លៀកបំពាក់កងទ័ពខ្មែរក្រហមចេញ រួចមកនាំប្រពន្ធកូនត្រឡប់មករស់នៅក្នុងភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ជាទីកន្លែងដែលខ្ញុំកំពុងរស់នៅសព្វថ្ងៃនេះ។

# ខ្ញុំរស់នៅវេទនាលំបាក ស្ទើរតែទ្រាំពុំបាន ក្នុងរបបខ្មែរក្រហម

សៀង កញ្ញា



ទូ ទិត្យ អាយុ៧៣ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ទូ ទិត្យ កើតនៅឆ្នាំ១៩៤៩ នៅកម្ពុជាក្រោម។ បច្ចុប្បន្នរស់នៅក្នុងភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ហាស់ ទូ ស្លាប់នៅឆ្នាំ១៩៩៤ និងម្ដាយឈ្មោះ ខៀវ ទាប ស្លាប់តាំងពីខ្ញុំមានអាយុ៨ឆ្នាំ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ គឺស្រី៤នាក់ និងប្រុស២នាក់។

កាលពីកុមារ ខ្ញុំបានចូលរៀនអក្សរខ្មែរនៅវត្តបានត្រឹមថ្នាក់ទី៣ ហើយក៏ឈប់រៀននៅអាយុ៨ឆ្នាំ។ បន្ទាប់មក នៅអាយុ១០ឆ្នាំ ខ្ញុំបានចូលរៀននៅសាលាវៀតណាម។ មូលហេតុដែលខ្ញុំរៀនភាសាវៀតណាម គឺដើម្បីងាយស្រួលក្នុងការទំនាក់ទំនងជាមួយជនជាតិវៀតណាមនៅទីនោះ។

នៅឆ្នាំ១៩៦៨ ខ្ញុំត្រូវបានធីវគី (វៀតណាមខាងត្បូង) ជ្រើសរើសឲ្យចូលធ្វើជាទាហាន។ ខ្ញុំបានហ្វឹកហាត់ និងរៀនបាញ់កាំភ្លើងរយៈពេល៣ខែ បន្ទាប់មកក៏ចេញទៅច្បាំងជាមួយកងទ័ពវៀតកុង (វៀតណាមខាងជើង)។ នៅក្នុងឆ្នាំ១៩៧៥ នៅប្រទេសវៀតណាមស្ងប់ស្ងាត់សង្គ្រាម ហើយខ្ញុំក៏វិលត្រឡប់មកផ្ទះធ្វើស្រែចម្ការនៅផ្ទះវិញ។

នៅឆ្នាំ១៩៧៨ ខ្ញុំនិងគ្រួសាររួមទាំងប្រជាជនខ្មែរក្រោមមួយចំនួនទៀតដែលរស់នៅតាមទល់ដែនវៀតណាម-កម្ពុជា ត្រូវបានខ្មែរក្រហមកៀរត្រឡប់មកប្រទេសកម្ពុជាវិញ។ ខ្មែរក្រហមបានកៀរខ្ញុំ និងគ្រួសារមកដាក់នៅឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ។ នៅពេលនោះ ខ្ញុំបានរៀបការរួចហើយ ព្រមទាំងមានកូន២នាក់។ ខ្មែរក្រហមបានចាត់តាំងខ្ញុំពេលព្រឹកឲ្យធ្វើស្រែចម្ការ និងដាំដំណាំ ហើយពេលរសៀលឃ្វាលគោ។ ចំណែកប្រពន្ធរបស់ខ្ញុំធ្វើការងារដកស្ទូង ដោយទុកកូន២នាក់នៅផ្ទះ។ ចំពោះការហូបចុករបស់ខ្ញុំមិនបានគ្រប់គ្រាន់ឡើយ គឺទទួលបានអង្ករតែមួយកំប៉ុងប៉ុណ្ណោះក្នុងមួយថ្ងៃ។

នៅដើមឆ្នាំ១៩៧៩ ខ្មែរក្រហមបានកៀរខ្ញុំនិងគ្រួសារទៅភ្នំនារាយណ៍ ដោយខ្មែរក្រហមនិយាយថា «ឡើងទៅលើភ្នំទៅ»។ ខ្ញុំខំប្រឹងរែកអង្ករផង រែកកូនផង រត់ចាកចេញពីភូមិអស់រយៈពេល៤ថ្ងៃ ទើបកងទ័ពស្ម័គ្រចិត្តវៀតណាមចូលមករំដោះប្រជាជនខ្មែរចេញពីរបប ប៉ុល ពត។ នៅពេលខ្ញុំដើរត្រឡប់មកផ្ទះវិញ ខ្ញុំប្រទះឃើញសាកសពមនុស្សជាច្រើននៅតាមផ្លូវ។ ខ្ញុំនិងគ្រួសារបានមកដល់ឃុំគិរីចុងកោះ ស្រុកគិរីវង់ ហើយបានតាំងទីលំនៅទីនេះរហូតមកដល់សព្វថ្ងៃ។ ខ្ញុំរស់នៅក្នុងរបបខ្មែរក្រហមត្រឹមតែរយៈពេល៨ខែប៉ុណ្ណោះ ប៉ុន្តែខ្ញុំជួបការលំបាកស្ទើរតែទ្រាំពុំបាន ដោយខ្ញុំត្រូវធ្វើការងារហួសកម្លាំង មិនមានអាហារហូបចុកគ្រប់គ្រាន់ និងរស់នៅក្នុងភាពភ័យខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោល។

# មាស ផាត ៖ កម្មករស្រែអំបិលកែប និងកំពត

**រឹម ស្រីស្រស់**



មាស ផាត អាយុ៦៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ មាស ផាត អាយុ៦៧ឆ្នាំ ប្រកបរបរធ្វើស្រែចម្ការ មានស្រុកកំណើតនៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឃុំនេះដដែល។ ខ្ញុំមានឪពុកឈ្មោះ ម៉ៅ វ៉ង់ និងម្តាយឈ្មោះ គន់ សុន និងមានបងប្អូន៨នាក់ (ស្រី៥នាក់) ហើយខ្ញុំគឺជាកូនទី៣ក្នុងគ្រួសារ។ បងប្អូនរបស់ខ្ញុំស្លាប់អស់៣នាក់។

ខ្ញុំរៀនត្រឹមថ្នាក់ទី១០ពីសង្គមចាស់នៅសាលាភូមិដើមបេង រួចក៏ឈប់រៀន ដើម្បីមកជួយធ្វើស្រែឪពុកម្តាយ និងជួយមើលថែប្អូន។ ឪពុកខ្ញុំគឺជាអ្នកឡើងត្នោត ហើយម្តាយរបស់ខ្ញុំធ្វើស្រែចម្ការ។ ក្រោយមកឪពុកខ្ញុំបានធ្លាក់ពីលើដើមត្នោត បណ្តាលឲ្យពិការធ្វើការងាររអ៊ីមិនបាន។ ម្តាយរបស់ខ្ញុំបានខិតខំរកស៊ីចិញ្ចឹមកូនទាំងអស់នាពេលនោះ។

នៅឆ្នាំ១៩៧០ មានព្រឹត្តិការណ៍ទម្លាក់គ្រាប់បែកនៅតាមជួរភ្នំក្បែរផ្ទះរបស់ខ្ញុំ។ ខ្ញុំនិងអ្នកភូមិដទៃទៀតរស់នៅមិនសូប់សុខឡើយ។ គ្រួសារខ្លះបានរត់គេចពីការទម្លាក់គ្រាប់បែកនេះ និងមិនដែលឃើញវិលត្រឡប់មកស្រុកកំណើតវិញ។ ប្រជាជនខ្លះទៀតនៅសម្ងំលាក់ខ្លួននៅក្នុងត្រង់សេក្បែរផ្ទះ នៅពេលមានការទម្លាក់គ្រាប់បែកម្តងៗ។ ខ្ញុំមិនរត់គេចទៅណាទេ គឺ ស៊ូទ្រាំរស់នៅក្នុងស្រុកកំណើតរហូតដល់ឆ្នាំ១៩៧៥។

នៅពេលរបបខ្មែរក្រហមឡើងកាន់កាប់អំណាច ខ្ញុំព្រមទាំងគ្រួសារត្រូវខ្មែរក្រហមជម្លៀសឲ្យទៅនៅភូមិភ្នំត្នោត ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត។ នៅទីនោះ ខ្មែរក្រហមបានប្រើខ្ញុំឲ្យជីកប្រឡាយ កាប់ព្រៃដាំដំឡូង និងដាំពោត។ បន្ទាប់មកទៀត ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យមកនៅភូមិខ្វាវ ឃុំតាអូរ ស្រុកគិរីវង់វិញ និងចាត់តាំងខ្ញុំឲ្យធ្វើស្រែជាមួយសហករណ៍នៅទីនោះ។ ខ្ញុំត្រូវមកហូបរួមនៅរោងបាយ ប៉ុន្តែហូបមិនបានគ្រប់គ្រាន់ឡើយ។ ខ្ញុំមិនមានអំបិលហូបទេ ពេលខ្លះខ្ញុំយកដីដំបូកមកស្ងោររម្ងាស់ ហើយយកទឹកដែលបានពីការស្ងោររម្ងាស់នេះទៅស្លហូប។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវខ្មែរក្រហមជម្លៀសម្តងទៀតឲ្យទៅនៅអង្គភាពស្រែអំបិល។ លើកនេះ ខ្ញុំទៅតែម្នាក់ឯង ចោលម្តាយរបស់ខ្ញុំនៅភូមិ។ អង្គភាពនេះមានមនុស្សបីពាន់នាក់សុទ្ធតែស្រីទាំងអស់។ នៅរដូវប្រាំង ខ្ញុំនិងអ្នកឯទៀតនៅក្នុងអង្គភាពធ្វើស្រែអំបិល។ ដល់រដូវវស្សា ខ្ញុំប្តូរទៅធ្វើចម្ការ គឺ ដាំពោត និងដាំដំឡូង។ ខ្ញុំធ្វើជាកម្មករស្រែអំបិលនៅកែបបានរយៈពេល១ឆ្នាំ ក៏ប្តូរទៅធ្វើនៅអង្គភាពស្រែអំបិលខេត្តកំពតវិញ។ នៅឆ្នាំ១៩៧៩ ខ្ញុំនិងអ្នកធ្វើការនៅក្នុងអង្គភាពបានរត់ភៀសខ្លួនទៅកាន់ព្រំដែនថៃ កាត់តាម

ភ្នំឪរ៉ាល់ លាច និងកន្លែងច្រើនទៀតដែលខ្ញុំមិនស្គាល់។

នៅតាមផ្លូវ ខ្ញុំឃើញមនុស្សស្លាប់ច្រើននិងអាណោចអាធ័មបំផុត។ ខ្ញុំមិនមានបាយ ហូបទេ ដូច្នេះខ្ញុំនិងអ្នករួមដំណើរនាំគ្នាដើរជីកដំ ឡូងហាលទុកសម្រាប់ធ្វើស្បៀងពេលធ្វើដំណើរតាមផ្លូវ។ បន្ទាប់មកខ្ញុំជួបយោធាខ្មែរក្រហម ហើយយោធាទាំងនោះបាននាំខ្ញុំទៅកាន់ព្រំដែនថៃតាមផ្លូវសំឡូត។ ទៅដល់ព្រំដែន អន្តភាពរបស់ខ្ញុំនៅសល់មនុស្សតែពីរនាក់ប៉ុណ្ណោះ គឺខ្ញុំ និងមិត្តនារីម្នាក់ទៀត។ ចំណែកអ្នកដទៃទៀតបានស្លាប់តាមផ្លូវអស់ហើយ។ នៅព្រំដែន ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ពេលអ៊ុនតាក់ចូលមកប្រទេសកម្ពុជានៅឆ្នាំ១៩៩៣ ទើបខ្ញុំបានវិលត្រឡប់មកស្រុកកំណើតវិញ។ មកដល់ស្រុកកំណើត មេឃុំបានចែកដីឲ្យខ្ញុំធ្វើស្រែដើម្បីចិញ្ចឹមជីវិត។ ប៉ុន្តែខ្ញុំសោកស្តាយណាស់ដែលខ្ញុំមិនបានជួបមុខឪពុកម្តាយខ្ញុំ ព្រោះអ្នកទាំងពីរបានស្លាប់នៅឆ្នាំ១៩៧៩ ដោយសារជំងឺអស់ហើយ។



មាស ផាត ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ រឹម ស្រីស្រស់ អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ សម្ភាសន៍ មាស ផាត អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម នៅផ្ទះរបស់គាត់ស្ថិតនៅក្នុងភូមិដើមប៉េង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រជាជន មន្ត្រីមូលដ្ឋានឃុំ និងសិស្សានុសិស្ស មកទស្សនាពិព័រណ៍រូបថតអចិន្ត្រៃយ៍

## និងឈ្វេងយល់ពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ

ផេង ពង្សរ៉ាស៊ី





ប្រជាជន មន្ត្រីមូលដ្ឋានឃុំ និងសិស្សានុសិស្ស មកទស្សនាពិព័រណ៍រូបថតអចិន្ត្រៃយ៍ និងឈ្វេងយល់ពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅខែមករា ឆ្នាំ២០២៣នេះ មានភ្ញៀវប្រុសស្រីចំនួន៥៧ នាក់បានមកទស្សនាពិព័រណ៍រូបថតអចិន្ត្រៃយ៍ និងឈ្វេងយល់ពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ ភ្ញៀវទាំងនោះរួមមានគ្រូបង្រៀន និងយុវជនវ័យក្មេងដែលជាសិស្សានុសិស្សនៅវិទ្យាល័យ ហ៊ុន សែន កោះអណ្តែត ចំនួន៣៥នាក់ និងប្រជាពលរដ្ឋដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន២២នាក់។

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវបានបង្ហាញពីផ្ទាំងពិព័រណ៍នីមួយៗដល់សិស្សានុសិស្ស និងសម្របសម្រួលដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងការដើរទស្សនាពិព័រណ៍រូបថតទាំងអស់។ សម្រាប់យុវជនដែលមានអាយុទើបតែ១៧ ឬ១៨ឆ្នាំ អ្នកទាំងនោះបានបង្ហាញពីការចាប់អារម្មណ៍ខ្លាំងលើផ្ទាំងរូបថតបង្ហាញអំពី «ប៉ុល ពត និង បក្សពួក» និង «តាម៉ុក»។ យុវជនទាំងអស់សុទ្ធតែបានដឹងថា តាម៉ុក គឺជាប្រធានភូមិភាគនិរតី ដែលមានកំណើតនៅក្នុងខេត្តតាកែវ។ អ្នកទាំងនោះគិតថា តាម៉ុក គឺជាអ្នកខេត្តតែមួយជាមួយនឹងខ្លួន។ ម្នាក់ៗបានបោមរោមមើលផ្ទាំងពិព័រណ៍ «តាម៉ុក» ដោយស្ងៀមស្ងាត់ និងយកចិត្តទុកដាក់។ នៅពីមុខផ្ទាំងពិព័រណ៍ «ប៉ុល ពត និងបក្សពួក» យុវជនមួយចំនួនបានសួរនាំអំពីបណ្តុំរូបថតតូចៗជាច្រើនសន្លឹកដែលមាននៅលើផ្ទាំងពិព័រណ៍ធំនេះ។ អ្នកខ្លះកត់ត្រា អ្នកខ្លះ

ប្រាប់គ្នីគ្នាអំពីរូបថត និងអ្នកខ្លះឈោងទៅជិតផ្ទាំងពិព័រណ៌ ដើម្បីអានចំណងជើងរូបថត។

ចំណែកឯអ្នកភូមិចំនួន២១នាក់វិញ ហាក់បង្ហាញការចាប់អារម្មណ៍ខ្លាំងតែចំពោះផ្ទាំងពិព័រណ៌ «តាម៉ុក» និងបានជជែកគ្នាពុៗពីខ្សែជីវិតរបស់ តាម៉ុក។ ដោយសារអ្នកទាំងនោះ មានស្រុកកំណើតជាមួយ តាម៉ុក និងស្គាល់ តាម៉ុក គ្រប់ៗគ្នាផងនោះ ពួកគាត់បានជជែកគ្នាច្រើនពីតាម៉ុក។ សមាជិកក្រុមប្រឹក្សាឃុំលាយបូរ ស្រុកត្រាំកក់ ឈ្មោះ ជា សុខុនបានចូលមកកាន់បរិវេណមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដើម្បីទស្សនាពិព័រណ៌រូបថត។ គាត់បានចាប់អារម្មណ៍ខ្លាំងពីផ្ទាំងពិព័រណ៌រូបថត «តាម៉ុក» និង ផ្ទាំងពិព័រណ៌ស្ពានជ្រោយចង្វារដែលបាក់ស្រុតចូលក្នុងទន្លេកាលពីឆ្នាំ១៩៧៤។

សុខុន បានប្រាប់ថា គាត់ធ្លាប់ធ្វើការជាមួយ តាម៉ុក មួយរយៈពេលខ្លីដែរ ប៉ុន្តែមិនស្គាល់ពីប្រវត្តិរបស់តាម៉ុកច្បាស់លាស់។ សុខុនបានស្នើសុំឯកសារដែលទាក់ទងនឹងប្រវត្តិរបស់ តាម៉ុក។ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវបានប្រគល់សៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ», «បូជាភ្លើង», «ទស្សនាវដ្តីស្វែងរកការពិត» និង ឯកសារមួយចំនួនទៀត ដល់គាត់ដើម្បីអាន និងទុកជាឯកសារ។

មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បើកដំណើរការរៀងរាល់ថ្ងៃចន្ទដល់ថ្ងៃសុក្រ ព្រឹកពីម៉ោង៧កន្លះដល់ម៉ោង១២ និងរសៀលពីម៉ោង១កន្លះ ដល់ម៉ោង៥ល្ងាច ដើម្បីទទួលភ្ញៀវចូលទស្សនា និងស្រាវជ្រាវឯកសារប្រវត្តិសាស្ត្រខ្មែរក្រហម ជាច្រើនដែលមានតម្កល់នៅក្នុងការិយាល័យនេះ។ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ នឹងចាប់ផ្តើមចាក់បញ្ចាំងខ្សែភាពយន្តឯកសារប្រវត្តិសាស្ត្រ ទាក់ទងនឹងរបបខ្មែរក្រហម ចាប់ពីខែកុម្ភៈ ឆ្នាំ២០២៣ តទៅ។







ប្រជាជន មន្ត្រីមូលដ្ឋានឃុំ និងសិស្សានុសិស្សមកទស្សនាពិព័រណ៌រូបថតអចិន្ត្រៃយ៍ និងឈ្វេងយល់ពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យុវជនស្រុកបាទី ខេត្តតាកែវ ផ្ដល់ក្ដីគោរពដ៏ជ្រាលជ្រៅ ដល់អ្នកស្លាប់ពីរបបខ្មែរក្រហម

ផេង ពង្សរ៉ាស៊ី






នៅព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនស្ដីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដោយមានសិស្សានុសិស្សចំនួន៣០នាក់ មកពីវិទ្យាល័យ ហ៊ុន សែនបាទី ចូលរួម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ មានយុវជនក្មេងៗក្រោមអាយុ១៨ឆ្នាំដែលត្រូវជាចៅ ចៅទួតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣០នាក់ បានផ្ដល់ក្ដីគោរពដ៏ជ្រាលជ្រៅដល់វិញ្ញាណក្ខ័ន្ធអ្នកស្លាប់ក្នុងរបបខ្មែរក្រហម នៅពីមុខមន្ទីរបូជនីយដ្ឋានវត្តសុរភី ហៅវត្តកកោះ ស្ថិតនៅក្នុងស្រុកបាទី ខេត្តតាកែវ។ អង្គុយបត់ជើងនៅពីមុខលលាដ៏ក្បាលសាកសពរាប់ពាន់ដែលដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានវត្តសុរភី យុវជនម្នាក់ៗកាន់ធូបមួយសរសៃលើកដៃសំពះ ភ្នែកសម្លឹងទៅរកលលាដ៏ក្បាលទាំងនោះដោយស្ងៀមស្ងាត់ ជាមួយនឹងទឹកមុខស្រពាប់ស្រពោន និង សញ្ជឹងគិត។

ការផ្ដល់នូវសេចក្ដីគោរពនេះ កើតឡើងបន្ទាប់ពីយុវជនទាំងនោះបានចូលរួមស្ដាប់ការធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅក្នុងកម្មវិធីវេទិកាថ្នាក់រៀនមួយ រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវកាលពីវេលាព្រឹកថ្ងៃទី១៥ខែកុម្ភៈឆ្នាំ២០២៣។ តាមរយៈការស្នើសុំរបស់លោកនាយកវិទ្យាល័យហ៊ុន សែនបាទី ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បាននាំក្រុមយុវជនទាំងអស់មកកាន់ទីតាំង







នៅព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដោយមានសិស្សានុសិស្សចំនួន៣០នាក់ មកពីវិទ្យាល័យ ហ៊ុន សែនបាទី ចូលរួម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តម្កល់អដ្ឋិធាតុវត្តសុរភី ហៅ វត្តកកោះ ដើម្បីបង្ហាញពីភស្តុតាងជាក់ស្តែង ទាក់ទងនឹងការបាត់បង់ជីវិតមនុស្សជាងមួយម៉ឺននាក់ដ៏អយុត្តិធម៌ ក្រោមការដឹកនាំរបស់ខ្មែរក្រហម។

នៅឆ្នាំ២០០០ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាត់ឲ្យក្រុមស្រាវជ្រាវ ទាក់ទងនឹងការធ្វើផែនទីរណ្តៅសាកសព និងមន្ទីរសន្តិសុខរបស់ខ្មែរក្រហម មកធ្វើការស្រាវជ្រាវទីតាំងផ្ទុកសាកសពនៅវត្តសុរភីនេះ។ ក្រុមស្រាវជ្រាវបានជួបសម្ភាសន៍អ្នករស់រានមានជីវិតមួយចំនួន រួមទាំងព្រះសង្ឃគង់ចាំព្រះវស្សានៅក្នុងវត្តសុរភីផង ដើម្បីសួរនាំពីចំនួន និងមូលហេតុដែលនាំឲ្យការប្រើប្រាស់បរិវេណវត្តធ្វើជាទីតាំងផ្ទុកសាកសពអ្នកជម្លៀសនៅក្នុងខែមេសាឆ្នាំ១៩៧៥។ លទ្ធផលនៃការស្រាវជ្រាវបង្ហាញថា ប្រជាជនដែលត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញរាប់ម៉ឺននាក់ ត្រូវបានសម្លាប់នៅក្នុងស្រះទឹកមួយចំនួនដែលមានទំហំ៥០ម៉ែត្របួនជ្រុង និងជម្រៅប្រហែល៤ម៉ែត្រ ស្ថិតនៅជុំវិញវត្តសុរភី។ លោក ប៊ុន ហ៊ីង គឺជាអនិកជនរស់នៅសហរដ្ឋអាមេរិក បានធ្វើរបាយការណ៍ជាភាសាអង់គ្លេសចំនួនពីរទំព័រ ផ្ញើតាមប្រព័ន្ធអ៊ីម៉ែលកាលពីឆ្នាំ២០០០ មកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាថា ចាប់តាំងពីថ្ងៃទី១៨ដល់២៥ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនភាគច្រើនដែលបានជម្លៀសចេញពីទីក្រុងភ្នំពេញ ត្រូវខ្មែរក្រហមបង្ខំឲ្យចូលមកកាន់បរិវេណវត្តសុរភី បន្ទាប់មកអ្នកទាំងនោះត្រូវបានសម្លាប់ចោលទាំងអស់។ បើតាម ប៊ុន ហ៊ីង ឈ្មោះ អ៊ុយ គឺជាមេបញ្ជាការរងភូមិភាគនិរតី គឺជាអ្នកសម្លាប់មនុស្សច្រើនជាងគេ។ ក្រៅពីសាកសពដែលត្រូវបានសម្លាប់ នៅមានសាកសពជាច្រើននាក់ទៀតគឺជាសាកសពមនុស្សចាស់ក្មេងប្រុសស្រីដែលបានស្លាប់ដោយសារការជម្លៀសនៅតាមចិញ្ចើមថ្នល់ ហើយត្រូវសែងមកដាក់នៅក្នុងស្រះទឹកទាំងនោះដែរ។ មានសាក្សីពីរនាក់ទៀតគឺ ទឹម គុន និង មុយ ចក់ បានប្រាប់ឲ្យដឹងថា ខ្មែរក្រហមបានបន្តសម្លាប់មនុស្សដាក់នៅក្នុងស្រះទឹកនេះរហូតដល់ចុងឆ្នាំ១៩៧៨។

តាមរយៈការសាកសួរពីអារម្មណ៍ និងទឹកចិត្តរបស់យុវជនក្នុងពេលដែលអ្នកទាំងនោះ បាននិងកំពុងស្ថិតនៅក្នុងបរិវេណជាអតីតកន្លែងសម្លាប់

មនុស្ស និងផ្ទុកសាកសពមនុស្សកាលពីរបបខ្មែរក្រហម បានឲ្យដឹងថា ក្មេងៗទាំងនោះពេញចិត្តនឹងជីវិតនាពេលបច្ចុប្បន្នរបស់ខ្លួន ហើយក៏មិនភ្លេចដែរពីរឿងរ៉ាវដែលបានកើតឡើងពីអតីតកាលក្នុងរបបខ្មែរក្រហម ជាពិសេសការស្លាប់បាត់បង់ជីវិតរបស់ប្រជាជនកម្ពុជាអស់រាប់លាននាក់។ ចម្លើយភាគច្រើនរបស់យុវជនបង្ហាញពីអារម្មណ៍គិតគូរដល់ជាតិខាងមុខរបស់អ្នកស្លាប់ សោកស្តាយពីបទពិសោធន៍អាក្រក់ៗដែលបានកើតឡើង និងបានសម្តែងចិត្តអាណិតអាសូរដល់អ្នកស្លាប់ទាំងអស់។ លើសពីនេះទៀត ក្មេងៗជំនាន់ក្រោយ នៅតែចាត់ទុកព្រលឹងអ្នកដែលបានស្លាប់ទៅថា ជាវត្ថុសក្តិសិទ្ធិដែលអាចជួយឲ្យអ្នកទាំងនោះបានសេចក្តីសុខ និងចម្រុងចម្រើន។

សិស្ស លួត ស្រីយី អាយុ១៧ឆ្នាំ បានបង្ហាញពីអារម្មណ៍របស់ខ្លួនក្នុងពេលដែលកំពុងកាន់ធូបឧទ្ទិសដល់វិញ្ញាណសាកសព ដោយនិយាយដូច្នេះថា «ខ្ញុំគិតថា ខ្ញុំឥឡូវនេះរស់នៅបានសុខស្រួលណាស់ ប៉ុន្តែបើក្រឡេកមើល និងរំពុកដល់អ្នកដែលស្លាប់ក្នុងរបបខ្មែរក្រហមវិញ គឺថាពួកគាត់វេទនាណាស់ ហើយការស្លាប់របស់ពួកគាត់ទៀតគឺគ្មានបានយុត្តិធម៌ និងគ្មានការធ្វើបុណ្យតាមប្រពៃណីទេ។ ខ្ញុំបានបួងសួងដល់ព្រលឹងគាត់ឲ្យបានចាប់ជាតិណាៗ កុំឲ្យដូចពេលដែលគាត់រស់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំក៏សូមឲ្យរូបខ្ញុំ និងគ្រួសារបានសុខសប្បាយរហូតទៅ កុំឲ្យជួបប្រទះដូចរបបខ្មែរក្រហមទៀត»។

ចំណែកយុវជន សុខ ប៊ុនលាភ វិញនិយាយថា «ខ្ញុំបិទភ្នែកគិតដល់គាត់! តើគាត់ពិបាកយ៉ាងណា? ខ្ញុំសូមបួងសួងឲ្យវិញ្ញាណក្ខន្ធគាត់កើតជាតិណាៗឲ្យបានសុខសប្បាយរហូត។ ខ្ញុំក៏បួងសួងដែរថា សុំឲ្យព្រលឹងគាត់ជួយថែរក្សាខ្ញុំ និងសូមឲ្យគាត់ជួយយើងទាំងអស់គ្នាឲ្យសុខសប្បាយរហូតទៅ»។

ផា និត ក៏ជាយុវជនម្នាក់ទៀតនៃវិទ្យាល័យហ៊ុន សែន បាទី ដែរ បាននិយាយស្រដៀងគ្នានឹងស្រីយី ដែរថា «ខ្ញុំអាណិតពួកគាត់ ព្រោះពួកគាត់ស្លាប់ដោយអយុត្តិធម៌ ហើយមិនបានធ្វើបុណ្យតាមប្រពៃណីទៀត»។

ដោយឡែក ម៉ា ណែត វិញនិយាយថា «ខ្ញុំអុជធូបអម្បាញ់មិញនេះ គឺបួងសួងសូមសេចក្តីសុខដល់ខ្ញុំក្នុងជាតិនេះ ហើយខ្ញុំក៏រំពុកឡើងវិញពីជីវិតរបស់អ្នកដែលបានស្លាប់នៅតាមដងផ្លូវក្នុងពេលដែលគាត់ត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុង។ អ៊ីចឹង! ខ្ញុំគិតដល់ពួកគាត់ថា សូមឲ្យគាត់ចាប់ជាតិខាងមុខសូមឲ្យជៀសផុតពីសេចក្តីទុក្ខលំបាក ទុក្ខវេទនាដែលបានជួបប្រទះក្នុងរបបខ្មែរក្រហម ហើយក៏សង្ឃឹមថា អ្វីដែលខ្ញុំបានបន់ស្រន់នេះ ប្រសិនជាអាចឧទ្ទិសដល់វិញ្ញាណក្ខន្ធពួកគាត់បាន ខ្ញុំសូមឲ្យគាត់បានដល់សុគតិភព និងសូមបួងសួងឲ្យជីវិតខ្ញុំនាពេលនេះបានសុខចម្រើនតទៅ»។

ប៉េង សុង បាននិយាយថា «ខ្ញុំបានបួងសួងថា សូមឲ្យព្រលឹងពួកគាត់កើតជាតិណាៗ សូមឲ្យបានសុខ កុំឲ្យអភ័ព្វដូចជាតិមុន និងសូមឲ្យពួកខ្ញុំទាំងអស់គ្នាមានសុភមង្គល និងមានសេចក្តីសុខ»។



នៅព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដោយមានសិស្សានុសិស្សចំនួន៣០នាក់ មកពីវិទ្យាល័យហ៊ុន សែន បាទី ចូលរួម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សានុសិស្សមកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍

## ក្រោមប្រធានបទ៖ តើខ្មែរក្រហមជានរណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?

*ភា រស្មី*





សិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ក្រោមប្រធានបទ៖ តើខ្មែរក្រហមជានរណា? រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រសិនបើត្រឡប់ទៅមើលអតីតកាល កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាថ្ងៃដែល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ហើយប្រទេសចាប់ផ្តើមមានសង្គ្រាម។ ការធ្វើរដ្ឋប្រហាររបស់លោកសេនាប្រមុខ លន់ នល់ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ និងការអំពាវនាវរបស់សម្តេចព្រះ នរោត្តម សីហនុ ឲ្យប្រជាជនចូលព្រៃម៉ាគីប្រឆាំងនឹងរបប លន់ នល់ បានធ្វើឲ្យខ្មែរក្រហមក្តោបយកឱកាសឡើងកាន់អំណាចយ៉ាងឆាប់រហ័ស។ បើរាប់ពីឆ្នាំ១៩៧០ មកទល់នឹងបច្ចុប្បន្ននេះគឺមានរយៈពេល៥៣ឆ្នាំមកហើយ។

គ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យានៅវិទ្យាល័យ សុខ អាន ដូងខ្ពស់ បុរីជលសារ ឈ្មោះ ឌូ សុង បានប្រាប់ឲ្យដឹងថា មេរៀនប្រវត្តិសាស្ត្ររបបសាធារណរដ្ឋខ្មែរ ទើបត្រូវបានបញ្ចប់ការបង្រៀននៅពេលថ្មីៗនេះ ហើយគាត់កំពុងរៀបចំកិច្ចតែងការបង្រៀនសម្រាប់ការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងខែបន្ទាប់ទៀត។ សិស្សចំនួនបីនាក់គឺ ភោន ហ៊ុយ, សារី ស៊ីមា និង សារី យិស្មី បានប្រាប់ថា ខ្លួនបានដឹងថាមានរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ដោយសេនាប្រមុខ លន់



សិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ក្រោមប្រធានបទ៖ តើខ្មែរក្រហមជានរណា? រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។
(ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នល់ តាមរយៈគ្រូបង្រៀនៗ សិស្សទាំង៣នាក់បានបង្ហាញពីការចង់ចេះចង់ដឹងបន្ថែមថា ខ្លួនចង់ដឹងព្រឹត្តិការណ៍ជាច្រើនទៀតនាំដល់ការកកើតរបបខ្មែរក្រហម។ លោកគ្រូ ឌូ សុង បាននិយាយ ទាំងទឹកមុខរីករាយដូច្នេះ «ខ្ញុំសប្បាយរីករាយ ដែលសិស្សរបស់ខ្ញុំមានឱកាសបានមកចូលរួមធ្វើទស្សនកិច្ចសិក្សា និងចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្ញុំក៏កំពុងតែត្រៀមមេរៀនសម្រាប់ការបង្រៀនមេរៀននេះនៅខែក្រោយដែរ។ សិស្សរបស់ខ្ញុំនៅមិនទាន់មានចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមទេ។ ខ្ញុំសង្ឃឹមថា វេទិកានេះនឹងជួយសិស្សរបស់ខ្ញុំឲ្យទទួលបានចំណេះដឹងច្រើនពីប្រវត្តិសាស្ត្រខ្មែរក្រហម ជាពិសេសពីលោកគ្រូផ្ទាល់»។

នៅវេលាម៉ោងប្រមាណជា៨ព្រឹក ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តតាកែវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលស្វាគមន៍សិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់បូរីជលសារ ចំនួន២៤នាក់ ក្រោមការដឹកនាំពីគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាចំនួន២នាក់ ក្នុងដំណើរទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ និងចូលរួមក្នុងវេទិកាថ្នាក់រៀនចុងសប្តាហ៍។ សិស្សានុសិស្សបានចូលទស្សនាពិព័រណ៍រូបថតនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តតាកែវ អមជាមួយការពន្យល់បន្ថែមពី លោក ដេង ពង្សរ៉ាស៊ី គឺជានាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ដែលជាគ្រូឧទ្ទេស។

នៅវេលាម៉ោងប្រមាណជា៨:១៥នាទីព្រឹក សិស្សានុសិស្សបានចូលទៅបន្ទប់ថ្នាក់រៀន ដើម្បីចូលរួមវេទិកាពិភាក្សាលើប្រធានបទ«តើខ្មែរក្រហមជានរណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?»។ ដំបូង សិស្សានុសិស្សត្រូវបានណែនាំឲ្យបំពេញតារាងស្ទាបស្ទង់មតិដើម្បីវាស់ស្ទង់ចំណេះដឹងមុនពេលចាប់ផ្តើមវេទិកា។ បន្ទាប់មកទៀត គ្រូឧទ្ទេសចាប់ផ្តើមការពិភាក្សាពីប្រធានបទខាងលើ។ ដោយមូលហេតុប្រធានបទនេះ មានទម្រង់ជាសំណួរស្រាប់ គ្រូឧទ្ទេសបានសួរសំណួរទាំងនេះ

ទៅកាន់សិស្សតែម្តង ដើម្បីចង់ដឹងពីការឆ្លើយតបមកវិញចំពោះការយល់ដឹងលើប្រធានបទនេះ។ គ្រូខទ្ទេសសួរសំណួរទី១៖ តើខ្មែរក្រហមជានរណា? ទៅកាន់អ្នកចូលរួមៗ ពុំមានអ្នកចូលរួមណាម្នាក់ឆ្លើយសំណួរនេះបានទេ។ ប្រហែល៥នាទីក្រោយមក គ្រូខទ្ទេសបន្តសំណួរទី២៖ តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា? សំណួរនេះ ក៏គ្មានអ្នកឆ្លើយដែរ។

បន្ទាប់មក គ្រូខទ្ទេសបានចាប់ផ្តើមពន្យល់ពីការបង្កើតចលនាខ្មែរឥស្សរៈនៅក្នុងទសវត្សរ៍ឆ្នាំ១៩៤០, ការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរក្នុងឆ្នាំ១៩៥១, និងការផ្លាស់ប្តូរឈ្មោះបក្សជាបន្តបន្ទាប់ រហូតទាល់តែខ្មែរក្រហមអាចដណ្តើមកាន់កាប់ប្រទេសកម្ពុជាបាននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ក្នុងការពិភាក្សានេះ គ្រូខទ្ទេសបានពន្យល់យ៉ាងក្បោះក្បាយពីការរីកចម្រើនរបស់ក្រុមបដិវត្តន៍ដែលរស់នៅក្នុងព្រៃ ដោយមូលហេតុពីរយ៉ាងគឺ ទី១) ដោយសារមានព្រឹត្តិការណ៍ទម្លាក់គ្រាប់បែក និង ទី២) ដោយសារការគោរពស្រឡាញ់របស់ប្រជាជនទៅលើសម្តេចព្រះនរោត្តម សីហនុ។

នៅវេលាម៉ោងប្រមាណជា១១កន្លះព្រឹក វេទិកាថ្នាក់រៀនត្រូវបានបញ្ចប់ បន្ទាប់ពីគ្រូខទ្ទេសធ្វើបទបង្ហាញបន្ថែមពីនិយមន័យនៃអំពើប្រល័យពូជសាសន៍ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍រួចៗ នៅចុងបញ្ចប់នៃកម្មវិធីវេទិកាថ្នាក់រៀន គឺជាការវាស់ស្ទង់ចំណេះដឹងសិស្សក្រោយការទទួលបានចំណេះដឹងថ្មី និងការពិភាក្សាពីចម្ងល់ដែលមានៗ ក្រៅពីសំណួរទាក់ទងនឹងប្រធានបទ គ្រូខទ្ទេសបានផ្តល់ឱកាសឲ្យមានការសួរសំណួរដែលទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហមទាំងមូលដែរ។ សិស្សានុ-សិស្សចំនួន៦នាក់បានសួរសំណួរទៅកាន់គ្រូខទ្ទេសដែលសំណួរទាំងនោះទាក់ទងនឹងការកើតមាន និងការបញ្ចប់សង្គ្រាមស៊ីវិល, មូលហេតុនៃកាជ្រើសរើសយកសាឡុតស(ប៉ុលពត)ធ្វើជាលេខាបក្សជំនួស, ការស្លាប់របស់ ប៉ុល ពត, សុន សេន និង វន វ៉េត, និងការបណ្តេញជនជាតិវៀតណាមចេញពីប្រទេសកម្ពុជា។



មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដោយមានសិស្សានុសិស្សមកពីវិទ្យាល័យ សុខ អាន ដូងខ្ពស់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងពេលជាមួយគ្នានេះដែរ យុវសិស្សបីនាក់បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនបន្ទាប់ពីបានចូលរួមនៅក្នុងវេទិកាពិភាក្សានេះថា ខ្លួនបានរៀនសូត្រច្រើនគួរសមទាក់ទងនឹងព្រឹត្តិការណ៍រដ្ឋប្រហារការកើតមានសង្គ្រាមស៊ីវិល ការទម្លាក់គ្រាប់បែក ការកើតមានរបបខ្មែរក្រហមដែលនាំឲ្យមានការបិទសិទ្ធិសេរីភាពប្រជាជន និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍។ ខាងក្រោមនេះជាការលើកឡើងរបស់សិស្សទាំង៣នាក់៖

ភោន ហ៊ុយ ភេទប្រុសអាយុ១៧ឆ្នាំ៖«ក្រោយពីបានចូលរៀននៅព្រឹកនេះ ខ្ញុំបានដឹងអំពីរបបខ្មែរក្រហម ដូចជា ការធ្វើទារុណកម្ម ការបំបិទសិទ្ធិមនុស្ស ការហូបអាហារមិនគ្រប់គ្រាន់ ការធ្វើការងារធ្ងន់ៗរបស់ប្រជាជនជាពិសេសការធ្វើរដ្ឋប្រហារទម្លាក់ សម្តេចព្រះនរោត្តម សីហនុ និង វិធីសាស្ត្រការពារអំពើប្រល័យពូជសាសន៍»។

សារី ស៊ីម៉ា ភេទស្រី អាយុ១៩ឆ្នាំ៖ «បន្ទាប់ពីបានចូលរៀនក្នុងវេទិកាថ្នាក់រៀន ខ្ញុំបានដឹងថានៅក្នុងសម័យ លន់ នល់ មានការទម្លាក់គ្រាប់បែក ប្រជាជនបានជម្លៀសខ្លួនពីជនបទទៅទីក្រុង និងមានសង្គ្រាមស៊ីវិល។ បន្ថែមជាងនេះទៀត ខ្ញុំមានការយល់ដឹងកាន់តែច្បាស់អំពីការធ្វើរដ្ឋប្រហារ សម្តេចព្រះនរោត្តម







មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដោយមានសិស្សានុសិស្សមកពីវិទ្យាល័យ ស៊ុខ អាន ដូងខ្ពស់ ចូលរួម និងទស្សនកិច្ចសិក្សាទៅកាន់ចេតិយជាសំណង់សមូហភាពរបស់អ្នករស់រានមានជីវិតនៅក្នុងភូមិត្រពាំងស្វាយ ឃុំតាភេម និងអតីតមន្ទីរសន្តិសុខក្រាំងតាចាន់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សីហនុនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និងមូលហេតុដែលធ្វើឲ្យខ្មែរក្រហមទទួលបានជ័យជម្នះយ៉ាងឆាប់រហ័សនៅ ឆ្នាំ១៩៧៥។ ចំណែកនៅក្នុងសម័យខ្មែរក្រហម ខ្ញុំបានដឹងពីការជម្លៀសរបស់ប្រជាជន ការធ្វើការងារហួសកម្លាំង និងការសម្លាប់យ៉ាងឃោរឃៅទៅលើអ្នកចេះដឹង និងប្រជាជនទូទៅ»។

សារី យ៉ិស្មី ភេទស្រី អាយុ១៨ឆ្នាំ៖ «ខ្ញុំបានដឹងអំពីគោលនយោបាយរបស់ខ្មែរក្រហម និងការកាន់អំណាចរបស់ខ្មែរក្រហម ជាពិសេស ធ្វើឲ្យខ្ញុំដឹងពីវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត»។

នៅរសៀលថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ ដដែល សិស្សានុសិស្សទាំងអស់បានធ្វើដំណើរទៅកាន់ភូមិត្រពាំងស្វាយ ឃុំតាភេម ដើម្បីពិនិត្យមើលសំណង់ចេតិយ និងផ្ទាំងពាក្យស្លោកស្តីអំពីការចងចាំប្រវត្តិ-សាស្ត្រខ្មែរក្រហម។ អត្ថន័យរបស់ពាក្យស្លោកនេះ បង្ហាញឲ្យឃើញពីគន្លឹះសំខាន់ៗមួយចំនួនក្នុងការរារាំងការកកើតអំពើប្រល័យពូជសាសន៍គឺ ការយល់យោគគ្នា អត់ឱនឲ្យគ្នា និងចេះអធ្យាស្រ័យគ្នា។ មេភូមិត្រពាំងស្វាយឈ្មោះ ស៊ួស រ៉ា គឺជាអតីតកម្មាភិបាលខ្មែរក្រហម បានរៀបរាប់ពីប្រវត្តិរបស់គាត់ឆ្លងកាត់របបខ្មែរក្រហម និងបានអប់រំណែនាំសិស្សានុសិស្សឲ្យខិតខំរៀនសូត្រ និងការពារកុំឲ្យកើតមានរបបខ្មែរក្រហមម្តងទៀត។ លោកមេភូមិ ក៏បានពន្យល់ថា សំណង់ចេតិយដែលស្ថិតនៅជិតប្រមាណ១៥ម៉ែត្រពីផ្ទាំងពាក្យស្លោកនេះ គឺជាសមិទ្ធផលរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជាដែលបានផ្តល់ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងឃុំតាភេម សម្រាប់ប្រើប្រាស់ជាទីតាំងរួមក្នុងការតម្កល់អដ្ឋិធាតុសាច់ញាតិបងប្អូនដែលបានស្លាប់កាលពីជំនាន់ខ្មែរក្រហម។

បន្ទាប់ពីបញ្ចប់ទស្សនកិច្ចសិក្សានៅភូមិត្រពាំងស្វាយ យុវជនទាំងអស់បានធ្វើដំណើរបន្តទៅកាន់ទីតាំងសម្លាប់ដ៏ធំមួយក្នុងស្រុកត្រាំកក់ កាលពីជំនាន់ខ្មែរក្រហមគឺទីតាំងសម្លាប់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលជាគោលដៅចុងក្រោយសម្រាប់ទស្សនកិច្ចសិក្សារបស់សិស្សវិទ្យាល័យ ស៊ុខ អាន ដូងខ្ពស់ បូរីជលសារ ក្នុងថ្ងៃនេះ។

# សិស្សានុសិស្សមកពីវិទ្យាល័យ ជា ស៊ីម តាកែវ សិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា

ចាន់ ធីន



នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន២៨នាក់ (ស្រី១៦នាក់) មកពីវិទ្យាល័យ ជា ស៊ីម តាកែវ បានចូលរួមក្នុងវេទិកាថ្នាក់រៀនចុងសប្តាហ៍ ដែលត្រូវបានរៀបចំធ្វើនៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខែមេសា គឺជាខែដែលអំពើប្រល័យពូជសាសន៍បានកើតឡើងស្ទើរតែគ្រប់ប្រទេស ហើយក៏ជាខែដែលប្រទេសជាច្រើនប្រារព្ធធ្វើពិធីបុណ្យសាសនា ដូចជាការប្រារព្ធពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យទំនៀមទម្លាប់ និងពិធីបុណ្យសាសនាផ្សេងៗជាដើម។ ជាក់ស្តែងដូចជាប្រទេសកម្ពុជា ប្រទេសស៊ូដង់ ប្រទេសរវ៉ាន់ដា ប្រទេសបូស្នី និងប្រទេសអាមេនី គឺសុទ្ធសឹងជាប្រទេសដែលបានកើតមានអំពើប្រល័យពូជសាសន៍នៅក្នុងខែមេសា នាចុងសតវត្សរ៍ទី២០ និងដើមសតវត្សរ៍ទី២១។ នៅខែមេសានេះមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍មួយជាមួយសិស្សានុសិស្សចំនួន ២៨នាក់ (ស្រី១៦នាក់) មកពីវិទ្យាល័យ ជា ស៊ីម តាកែវ ដើម្បីផ្តល់នូវចំណេះដឹងបន្ថែមអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។ ប្រធានបទដែលលើកយកមកពិភាក្សានៅក្នុងវេទិកានេះគឺ «ការជម្លៀសប្រជាជនចេញពីទីក្រុង, ការជម្លៀសដោយបង្ខំ និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ»។




នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣ សិស្សានុសិស្ស ចំនួន២៨នាក់ (ស្រី១៦នាក់) មកពីវិទ្យាល័យ ជា ស៊ីម តាកែវ បានចូលរួមក្នុងវេទិកាថ្នាក់រៀនចុងសប្តាហ៍ ដែលត្រូវបានរៀបចំធ្វើនៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីសិស្សានុសិស្សទាំងអស់បានមកជួបជុំគ្នានៅក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ ហើយ ក្រុមការងារបានណែនាំអ្នកទាំងនោះអំពីផ្ទាំងពិព័រណ៍រូបថតស្តីពីការវិលត្រឡប់វិញនៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, មេដឹកនាំ ខ្មែរក្រហម និងបក្ខពួក, តាម៉ុក និងយុទ្ធមិត្ត និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

បន្ទាប់មកសិស្សានុសិស្សទាំងអស់ ស្តាប់ការធ្វើបទបង្ហាញរបស់លោក ដេង ពង្សរ៉ាស៊ី ស្តីពីមាតិកាប្រវត្តិសាស្ត្រខ្មែរក្រហម, និយមន័យ និងកត្តាគ្រោះថ្នាក់ដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍ និងវិធីសាស្ត្រចាំបាច់នានាក្នុងការទប់ស្កាត់អំពើហិង្សា។ ខាងក្រោមគឺជាការសង្ខេបចេញពីការធ្វើបទបង្ហាញ៖

**ទី១) កំណើននៃការចូលបម្រើបដិវត្តន៍របស់ប្រជាជនតាមរយៈការអំពាវនាវរបស់សម្តេចព្រះ នរោត្តម សីហនុ៖**

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេចព្រះនរោត្តម សីហនុ ទ្រង់បានអំពាវនាវពីទីក្រុងប៉េកាំងឲ្យប្រជាជនចូលព្រៃម៉ាគី ដើម្បីចូលរួមជាមួយរដ្ឋាភិបាលរួបរួមជាតិកម្ពុជា តាមរយៈកម្លាំងបដិវត្តន៍



ខ្មែរក្រហម។ ក្នុងពេលនោះប្រជាជននាំគ្នាចូលរួមក្នុងចលនាបដិវត្តន៍យ៉ាងច្រើនកុះករដើម្បីប្រឆាំងនឹងការគ្រប់គ្រងប្រទេសរបស់របបសាធារណរដ្ឋខ្មែរ ។

**ទី២) ផែនការវាយរំលំទីក្រុងភ្នំពេញរបស់ខ្មែរក្រហម៖**

ខ្មែរក្រហមបានកាត់ផ្តាច់ផ្លូវគោក និងផ្លូវទឹកនៅក្នុងឆ្នាំ១៩៧៤។ នៅដើមឆ្នាំ១៩៧៥ តាម៉ុកបានវាយផ្តាច់ផ្លូវអាកាសបន្ថែមទៀត ដែលជាហេតុធ្វើឲ្យ

លន់ នល់ ពិបាកក្នុងការដឹកជញ្ជូនស្បៀងអាហារ និងអាវុធយុទ្ធភណ្ឌទៅកាន់បន្ទាយរបស់ខ្លួនដែលស្ថិតនៅទីជនបទ។ ទាំងនេះជាមូលហេតុសំខាន់មួយដែលអាចឲ្យក្រុមខ្មែរក្រហមងាយស្រួលក្នុងការវាយផ្តួលរំលំរបប លន់ នល់ នៅក្នុងខែមេសា ឆ្នាំ១៩៧៥។

### ទី៣) ការចូលកាន់កាប់ទីក្រុងភ្នំពេញរបស់ខ្មែរក្រហម៖

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកទីក្រុងភ្នំពេញ ស្របពេលគ្នាដែលប្រជាជនភាគច្រើនបានស្វាគមន៍ និងអបអរសាទរកងទ័ពខ្មែរក្រហមតាមដងផ្លូវក៏មានប្រជាជនជាច្រើនទៀត បានពួនសម្ងំលាក់ខ្លួននៅក្នុងផ្ទះព្រោះខ្លាចខ្មែរក្រហមចាប់ខ្លួន ឬ បាញ់សម្លាប់ចោល។ មិនយូរប៉ុន្មានខ្មែរក្រហមបានប្រកាសឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញឆ្ពោះទៅកាន់ទីជនបទ។ ខ្មែរក្រហមបានលើកយកហេតុផលចំនួន៣ ដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ហេតុផលទាំងបីនោះគឺ អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកនៅទីក្រុងភ្នំពេញ, ប្រជាជនទាំងអស់ត្រូវចេញទៅយកស្បៀងនៅទីជនបទដោយខ្លួនឯង និងបំបែកក្រុមចារកម្មរបស់ខ្មាំង។



### ទី៤) ការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញដោយបង្ខំ៖

ប្រជាជនទទួលរងនូវការគំរាមកំហែង, ការធ្វើទារុណកម្ម, ការភ្ជង់នឹងកាំភ្លើង, ការវាយនឹងស៊ុយកាំភ្លើង ឬឧបករណ៍រឹង និងការបាញ់សម្លាប់ចោល។ ក្នុងពេលជម្លៀសដោយបង្ខំ ខ្មែរក្រហមគ្មានការលើកលែងនរណាម្នាក់ឡើយ ទាំងក្មេង ចាស់ ប្រុស ស្រី អ្នកជំងឺ ស្ត្រីមានផ្ទៃពោះ និងព្រះសង្ឃ។ ជនបរទេសទាំងឡាយត្រូវខ្មែរក្រហមបង្ខាំងនៅក្នុង

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន២៨នាក់ (ស្រី១៦នាក់) មកពីវិទ្យាល័យ ជា ស៊ីម តាកែវ បានចូលរួមក្នុងវេទិកាថ្នាក់រៀនចុងសប្តាហ៍ ដែលត្រូវបានរៀបចំធ្វើនៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



សណ្ឋាគារ ឡឺភ្នំ មុនពេលដែលអ្នកទាំងនោះត្រូវខ្មែរក្រហមបញ្ជូនបន្តទៅស្នាក់នៅបណ្ដោះអាសន្ននៅស្ថានទូតបារាំង ហើយបន្តដំណើរតាមរថយន្តទៅកាន់ព្រំដែនថៃ។

## ទី៥) ការជម្លៀសប្រជាជនដំណាក់កាលទី២ និងទី៣៖

ចាប់ពីចុងឆ្នាំ១៩៧៥ ការជម្លៀសប្រជាជនដំណាក់កាលទី២របស់ខ្មែរក្រហមបានចាប់ផ្ដើមឡើង ដោយការបញ្ជូនមនុស្សចេញពីភូមិភាគកណ្ដាល ភូមិភាគនិរតី ភូមិភាគឧត្តរ និងភូមិភាគពិសេស ចេញទៅកាន់ទីជនបទនៃបណ្ដាខេត្តផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ដើម្បីចូលរួមធ្វើកសិកម្ម។ ចំណែកឯការជម្លៀសដោយបង្ខំក្នុងដំណាក់កាលទី៣ គឺកើតឡើងនៅឆ្នាំ១៩៧៧ ហើយប្រជាជនរស់នៅក្នុងភូមិភាគបូព៌ាគឺជាអ្នកទទួលរងគ្រោះក្នុងការជម្លៀសនេះ។ ប្រជាជនត្រូវបានជម្លៀសចេញពីស្រុកកំណើតទៅកាន់ភាគពាយ័ព្យប្រទេស គឺ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបង ដើម្បីធ្វើកសិកម្ម។ មុនដំបូង ប្រជាជនទាំងនោះ ត្រូវបានប្រមូលផ្ដុំនៅត្រើយខាងកើតអ្នកលឿងដើម្បីរង់ចាំការធ្វើដំណើរបន្តមកកាន់ទីក្រុងភ្នំពេញតាមកប៉ាល់ទឹក និងរថយន្ត។ បន្ទាប់ពីមកដល់ភ្នំពេញ អ្នកទាំងនោះត្រូវស្នាក់នៅបណ្ដោះអាសន្ននៅច្បារអំពៅ និងផ្សារថ្មី ដើម្បីត្រៀមចាកចេញបន្តទៅកាន់គោលដៅចុងក្រោយគឺខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបង។

## ទី៦) ការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ៖

ទួលពោធិ៍ជ្រៃមានទីតាំងស្ថិតនៅស្រុកកណ្ដៀងក្នុងខេត្តពោធិ៍សាត់ ហើយទីទួលនេះស្ថិតនៅជាប់បឹងទន្លេសាប។ នៅឆ្នាំ១៩៧៦ ទួលពោធិ៍ជ្រៃ គឺជាទីកន្លែងសម្លាប់មនុស្ស ដែលជាប្រជាជន និងទាហានលន់ នល់ ជាច្រើនពាន់នាក់យ៉ាងរង្គាល។ អ្នកបើករថយន្តបានដឹកអ្នកទាំងអស់នោះទៅដាក់នៅទីទួលមួយ។ បន្ទាប់ពីបានមកដល់ទីទួលហើយ កម្មាភិបាលខ្មែរក្រហមបានចងដៃប្រជាជនទាំងនោះទៅក្រោយ។ ប្រជាជនទាំងអស់ ត្រូវបានសម្លាប់ដោយសារការបាញ់រះ និងចុចបំផ្ទុះពីខ្មែរក្រហម។

បន្ទាប់ពីការបញ្ចប់បទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម លោក ផេង ពង្សរ៉ាស៊ី បានបន្តធ្វើបទបង្ហាញពីនិយមន័យ កត្តាគ្រោះថ្នាក់ជាក់លាក់ដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍ និងការបង្ហាញពីវិធីសាស្ត្រមួយចំនួនក្នុងការទប់ស្កាត់អំពើហិង្សាក្នុងកម្រិតបុគ្គល គ្រួសារ សហគមន៍ និងប្រទេសជាតិ។

## ចំណាប់អារម្មណ៍របស់សិស្សានុសិស្សបន្ទាប់ពីបានចូលរួមក្នុងវេទិកាថ្នាក់រៀនចុងសប្ដាហ៍៖

ផន ពេជ្រពិសី ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យ ជា ស៊ីម តាកែវ៖

បន្ទាប់ពីនាងខ្ញុំបានចូលរួមក្នុងវេទិកាថ្នាក់រៀនចុងសប្ដាហ៍នេះ នាងខ្ញុំមានអារម្មណ៍ថា រីករាយ និងទទួលបានព័ត៌មានថ្មីៗទាក់ទងនឹងរបបខ្មែរក្រហមពីលោកគ្រូ។ ពេលបញ្ចប់វេទិកានេះ នាងខ្ញុំយល់ដឹងបានច្រើនពីរបបប្រល័យពូជសាសន៍ ដឹងពីព្រឹត្តិការណ៍ពាក់ព័ន្ធនឹងសម័យខ្មែរក្រហម និងរៀនសូត្រពីប្រវត្តិ-សាស្ត្រនោះ។ នាងខ្ញុំទទួលបានមេរៀនជាច្រើនទាក់ទងនឹងប្រជាជនក្នុងរបបខ្មែរក្រហមដែលរងទុក្ខវេទនា ខុសពីប្រជាជនបច្ចុប្បន្ននេះ។

ភួង ស្រីវង ភេទស្រី អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យ ជា ស៊ីម តាកែវ៖

បន្ទាប់ពីនាងខ្ញុំបានចូលរួមក្នុងវេទិកាថ្នាក់រៀនចុងសប្ដាហ៍នេះ នាងខ្ញុំដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម ការធ្វើទារុណកម្ម និងទីតាំងធ្វើទារុណកម្មនៅមន្ទីរ ស-២១ ព្រមទាំងវិធីធ្វើទារុណកម្ម និងសួរចម្លើយ។ យើងត្រូវលុបបំបាត់ការរើសអើង និងត្រូវសិក្សាឈ្វេងយល់ពីអំពើប្រល័យពូជសាសន៍ ដើម្បីទប់ស្កាត់កុំឲ្យវាកើតឡើងនាពេលអនាគត។

ជា ចាន់ចក្រី ភេទប្រុស អាយុ១៧ឆ្នាំ ជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យ ជា ស៊ីម តាកែវ៖

ខ្ញុំបាទធ្លាប់បានដឹងប្រវត្តិសាស្ត្រខ្មែរក្រហមខ្លះៗមកហើយ តាមរយៈលោកគ្រូអ្នកគ្រូ និងឪពុកម្តាយ។ ខ្ញុំពិតជាសោកស្តាយ បន្ទាប់ពីឪពុកម្តាយរបស់ខ្ញុំបានឆ្លងកាត់របបខ្មែរក្រហម ព្រោះគាត់ត្រូវរងទុក្ខលំបាកវេទនា និងរងទារុណកម្មរៀងរាល់ថ្ងៃ។ បន្ទាប់ពីខ្ញុំបាទបានរៀនពីលោកគ្រូនៅសាលា និងស្តាប់ឪពុកម្តាយនិយាយប្រាប់ ខ្ញុំបានយល់ដឹងបន្ថែមទៀតពីវេទិកាថ្នាក់រៀនចុងសប្តាហ៍នេះ។ ខ្ញុំគិតថាដើម្បីចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍ យើងគួរតែទប់ស្កាត់អំពើហិង្សា ការរើសអើងពូជសាសន៍ ពណ៌សម្បុរ ឬសាសនា ជាដើម។

វ៉ាន់ សុធាវ៉ា ភេទស្រី អាយុ១៨ឆ្នាំ ជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យ ជា ស៊ីម តាកែវ៖

ក្រោយពីខ្ញុំបានចូលរួមក្នុងកម្មវិធីពេញមួយព្រឹកនេះ ខ្ញុំមានអារម្មណ៍រីករាយ ព្រោះខ្ញុំទទួលបានចំណេះដឹងទាក់ទងនឹងរបបខ្មែរក្រហម ថែមទាំងបានឃើញពីទីតាំងឧក្រិដ្ឋកម្ម ក្រាំងតាចាន់ទៀត។ ខ្ញុំកាន់តែយល់ដឹងច្រើន។ យាយទួតរបស់ខ្ញុំបានប្រាប់ខ្ញុំថា គាត់ពិបាកណាស់ ព្រមទាំងមានប្រវត្តិដូរចត់មិនអាចបំភ្លេចបាន។ គាត់ត្រូវផ្លាស់ប្តូរទីលំនៅទៅស្រុកលើ រួចផ្លាស់ទៅនៅបារាយណ៍។ ពេលខ្ញុំបានមកដល់ទីតាំងឧក្រិដ្ឋកម្ម ក្រាំងតាចាន់ ខ្ញុំមានអារម្មណ៍ថាអាណិតគាត់កាន់តែខ្លាំង។



នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន២៤នាក់ (ស្រី១៦នាក់) មកពីវិទ្យាល័យ ជា ស៊ីម តាកែវ បានចូលរួមក្នុងវេទិកាថ្នាក់រៀនចុងសប្តាហ៍ ដែលត្រូវបានរៀបចំធ្វើនៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



# វេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «មូលហេតុនៃការកកើតខ្មែរក្រហម» នៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ

*ឌីម សុខគា*



សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កោះអណ្តែត ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «មូលហេតុនៃការកកើតខ្មែរក្រហម» រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «មូលហេតុនៃការកកើតខ្មែរក្រហម» ជាមួយសិស្សានុសិស្ស មកពីវិទ្យាល័យ ហ៊ុន សែន កោះអណ្តែត ចំនួន៣៥នាក់ ក្រោមការដឹកនាំរបស់លោកគ្រូ-អ្នកគ្រូ ឯកទេសប្រវត្តិវិទ្យា ចំនួន២រូប។ គោលបំណងនៃវេទិកាថ្នាក់រៀននេះ គឺជំរុញលើកទឹកចិត្តដល់យុវជន និងក្មេងៗជំនាន់ក្រោយឲ្យចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងទប់ស្កាត់ការវិលត្រឡប់នៃរបបខ្មែរក្រហមម្តងទៀត។

ជាដំបូង សិស្សានុសិស្សទស្សនាពិព័រណ៌រូបថតដែលស្ថិតនៅខាងមុខ និងខាងក្នុងការិយាល័យ។ បន្ទាប់មក សិស្សានុសិស្សទាំងអស់ត្រូវបានណែនាំឲ្យស្គាល់ពីឯកសារខ្មែរក្រហមដែលមាននៅក្នុង



សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កោះអណ្តែត ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «មូលហេតុនៃការកកើតខ្មែរក្រហម» រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទូដែកស្ថិតនៅខាងក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ នៅក្នុងឱកាសនោះ យុវជនមួយចំនួនបានសួរសំណួរទាក់ទងនឹងផ្ទាំងរូបថត និងឯកសារខ្មែរក្រហម។ នៅពេលយុវជនទាំងនោះចូលទៅក្នុងថ្នាក់រៀន ពួកគាត់បានបំពេញកម្រងសំណួរវាស់ស្ទង់ចំណេះដឹង មុនពេលវេទិកាថ្នាក់រៀនចាប់ផ្តើម។

បន្ទាប់ពីនោះមកលោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចាប់ផ្តើមធ្វើបទបង្ហាញអំពី «មូលហេតុនៃការកើតរបបខ្មែរក្រហម»។ បន្ទាប់ពីបញ្ចប់ការធ្វើបទបង្ហាញលើប្រវត្តិសាស្ត្រខ្មែរក្រហម លោក ផេង ពង្សរ៉ាស៊ី បានបន្តធ្វើបទបង្ហាញអំពីនិយមន័យអំពើប្រល័យពូជសាសន៍ និងវិធីសាស្ត្រជាក់លាក់ក្នុងការទប់ស្កាត់អំពើហិង្សាក្នុងកម្រិតបុគ្គល គ្រួសារ សហគមន៍ និងប្រទេសជាតិ។

បន្ទាប់ពីរយៈពេលប្រមាណ២ម៉ោងនៃការធ្វើបទបង្ហាញ លោក ផេង ពង្សរ៉ាស៊ីតម្រូវឲ្យសិស្សានុសិស្សបំពេញកម្រងសំណួរវាស់ស្ទង់ចំណេះដឹងក្រោយវេទិកា ដើម្បីវាស់ស្ទង់ចំណេះដឹងសិស្សក្រោយវេទិកា។ ជាចុងក្រោយក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ, គ្រូដឹកនាំ និងសិស្សានុសិស្សបានថតរូបជុំគ្នាទុកជាអនុស្សាវរីយ៍។



នៅវេលាម៉ោង២រសៀល សិស្សានុសិស្សទាំងអស់បានធ្វើដំណើរទៅកាន់អតីតមន្ទីរសន្តិសុខក្នុងរបបខ្មែរក្រហម ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ដើម្បីស្តាប់ការចែករំលែករឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទីនោះ។ លោកតា សេង ហេង សព្វថ្ងៃមានអាយុ៧៥ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានរៀបរាប់ទាក់ទងទៅនឹងទីតាំងមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រាំងតាចាន់ នៅក្នុងរបបខ្មែរក្រហម



ថា មន្ទីរសន្តិសុខនេះ គឺជាកន្លែងបង្អត់អាហារធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់អ្នកទោស។ បន្ទាប់ពីរៀបរាប់រួចហើយ លោកតា សេង ហេង បានបង្ហាញសិស្សានុសិស្សទាំងអស់ពីការបណ្តើរអ្នកទោសចូលមន្ទីរសន្តិសុខ កន្លែងឃុំឃាំង កន្លែងសួរចម្លើយ កន្លែងសម្លាប់ ហើយចុងក្រោយ គាត់បាននាំសិស្សានុសិស្សទៅមើលបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហម។

នៅក្នុងឱកាសនោះ លោក ផេង ពង្សរ៉ាស៊ី បានរៀបរាប់ប្រាប់សិស្សានុសិស្សបន្ថែមពីការបង្កើតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ហើយមន្ទីរសន្តិសុខក្រាំងតាចាន់ គឺជាមន្ទីរសន្តិសុខថ្នាក់ស្រុកមួយក្នុងចំណោមមន្ទីរសន្តិសុខទាំង១៩៧ ដែលខ្មែរក្រហមបានបង្កើតឡើង។ លោក ផេង ពង្សរ៉ាស៊ី ក៏បានលើកឡើងពីការចងក្រងរបាយការណ៍លម្អិតទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ ប្រាប់ដល់ក្រុមយុវជនទាំងអស់ឲ្យបានដឹងមុននឹងសិស្សានុសិស្សដើរទស្សនាទីតាំងផ្សេងទៀតនៅជុំវិញមន្ទីរសន្តិសុខនេះ។





សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កោះអណ្តែត ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «មូលហេតុនៃការកកើតរបបខ្មែរក្រហម» រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


















# បណ្ណាល័យមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ

បណ្ណាល័យមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូនសិស្ស និស្សិត អ្នកស្រាវជ្រាវ មន្ត្រីរាជការ អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្ដីខ្មែរក្រហម។

បណ្ណាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ គឺជាកន្លែងប្រមូលផ្ដុំ និងតម្កល់ឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងច្រើន ដែលឯកសារទាំងនោះរួមមាន៥ប្រភេទគឺ ប្រភេទឯកសារទីមួយ គឺជាឯកសារក្រដាសដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ប្រភេទឯកសារទីបី គឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួន គឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្ដៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំ គឺជាឯកសារខ្សែភាពយន្តដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈបណ្ណាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ សាធារណជនអាចមកស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស សារទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ដនិទ្ទេសបង្ហាញពីរណ្ដៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។



## បណ្ណាល័យមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ

មានទីតាំងស្ថិតនៅផ្លូវលេខ៣ ផ្ទះលេខ៩០៣ ភូមិចក សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ព្រឹក ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ សូមទាក់ទងមកលោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ តាមរយៈ:

ទូរសព្ទលេខ៖ ០១២ ៦៩៦ ៩៦១ ឬ

អ៊ីម៉ែល៖ truthrasy.p@ dccam.org

សូមអរគុណ!











# វេទិកាអប់រំសហគមន៍ស្តីពីការសន្ទនាអន្តរជំនាន់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩)

## នៅវត្តត្រើយឃ្លោក ស្ថិតនៅភូមិត្រើយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ

*ឌីម សុខគា*





នៅថ្ងៃព្រហស្បតិ៍ ទី២៧ ខែមេសា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ បានរៀបចំវេទិកាអប់រំសហគមន៍ ស្តីពីការសន្ទនាអន្តរជំនាន់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការពិនិត្យមើលពីបញ្ហាប្រឈមនានាដែលកើតមាននៅក្នុងសហគមន៍ ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន១៤នាក់ រស់នៅភូមិត្រើយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ និងសិស្សានុសិស្សមកពីវិទ្យាល័យ សុខអាន ដូងខ្ពស់ បូរីជលសារ ដែលត្រូវជាចៅៗរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១១នាក់ៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃព្រហស្បតិ៍ ទី២៧ ខែមេសា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ បានរៀបចំវេទិកាអប់រំសហគមន៍ ស្តីពីការសន្ទនាអន្តរជំនាន់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការពិនិត្យមើលពីបញ្ហាប្រឈមនានាដែលកើតមាននៅក្នុងសហគមន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១៤នាក់ ស្រី៨នាក់ រស់នៅភូមិត្រើយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ និងសិស្សានុសិស្សមកពីវិទ្យាល័យ សុខអាន ដូងខ្ពស់ បូរីជលសារ ដែលត្រូវជាចៅៗរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមៗ វេទិកានេះប្រព្រឹត្តទៅនៅក្នុងបរិវេណវត្តត្រើយឃ្លោក

ស្ថិតនៅភូមិត្រើយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ។ គោលបំណងនៃការធ្វើវេទិកានេះ គឺបង្កើតការសន្ទនាអំពីប្រវត្តិរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមដើម្បីការចងចាំ និងលើកទឹកចិត្តយុវជនជំនាន់ក្រោយឲ្យរៀនសូត្រពីបទពិសោធន៍ទាំងនេះ ដើម្បីការចងចាំបន្តវេណពីចាស់ៗក្នុងន័យថែរក្សាសន្តិភាព និងប្រឆាំងចំពោះការប្រព្រឹត្តអំពើហិង្សានានានៅក្នុងសង្គម ដែលជាកត្តានាំដល់ការកកើតអំពើប្រល័យពូជសាសន៍ម្តងទៀតនៅកម្ពុជា។ ជាមួយគ្នានេះដែរ វេទិកាក៏មានការពិភាក្សាពីបញ្ហាប្រឈមនានានៅក្នុងសហគមន៍នាពេលបច្ចុប្បន្ន ដើម្បីឈ្វេងយល់ពីតម្រូវការជាមូលដ្ឋានរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងជីវភាពប្រចាំថ្ងៃរបស់គាត់។

វេទិកានេះប្រព្រឹត្តទៅរយៈពេល២ម៉ោងកន្លះ ចាប់ពីម៉ោង៩ព្រឹក ដល់ម៉ោង១១កន្លះ ក្រោមការសហការពីអាជ្ញាធរមូលដ្ឋាន ប្រធានភូមិ អាចារ្យ និងគណៈកម្មការវត្តអ្នករស់រានមានជីវិត និងសិស្សានុសិស្សដែលជាក្មេងៗជំនាន់ក្រោយ។ ដំណើរការនៃវេទិកាបានផ្តោតសំខាន់លើ៖ ទី១ ប្រសាសន៍សំណេះសំណាលរបស់លោកមេភូមិត្រើយឃ្លោក។ ទី២ ចាក់បញ្ចាំងវីដេអូខ្លីស្តីអំពីព្រឹត្តិការណ៍ខ្មែរក្រហមឡើងកាន់អំណាចពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ទី៣ បទបង្ហាញខ្លីស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ទី៤ ការចែករំលែកបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហមពីអ្នករស់រានមានជីវិតពីរបបនេះ។ ទី៥ ការសន្ទនាអន្តរជំនាន់ទាក់ទងនឹងចម្ងល់របស់ក្មេងៗជំនាន់ក្រោយជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ស្តីពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម។ ទី៦ ការបង្ហាញពីចំណេះដឹងរបស់ក្មេងៗជំនាន់ក្រោយដែលទទួលបានពីវេទិកា និងការថ្លែងអំណរគុណ និងសេចក្តីគោរពរបស់ក្មេងៗជំនាន់ក្រោយចំពោះលោកយាយលោកតាដែលជាអ្នកចូលរួមនៅក្នុងវេទិកា និងទី៧ ការលើកឡើងពីការអភិវឌ្ឍភូមិឃុំ និងបញ្ហាប្រឈមដែលកំពុងកើតមាននៅក្នុងភូមិ ។

**១) មតិស្វាគមន៍របស់ប្រធានភូមិត្រើយឃ្លោក៖**

លោកមេភូមិបានថ្លែងបើកកម្មវិធីវេទិកា និងលើកទឹកចិត្តដល់អ្នករស់រានមានជីវិតទាំងអស់ឲ្យចែករំលែកបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហមប្រាប់ដល់ក្មេងៗជំនាន់ក្រោយ។ ជាមួយគ្នានេះដែរ លោកមេភូមិក៏បានណែនាំដល់ក្មេងៗជំនាន់ក្រោយទាំងអស់ឲ្យយកចិត្តទុកដាក់ស្តាប់ការនិយាយរបស់លោកយាយ លោកតា ពីប្រវត្តិរបស់គាត់ដើម្បីទទួលបានចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ចុងក្រោយ លោកមេភូមិក៏បានលើកឡើងពីបទពិសោធន៍របស់គាត់ឆ្លងកាត់របបខ្មែរក្រហម និងបានប្រាប់ពីទីតាំងដែលកំពុងរៀបចំវេទិកានេះថា ជាអតីតកន្លែងដលិតថ្នាំពេទ្យក្នុងរបបខ្មែរក្រហម និងកន្លែងកប់សាកសពប្រជាជនដែលស្លាប់ដោយសារជំងឺ។

**២) ការចាក់បញ្ចាំងវីដេអូឯកសារចំណងជើង «សម័យខ្មែរក្រហម»៖**

ខ្សែវីដេអូឯកសាររយៈ២០នាទី ស្តីពីព្រឹត្តិការណ៍សំខាន់ៗ ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ត្រូវបានចាក់បញ្ចាំងឲ្យអ្នកចូលរួមទស្សនា។ នេះជាលើកទី១ហើយ ដែលគាត់បានទស្សនាវីដេអូឯកសារស្តីពីរបបខ្មែរក្រហម។ អ្នកចូលរួមម្នាក់ៗបានយកចិត្តទុកដាក់ទស្សនា និងពិភាក្សាគ្នាពីជីវិតពិតរបស់ខ្លួន ដោយប្រៀបធៀបទៅនឹងខ្សែវីដេអូនេះ។ អ៊ំប្រុសម្នាក់ បានងាកទៅផ្តាំផ្ញើក្មេងៗដែលកំពុងទស្សនាដូចគ្នាថា «ចៅៗ! ទាំងអស់ដែលមាននៅក្នុងកុនហ្នឹង គឺសុទ្ធតែជារឿងពិតទាំងអស់ ហើយមានកន្លែងខ្លះនៅក្នុងកុនហ្នឹង មិនលំបាកដល់តាកាលពីជំនាន់នោះផង»។

**៣) បទបង្ហាញខ្លីពីការអនុវត្តគោលនយោបាយបំផ្លិចបំផ្លាញជីវិតមនុស្ស និងប្រទេសជាតិ៖**

លោក ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានបង្ហាញពីការអនុវត្តគោលការណ៍៨ចំណុចរបស់ខ្មែរក្រហម ដែលនាំឲ្យមានការកាប់សម្លាប់ប្រជាជន គ្រោះអត់ឃ្លាន កើតមានជំងឺផ្សេងៗ ការធ្វើទារុណកម្ម



នៅថ្ងៃព្រហស្បតិ៍ ទី២៧ ខែមេសា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ បានរៀបចំវេទិកាអប់រំសហគមន៍ ស្តីពីការសន្ទនាអន្តរជំនាន់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការពិនិត្យមើលពីបញ្ហាប្រឈមនានាដែលកើតមាននៅក្នុងសហគមន៍ ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១៨នាក់ រស់នៅភូមិត្រើយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ និងសិស្សានុសិស្សមកពីវិទ្យាល័យ ស៊ុំអាន ដូងខ្ពស់ បូរីជលសារ ដែលត្រូវជាចៅៗរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១១នាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការបែកបាក់ក្រុមគ្រួសារ និងការធ្វើការហួសកម្លាំងៗ អ៊ំប្រុស អ៊ិន ពិន ជាអាចារ្យវត្តត្រើយឃ្លោក បានលើកឡើងថា ការអនុវត្តគោលនយោបាយទាំងនេះ គឺជាកំហុសរបស់មេដឹកនាំ ប៉ុល ពត ដែលមិនបានគិតគូរពីសុខទុក្ខរបស់ប្រជាជនខ្លួនឯងៗ អ៊ំប្រុសមិនស្គាល់ឈ្មោះម្នាក់ទៀតបានបន្ថែមថា «ដោយសារតែដូច្នេះហើយ បានជា ប៉ុល ពត មិនអាចគ្រប់គ្រងអំណាចបានយូរលើសពីបីឆ្នាំ»។ អ៊ំស្រីម្នាក់ដែលអង្គុយនៅចំកណ្តាល បានបន្ថែមថា «ឲ្យចប់ទៅ! ខ្ញុំមិនចង់ឲ្យរបបហ្នឹងនៅបន្តទៀតទេ។ បើនៅបន្តទៀតប្រាកដជាមានមនុស្សស្លាប់ច្រើនជាងហ្នឹងទៀត»។ ក្មេងៗបានស្តាប់ពួការនិយាយគ្នានេះ ប៉ុន្តែមិនបានតបតអ្វីឡើយ។

## ៤) ការពិភាក្សាអន្តរជំនាន់ និងការលើកឡើងពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖

អ៊ំប្រុសអិនពិនបច្ចុប្បន្នរស់នៅភូមិត្រើយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ បានរៀបរាប់ថា៖ នៅក្នុងរបប ប៉ុល ពត ខ្ញុំជួបការលំបាកដោយធ្វើការហួសកម្លាំងៗ ខ្មែរក្រហមប្រើខ្ញុំឲ្យរែកដីបង្គីធំៗ ហើយត្រូវដាក់បង្គីត្រួតលើគ្នាទៀតៗ នៅឆ្នាំ១៩៧៣ ខ្ញុំបានទៅធ្វើស្រែ និងជីកប្រឡាយនៅខាងកើតកោះអណ្តែតៗ ពេលជិតបែក ខ្ញុំបានទៅលើកទំនប់សាមគ្គីក្រោមការអ្នកគ្រប់គ្រងរបស់ តាគីនៅព្រៃបុស្សី ឃុំអង្គញ់ៗ តាគីនិយាយថា «មាននរណាចង់ទៅវាយមនុស្សចោលអត់?» គ្មាននរណាហ៊ានឆ្លើយទេៗ ខ្ញុំធ្លាប់បានឃើញខ្មែរក្រហមបណ្តើរប្រជាជន១៧មេសា ជាទាហាន លន់ នល់ និង

ប្រជាជនធម្មតាយកទៅសម្លាប់ដោយត្បូងចប និងស៊ុយការាំភ្លើងនៅត្រពាំងត្រកៀត ស្ថិតនៅខាងលិចវត្តត្រើយឃ្លោកប្រហែល៦០ ទៅ៧០នាក់។ អញ្ចឹងហើយសូមក្មួយៗជំនាន់ក្រោយ ដែលមិនទាន់ធ្លាប់ឆ្លងកាត់ត្រូវយកចិត្តទុកដាក់ចំពោះអនុសាសន៍ និងការបញ្ចាំងវីដេអូអំពីការរស់នៅក្នុងរបបប៉ុល ពត ហើយត្រូវការពារកុំឲ្យរបបនេះវិលត្រឡប់មកម្តងទៀត។ ចុងក្រោយ ខ្ញុំរំឭកដល់ក្មួយៗត្រូវមានការប្រុងប្រយ័ត្ន និងការពារកុំឲ្យរបបខ្មែរក្រហមកើតមានឡើងវិញ យើងត្រូវសាមគ្គីគ្នាជាធ្លុងមួយដើម្បីរស់នៅមានភាពសុខសប្បាយទាំងអស់គ្នា។

អ៊ំស្រី ប៉ុក សេគា អាយុ៦១ឆ្នាំ រស់នៅភូមិត្រើយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ លើកឡើងថា នៅក្នុងរបបខ្មែរក្រហមខ្ញុំបានជួបការលំបាកខ្លាំងណាស់។ ដំបូងខ្មែរក្រហមឲ្យខ្ញុំចូលកងកុមារវែកដីដំបូក។ ខ្ញុំត្រូវបែកពីឪពុកម្តាយទៅរស់នៅក្នុងកងចល័ត។ ក្រោយមក ខ្ញុំរត់រហូតទៅដល់ភ្នំដងរែក។ ខ្ញុំមានការឈឺចាប់និងផ្តាំប្អូនៗជំនាន់ក្រោយឲ្យខិតខំរៀនសូត្រ មានចំណេះវិជ្ជាខ្ពង់ខ្ពស់ជាទំពាំងស្នងឫស្សីនាពេលខាងមុខ។

លោកតាជ្រី ជ្រាង អាយុ៧២ឆ្នាំ រស់នៅភូមិត្រើយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ បានរៀបរាប់ថា នៅក្នុងរបបខ្មែរក្រហមពួកវាប្រើមនុស្សចាស់ឲ្យរែកទឹកមួយថ្ងៃឲ្យបានប្រាំមួយអម្រែក ដើម្បីស្រោចថ្នាំជក់។ កុមារា កុមារី ត្រូវខ្មែរក្រហមប្រើឲ្យកាប់ដីដំបូក កាប់ទន្រ្ទានខែត្រយកទៅធ្វើជីដោយលាយជាមួយលាមកនឹងដៃទទេ។ ខ្មែរក្រហមប្រើខ្ញុំឲ្យជីកប្រឡាយ និងរែកដី។ ខ្ញុំខំប្រឹងធ្វើការណាស់ ព្រោះខ្លាចខ្មែរក្រហមសម្លាប់។ ខ្ញុំហូបបបរតែមួយវែកប៉ុណ្ណោះ។ សូម្បីតែសម្លព្រលិតដែលនៅសល់ក៏ខ្មែរក្រហមមិនឲ្យហូបដែរ។

យិន សាំ បានរៀបរាប់ថា ប្អូនៗយុវជនទាំងអស់រឿងនៅក្នុងរបបខ្មែរក្រហមខ្ញុំនិងចាស់ៗផ្សេងៗទៀតធ្លាប់ជួបហើយ។ សូមប្អូនៗជំនាន់ក្រោយជួយចងចាំនៅសម័យ ប៉ុល ពត ដែលលោកអ៊ំៗ និងយាយតាលើកឡើងនេះមិនមានអ្វីខុសគ្នាទេ។

តមកទៀត យុវជនមួយរូបលើកជាសំណួរថា «តើក្នុងរបបខ្មែរក្រហម មានអ្នកមានផ្ទៃពោះដែរឬទេ? ប្រសិនជាមាន តើគាត់បានឈប់សម្រាកពេលសម្រាលកូនរយៈពេលប៉ុន្មានថ្ងៃ?» លោកគ្រូ ខទ្ទេស បានប្រគល់តួនាទីជូនប្រធានភូមិត្រើយឃ្លោកជាអ្នកបកស្រាយ ហើយការបកស្រាយនេះមានដូចតទៅ៖ «ការសម្រាលកូន គឺមិនមានពេទ្យត្រឹមត្រូវទេ ពីដើមមានតែឆ្មបនៅតាមភូមិ។ ស្ត្រីដែលមានផ្ទៃពោះត្រូវសម្រាលកូនខ្មែរក្រហមឲ្យឈប់សម្រាកចំនួន១ខែ។ ពេលដែលអ្នកនោះរឹងដៃរឹងជើងហើយត្រូវទៅធ្វើការវិញ។ ចំណែកកូនទុកឲ្យយាយៗមើដោះជាអ្នកចិញ្ចឹម ហើយម៉ែដោះមិនមានទឹកដោះគោឲ្យបៅដូចសព្វថ្ងៃទេមានតែទឹកបបរឬបាយត្រូវកិនឲ្យហ្មត់បញ្ចុកក្មេងតូចនោះ។ ម្តាយអាចមកបំបៅកូនបានមួយភ្លែតៗប៉ុណ្ណោះ»។

## ៥) ចំណាប់អារម្មណ៍របស់ក្មេងៗជំនាន់ក្រោយ

យុវតីឈ្មោះ ជឿន ដាន់ណា ជាសិស្សរៀននៅវិទ្យាល័យដូងខ្ពស់ បានបញ្ចេញនូវចំណាប់អារម្មណ៍ផ្ទាល់ខ្លួនថា «ខ្ញុំមានអារម្មណ៍ឈឺចាប់ ព្រោះរបបខ្មែរក្រហមជារបបមួយដែលសម្លាប់មនុស្សយ៉ាងរង្គាលដោយមិនញញើតដៃ និងផ្តាច់ការ។



នៅថ្ងៃព្រហស្បតិ៍ ទី២៧ ខែមេសា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ បានរៀបចំវេទិកាអប់រំសហគមន៍ ស្តីពីការសន្ទនាអន្តរជំនាន់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការពិនិត្យមើលពីបញ្ហាប្រឈមនានាដែលកើតមាននៅក្នុងសហគមន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១៤នាក់ រស់នៅភូមិត្រើយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ និងក្មេងៗជាសិស្សានុសិស្សមកពីវិទ្យាល័យ សុខអាន ដូងខ្ពស់ បូរីជលសារ ដែលត្រូវជាចៅៗរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១១នាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំមិនចង់ឲ្យរបបខ្មែរក្រហមកើតជាលើកទី២ទេ។ ខ្ញុំសូមសំណូមពរឲ្យលោកគ្រូបង្កើតកម្មវិធីនេះឲ្យបានញឹកញាប់ដើម្បីឲ្យប្អូនៗជំនាន់ក្រោយបានយល់ដឹងពីការសម្លាប់យ៉ាងរង្គាលនៅក្នុងរបបនោះ»។

### ៦) តម្រូវការរបស់អ្នករស់រានមានជីវិតក្នុងភូមិត្រើយឃ្លោកនាពេលបច្ចុប្បន្ន សម្រាប់ការអភិវឌ្ឍភូមិឃុំ

លោកមេភូមិត្រើយឃ្លោក បានលើកឡើងតម្រូវការមួយចំនួនដែលប្រជាជននៅក្នុងភូមិត្រូវការជាចំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ។ ក្នុងនោះមានដូចជា លូបង្ហូរទឹកនៅតាមសងខាងផ្លូវដែលទើបកសាងរួចជាដើម។ ចំណុចនេះ លោកមេភូមិបានពន្យល់ថា ប្រជាជនភាគច្រើនមិនមានថវិកាក្នុងការទិញលូបង្ហូរទឹកសម្រាប់ដាក់តាមសងខាងផ្លូវកាត់មុខផ្ទះរបស់ខ្លួនឡើយ។ លោកមេភូមិបានបន្តថា ប្រសិនជាគ្មានលូបង្ហូរទឹកទេ ផ្លូវថ្មីមួយខ្សែនេះអាចនឹងត្រូវលិចទឹកពេលមានភ្លៀងធ្លាក់ ហើយអាចបណ្តាលឲ្យឆាប់ខូច។ លោកមេភូមិស្នើសុំឲ្យមានសប្បុរសជនផ្តល់ជាជំនួយ លូបង្ហូរទឹកចំនួន៨០០លូ ដើម្បីបំពេញបន្ថែមលើការដាក់លូបង្ហូរទឹកក្នុងភូមិរបស់គាត់។ តម្រូវការទីពីរដែលមេភូមិត្រូវការគឺបង្គន់អនាម័យ និងបន្ទប់ទឹកសម្រាប់អគារទើបសាងសង់ថ្មីសម្រាប់រៀបចំការប្រជុំនានាក្នុងភូមិ។








នៅថ្ងៃព្រហស្បតិ៍ ទី២៧ ខែមេសា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ បានរៀបចំវេទិកាអប់រំសហគមន៍ ស្តីពីការសន្ទនាអន្តរជំនាន់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការពិនិត្យមើលពីបញ្ហាប្រឈមនានាដែលកើតមាននៅក្នុងសហគមន៍ ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១៨នាក់ រស់នៅភូមិត្រើយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ និងក្មេងៗជាសិស្សានុសិស្សមកពីវិទ្យាល័យ សុខអាន ដូងខ្ពស់ បូរីជលសារ ដែលត្រូវជាចៅៗរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១១នាក់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឈន ខិន្នែត ៖ ខ្មែរក្រហមយកឪពុកខ្ញុំទៅសម្លាប់ដោយសារតែបណ្តោយឱ្យគោស៊ីកណ្តាប់

*សៀង កញ្ញា និង ហៀក ស្រីពេជ្រ*

ខ្ញុំឈ្មោះ ឈន ខិន្នែត អាយុ ៥៤ឆ្នាំ កើតនៅក្នុងភូមិត្រពាំងខ្វារ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត។ ខ្ញុំមានម្តាយឈ្មោះ ប៊ី សែ និងឪពុកឈ្មោះ ឈន សន (ស្លាប់)។ ខ្ញុំមានបងប្អូនបង្កើត៦នាក់ (ស្លាប់២នាក់)។ កាលពីកុមារភាព ខ្ញុំរៀនបានតិចតួចណាស់ ដោយសារខ្ញុំខ្សត់ខ្សោយ ហើយ និងមានការរាំងស្ទះរយៈពេលវែងរវាងកងទ័ព លន់ នល់ និងក្រុមខ្មែរក្រហម ដែលបណ្តាលឲ្យមានចលាចលជាញឹកញាប់។

នៅក្នុងរបបខ្មែរក្រហមគ្រួសាររបស់ខ្ញុំកាន់តែលំបាកខ្លាំង។ ឪពុករបស់ខ្ញុំគឺជាគ្រូបង្រៀន ដូច្នេះខ្មែរក្រហមបានចាត់ទុកគ្រួសារខ្ញុំគឺជាពួកមូលធន។ អង្គការបានជម្លៀសគ្រួសារខ្ញុំឲ្យទៅរស់នៅក្នុងភូមិថ្មីមួយទៀត។ ប្រជាជនដែលរស់នៅទីនោះអង្គការហៅថាជាពួកបញ្ញើ ឬប្រជាជនត្រៀម។ អង្គការបានចាត់តាំងឪពុកខ្ញុំឲ្យបររទេះដឹកកណ្តាប់ស្រូវ, ម្តាយរបស់ខ្ញុំច្រូតស្រូវ ហើយបងប្អូនរបស់ខ្ញុំ និងខ្ញុំដញ្ជូនកណ្តាប់ស្រូវ។ មានថ្ងៃមួយ គោដែលឪពុករបស់ខ្ញុំយកទៅទឹមរទេះបានស៊ីកណ្តាប់ស្រូវ។ ខ្មែរក្រហមក៏នាំយកឪពុកខ្ញុំទៅវាយសម្លាប់ចោល។ ដំបូង ខ្ញុំនិងម្តាយមិនដឹងថាខ្មែរក្រហមយកឪពុកខ្ញុំទៅសម្លាប់ទេ គឺមានអ៊ំប្រុសម្នាក់ដែលបររទេះដឹកកណ្តាប់ស្រូវជាមួយឪពុកខ្ញុំបានឃើញខ្មែរក្រហមសម្លាប់ឪពុករបស់ខ្ញុំផ្ទាល់នឹងភ្នែក ហើយគាត់ក៏យកដំណឹងនេះមកប្រាប់គ្រួសារខ្ញុំ។ ក្រោយពេលដឹងថាឪពុករបស់ខ្ញុំស្លាប់ ម្តាយរបស់ខ្ញុំឈឺចិត្តយ៉ាងខ្លាំង ប៉ុន្តែគាត់មិនហ៊ានយំទេព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោលទៀត។ មានយប់មួយ ខ្ញុំនឹកឪពុកពេក ខ្ញុំយំ។ ពេលនោះកងឈ្លបបានមកលបមើលខ្ញុំ និងបម្រុងយកខ្ញុំចេញទៅ ប៉ុន្តែខ្ញុំធ្វើពុតជាយល់សប្តិ ទើបកងឈ្លបម្នាក់នោះដើរចេញទៅវិញ។ ចំណែកបងស្រីរបស់ខ្ញុំ២នាក់ទៀតបានស្លាប់ដោយសារធ្វើការងារបាក់កម្លាំង និងហូបមិនគ្រប់គ្រាន់។ នៅពេលនោះមានស្ត្រីពោះធំម្នាក់ចាញ់កូន។ គាត់លួចបេះផ្លែឈើហូប ប៉ុន្តែខ្មែរក្រហមបានតាមទាន់ក៏យកស្ត្រីនោះទៅសម្លាប់ចោល។ ពេលខ្ញុំឃើញហេតុការណ៍នេះ ខ្ញុំភិតភ័យខ្លាំងណាស់។ ខ្ញុំមិនហ៊ាននិយាយពីហេតុការណ៍ដែលខ្ញុំបានឃើញទេ ព្រោះខ្ញុំភ័យខ្លាចខ្មែរក្រហមយកខ្ញុំទៅសម្លាប់។ ខ្មែរក្រហមបានប្រើអ្នកទោសឲ្យជីករណ្តៅ។ នៅពេលជីករណ្តៅរួចហើយ ខ្មែរក្រហមវាយអ្នកទោសនោះទម្លាក់ចូលទៅក្នុងរណ្តៅ។ អ្នកទោសខ្លះមិនទាន់ស្លាប់ទេ ដូច្នេះខ្មែរក្រហមក៏កាយដីកប់ពីលើ។ ខ្ញុំមិនហ៊ានប្រកែកឬក៏តវ៉ាជាមួយខ្មែរក្រហមទេ ទោះបីជាខ្មែរក្រហមសម្លាប់ឪពុករបស់ខ្ញុំ, ប្រើខ្ញុំឲ្យធ្វើការងារហួសកម្លាំង,



ឈន ខិន្នែត អាយុ៥៤ឆ្នាំ កើតនៅក្នុងភូមិត្រពាំងខ្វារ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មិនឲ្យហូបឆ្អែត និងមិនផ្តល់សម្លៀកបំពាក់ឲ្យខ្ញុំក៏ដោយ។ ក្រោយមក ខ្មែរក្រហមបានប្រើខ្ញុំឲ្យបុកអង្ករដើម្បីត្រៀមធ្វើនំបញ្ចុកសម្រាប់ពិធីបុណ្យ ប៉ុន្តែពេលជិតដល់ថ្ងៃបុណ្យកងទ័ពវៀតណាមបានវាយចូលមកដល់។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានចូលរៀននៅសាលា រហូតបានប្រឡងជាប់ជាគ្រូបង្រៀន។ ក្រោយមក ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំឈ្មោះ អ៊ុក សាវ៉ាត់ និងមានកូនប្រុស២នាក់។ ខ្ញុំប្រកបមុខរបរជាគ្រូបង្រៀនរហូតមកដល់បច្ចុប្បន្ន។

# ប៊ុន វ៉ាត ៖ ឪពុកម្តាយខ្ញុំស្លាប់ដោយសារជំងឺ និងអត់អាហារ

សៀង កញ្ញា

ខ្ញុំឈ្មោះ ប៊ុន វ៉ាត ភេទប្រុស កើតនៅឆ្នាំ១៩៥៨ នៅភូមិត្រពាំងព្រីង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ប៊ុន កេន និងម្តាយឈ្មោះ នាង នូ។ ឪពុកម្តាយខ្ញុំស្លាប់ដោយសារជំងឺ និងអត់អាហារនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំមានបងប្អូនបង្កើតចំនួន៨នាក់គឺស្រី៣នាក់ និងប្រុស៥នាក់ ហើយខ្ញុំគឺជាកូនទី៤នៅក្នុងគ្រួសារ។ បងប្អូនរបស់ខ្ញុំ៣នាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម។

កាលពីកុមារ ខ្ញុំរៀនបានដល់ថ្នាក់ទី១១ក្នុងសង្គមចាស់។ កាលនោះគ្រូបង្រៀនរបស់ខ្ញុំគឺជាព្រះសង្ឃដែលមានព្រះនាម ថ្លាង។ នៅឆ្នាំ១៩៧០ ខ្ញុំបានឈប់រៀនដោយសារតែប្រទេសជាតិមានសង្គ្រាម។ កាលនោះខ្ញុំមានអាយុ១២ឆ្នាំ។ ខ្ញុំមិនត្រូវរដ្ឋាភិបាល លន់ នល់ ជ្រើសឲ្យចូលធ្វើជាកងទ័ពឡើយ ប៉ុន្តែបងប្រុសរបស់ខ្ញុំម្នាក់ត្រូវបានរដ្ឋាភិបាលជ្រើសរើសគាត់ឲ្យចូលធ្វើជាទាហានដើម្បីបម្រើជាតិ។ ដោយសារតែនៅក្នុងភូមិត្រពាំងព្រីងមិនសូវមានសុវត្ថិភាព ខ្ញុំនិងគ្រួសារបាននាំគ្នាមកជួលផ្ទះស្នាក់នៅបណ្តោះអាសន្ននៅក្នុងភូមិចក សង្កាត់រការក្នុង ក្រុងដូនកែវ ខេត្តតាកែវ រយៈពេលប្រហែលបីឆ្នាំ។ នៅពេលដែលខ្ញុំនិងគ្រួសារមិនមានលុយបង់ថ្លៃផ្ទះ យើងត្រូវបង់ជាស្រូវទៅឲ្យម្ចាស់ផ្ទះ។

នៅវេលាម៉ោង៧ព្រឹក ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឮខ្មែរក្រហមប្រកាសថា ខ្លួនបានចូលទៅដល់ទីក្រុងភ្នំពេញហើយ ហើយប្រជាជនដែលនៅទីក្រុងភ្នំពេញទាំងអស់ត្រូវទៅរស់នៅទីជនបទវិញ។ ក្រោយមកខ្មែរក្រហមបានជម្លៀសខ្ញុំ គ្រួសារខ្ញុំនិងប្រជាជនឯទៀតចេញពីភូមិចក ទៅភូមិចំប៉ាលើក ស្ថិតនៅក្នុងឃុំតាភេម ស្រុកត្រាំកក់វិញ។ ដំបូងខ្មែរក្រហមមិនទាន់ឲ្យយើងហូបបាយរួមគ្នាទេ គឺបានចែកអង្ករឲ្យប្រជាជនម្នាក់មួយកំប៉ុងយកទៅដាំហូបរៀងខ្លួន។

នៅខែតុលា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងគ្រួសារទៅនៅឃុំបារាយណ៍ ស្រុកទ្រាំង តំបន់១០៧ វិញ។ ខ្មែរក្រហមបំបែកខ្ញុំចេញពីគ្រួសារ និងឲ្យទៅធ្វើការក្នុងកងចល័ត។ ខ្មែរក្រហមប្រើខ្ញុំឲ្យលើកទំនប់ និងជីកប្រឡាយ។

នៅខែកក្កដា ឆ្នាំ១៩៧៦ ម្តាយរបស់ខ្ញុំស្លាប់ដោយសារអត់អាហារហូប។ នៅខែឧសភា ឆ្នាំ១៩៧៧ ខ្មែរក្រហមបានផ្លាស់ខ្ញុំឲ្យមកជីកប្រឡាយនៅត្នោតជុំវិញ។ ថ្ងៃមួយមានភ្លៀងធ្លាក់យ៉ាងខ្លាំង ខ្ញុំមានអារម្មណ៍ឯកោ និងកំសត់យ៉ាងខ្លាំង។ នៅពេលយប់ខ្ញុំមិនមានកន្លែងស្នាក់នៅសមរម្យទេ។ ខ្ញុំដេកនៅតាមការដ្ឋានការងារដោយយកស្លឹកត្នោតដែលមានទទឹង



ប៊ុន វ៉ាត រស់នៅភូមិត្រពាំងព្រីង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រវែងមួយហត្ថ (កន្លះម៉ែត្រ) ដែលដេររួច គ្របពីលើមុខកុំឲ្យទទឹកទឹកភ្លៀង។

នៅខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំបានបាត់បង់ឪពុកម្នាក់ទៀត។ ឪពុករបស់ខ្ញុំបានស្លាប់ដោយសារជំងឺ។ មុនពេលឪពុកខ្ញុំស្លាប់ បងស្រីខ្ញុំតែងតែលួចទៅជួបគាត់ជាញឹកញាប់ ប៉ុន្តែពេលបងស្រីទៅមើលគាត់ជាលើកចុងក្រោយ ឪពុករបស់ខ្ញុំបានស្លាប់បាត់ទៅហើយ។ ខ្ញុំនិងបងស្រីឈឺចាប់ណាស់ និងអាឡោះអាល័យឪពុកខ្ញុំយ៉ាងខ្លាំង។ នៅពេលនោះ ការហូបចុកមានការខ្វះខាតយ៉ាងខ្លាំង ខ្មែរក្រហមបានបើកអង្ករ៧ខាំឲ្យមនុស្ស

១០នាក់ហូបៗ ដោយសារតែខ្ញុំហូបមិនឆ្អែត និងហត់នឿយខ្លាំងពេក ខ្ញុំធ្វើពុតជាឈឺៗ ទោះបីយ៉ាងណាក៏ដោយក៏ខ្មែរក្រហមមិនឲ្យខ្ញុំសម្រាកទេ និងបានផ្លាស់ខ្ញុំពីលើកទំនប់ឲ្យទៅដកសំណាបម្ដង និងបានកំណត់ឲ្យខ្ញុំដកសំណាបឲ្យបាន៥ដិបក្នុងមួយថ្ងៃ។

មានថ្ងៃមួយ ខ្ញុំដួលសន្លប់នៅការដ្ឋាន ពេលនោះអ្នកដែលនៅធ្វើការជាមួយខ្ញុំបានសែងខ្ញុំយកទៅព្យាបាលនៅមន្ទីរពេទ្យ។ នៅពេលទៅដល់ពេទ្យ ខ្ញុំបានដឹងខ្លួនឡើងវិញ។ ខ្ញុំមិនចង់ព្យាបាលនៅក្នុងមន្ទីរពេទ្យឡើយ ព្រោះមានអ្នកប្រាប់ខ្ញុំថា នៅពេលអ្នកជំងឺឈឺរ៉ាំរ៉ៃ និងមិនងាយជាសះស្បើយ គ្រូពេទ្យនឹងចាក់ថ្នាំសម្លាប់អ្នកជំងឺនោះ។ មានពេលមួយប្អូនស្រីរបស់ខ្ញុំបានលួចទៅជួបបងស្រីខ្ញុំហើយកងឈ្លបតាមទាន់ក៏ធ្វើទារុណកម្មប្អូនស្រីខ្ញុំ ដោយកប់ប្អូនស្រីខ្ញុំត្រឹមករយៈពេលបីម៉ោងដើម្បីឲ្យប្អូនស្រីខ្ញុំរៀងចាល។ ខ្មែរក្រហមមិនយោគយល់ដល់ក្មេងៗឡើយ។

មិនយូរប៉ុន្មាន កងទ័ពវៀតណាមបានវាយចូលមក។ ពេលនោះខ្មែរក្រហមបានកៀរគ្រួសារខ្ញុំ និងប្រជាជនឯទៀតឲ្យទៅភាគខាងលិច។ ដោយសារតែប្រជាជនមួយចំនួនមានវ័យចំណាស់មិនអាចបន្តដំណើរទៅមុខបាន យើងក៏នាំគ្នាឈប់សម្រាកនៅវត្តមុន្នីរង្សី ជាទីកន្លែងដែលកងទ័ពវៀតណាមស្ទាក់យើងជាប់។ កងទ័ពវៀតណាមប្រាប់យើងឲ្យត្រឡប់មកស្រុកកំណើតរៀងៗខ្លួនវិញ។ ពេលមកដល់ភូមិត្រពាំងព្រីង ផ្ទះរបស់ខ្ញុំត្រូវភ្លើងឆេះអស់ទៅហើយ ដូច្នេះខ្ញុំនិងគ្រួសារបាននាំគ្នាសាងសង់ផ្ទះថ្មីដើម្បីស្នាក់នៅ។ នៅឆ្នាំ១៩៨១ ខ្ញុំបានរៀបការប្រពន្ធ និងបានប្រកបរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។




ប៊ុន វ៉ាត ទទួលប្រអប់អនុស្សាវរីយ៍ពី ស៊ាង កញ្ញា បុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖

កងកុមារីវ័យជំទង់ កំពុងដឹកជញ្ជូនសម្ភារ និងគ្រាប់រំសេវ។ រូបថតប្រហែលក្នុងឆ្នាំ១៩៧៧។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

និមិត្តសញ្ញាអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា

DOCUMENTATION CENTER OF CAMBODIA ORGANIZATION


**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ១២ ៨៨២ ៥០៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 12 882 505 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Special Issue 2023 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.